សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# អំពើសញ្ញាកម្ម

ស្រាវជ្រាវពីថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៧ ដល់ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៧

ស្រាវជ្រាវដោយៈ
និស្សិតឈ្មោះ លោក **ម៉ែត ភាលីន**
កញ្ញា **ភុល ស្រីមាន**

សាស្ត្រាចារ្យណែនាំ
លោក **ជួន ម៉ុនធី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ១៧

ឆ្នាំចូលសិក្សា ២០១៣

ឆ្នាំសរសេរសារណា ២០១៧

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំទាំងពីរឈ្មោះ **វ៉ែត ភាលីន** និង **កុល ស្រីមាន** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែក នីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី១៧ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០១៦-២០១៧ ។

## សូមសម្តែងនូវគារវកិច្ច និងសេចក្តីកតញ្ញូតាធម៌

— ជូនចំពោះអ្នកមានគុណទាំងពីរ ដែលលោក បានផ្តល់កំណើត ឱ្យកូនមានជីវិតរស់រានបាន ឃើញពិភពលោកដ៏ធំទូលាយមួយនេះ។ លើសពីនេះទៅទៀតលោកទាំងពីរក៏បានចិញ្ចឹមបីបាច់ថែរក្សា អប់រំ ទូន្មាន ប្រៀនប្រដៅ កូនតាំងពីតូចរហូតដល់ធំដឹងក្តី និងបានផ្គត់ផ្គង់ដល់ការសិក្សារៀនសូត្រ រហូតដល់បញ្ចប់ការសិក្សាថ្នាក់បរិញ្ញបត្រនីតិសាស្ត្រប្រកបដោយភាពជោគជ័យ។គុណូបការៈរបស់លោកទាំងពីរពិតជាមានទំហំធំធេង ពុំអាចកាត់ថ្លៃបានឡើយសម្រាប់កូន ។ ទឹកចិត្ត និង ការស្រឡាញ់របស់អ្នកទាំងពីរ បានផ្តល់នូវកម្លាំងចលករ ជម្រុញឱ្យកូនកាន់តែខិតខំប្រឹងប្រែងសិក្សារៀនសូត្រ រហូតក្លាយទៅជាកូនល្អ សិស្សល្អ និងពលរដ្ឋល្អ សំរាប់សង្គមជាតិទាំងមូល ប្រសិនបើគ្មានលោកអ្នកមានគុណទាំងពីរទេ ប្រហែលជាកូនគ្មានថ្ងៃនេះឡើយ ។

— ជូនចំពោះឯឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង និង លោក លោកស្រី ដែលជាសាស្ត្រាចារ្យដែលបានបម្រើការងារនៅ ក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ទាំងអស់ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ទាំងកម្លាំងកាយ និងចិត្ត នៅក្នុងការបង្ហាត់បង្រៀនដល់និស្សិតទាំងអស់ ។

— ជាពិសេសលោកសាស្ត្រាចារ្យ **ជួន ម៉ុនធី** ដែលបានណែនាំយើងខ្ញុំទាំងពីរនាក់នៅក្នុងការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រនេះ ពោលគឺលោកសាស្ត្រាចារ្យ តែងតែ ចង្អុលបង្ហាញអំពីទិសដៅនៅក្នុងការសរសេរ ក៏ដូចជា ផ្តល់អនុសាសន៍ល្អៗ ដើម្បីកែតម្រូវ និងបំពេញនូវរាល់ ចន្លោះខ្វះខាតដែល មានតាំងពីថ្ងៃចាប់ផ្តើមសរសេររហូតដល់ថ្ងៃបញ្ចប់សារណានេះផងដែរ ។ គុណបំណាច់ ដ៏ធំធេងទាំងនេះ យើងខ្ញុំ ទាំងពីរនាក់ ពុំមានថ្ងៃបំភ្លេចបានឡើយ ហើយចងចាំទុក និង ដឹងគុណលោកសាស្ត្រាចារ្យជារៀងរហូតទៅ។ ក្នុងឱកាសដ៏មានតម្លៃនេះ យើងខ្ញុំទាំងពីរនាក់ សូមបួងសួងអស់វត្ថុស័ក្តិសិទ្ធិ ដែលមានក្នុងលោក សូមជួយថែរក្សាលោកសាស្ត្រាចារ្យឱ្យមានសុខភាពល្អ ដើម្បីឱ្យលោកបានបន្តបង្ហាត់បង្រៀនដល់និស្សិតជំនាន់ក្រោយៗទៀត ។

ដោយសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ និងដឹងគុណយ៉ាងជ្រាលជ្រៅបំផុតអំពីយើងខ្ញុំទាំងពីរនាក់ ។

# អារម្ភកថា

ក្នុងនាមយើងខ្ញុំជានិស្សិតផ្នែកច្បាប់ នៃសាកវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច មានសេចក្តីសោមនស្ស រីករាយយ៉ាងក្រៃលែង ដែលមានឱកាសបានសរសេរសារណាបញ្ចប់ការសិក្សា ក្រោយពីបានសិក្សាអស់រយៈពេល៤ឆ្នាំកន្លងមកនេះ ហើយយើងខ្ញុំបានជ្រើសយកនូវប្រធានបទស្តីពី **អំពើសញ្ចារកម្ម** មកធ្វើការតាក់តែងឡើង។ ការជ្រើសរើសយកប្រធានបទនេះនៅក្នុងគោលបំណង ដើម្បីសិក្សាស្វែងយល់ឱ្យកាន់តែច្បាស់ថា តើអ្វីទៅជាអំពើសញ្ចារកម្ម ហើយសកម្មភាពបែបណាខ្លះដែលចាត់ទុក ឬ មិនត្រូវបាន ចាត់ទុកថា ជាអំពើសញ្ចារកម្ម? ម៉្យាងវិញទៀតដោយយល់ឃើញថាអំពើសញ្ចារកម្មនេះ បានធ្វើឱ្យប៉ះពាល់ទៅដល់សណ្តាប់ធ្នាប់សង្គមយ៉ាងខ្លាំង មិនត្រឹមតែប៉ុណ្ណោះទេថែមទាំង បានធ្វើឱ្យប៉ះពាល់ទៅដល់សេចក្តីថ្លៃថ្នូរ របស់មនុស្សជាតិទៀតផង ជាពិសេស ស្ត្រី និង កុមារ ដែលជាហេតុនាំឱ្យ ទំនៀមទម្លាប់ ប្រពៃណីរបស់ជាតិយើងដែលល្អផូរផង់ ត្រូវបានធ្លាក់ចុះ និង អាប់អោន ដោយសារតែសកម្មភាពនៃអំពើទាំងនេះកើតមានឡើងនៅក្នុងសង្គម ។

នៅក្នុងអត្ថបទស្រាវជាវមួយនេះដែរ យើងខ្ញុំទាំងពីរនាក់បានចំណាយពេលវេលាយ៉ាងច្រើននៅក្នុងការស្វែងរកឯកសារពាក់ព័ន្ធផ្សេងៗ ដែលមានស្រាប់ នៅតាមបណ្ណាល័យ ដូចជា ឯកសារច្បាប់ ឯកសារមេរៀន និងធ្វើការស្រាវជ្រាវតាមប្រព័ន្ធ អ៊ីនធឺណេត ឬ គេហៈទំព័រផ្សេងៗ ដើម្បីប្រមូលបានជាទិន្នន័យក្នុងការចងក្រងជាសៀវភៅសារណានេះឡើង។ យើងខ្ញុំសង្ឃឹមថា សារណាមួយនេះ នឹងជាគុណប្រយោជន៍មួយចំណែកតូច ដើម្បីជាជំនួយដល់ការសិក្សាស្រាវជ្រាវបន្ថែមទៀតសំរាប់និស្សិតជំនាន់ក្រោយៗ ដែលមានបំណងចង់ស្វែងយល់អំពីបទល្មើសនេះឱ្យកាន់តែស៊ីជម្រៅឡើង ។

យ៉ាងណាមិញ ខ្ញុំជឿជាក់ថា សារណាមួយនេះនៅមានចំណុចខ្វះខាត នៅឡើយ ដែលកើតមានឡើង ដោយអចេតនា តាមរយៈកំហុសអក្ខរាវិរុទ្ធ ការប្រើប្រាស់ពាក្យពេចន៍មិនសមរម្យក៏ដូចជាកង្វះខាតផ្នែកអត្ថន័យក្តី ហេតុនេះហើយប្រសិនបើមានចំណុចខ្វះខាតត្រង់ចំណុចណាមួយ យើងខ្ញុំក៏សូមខន្តី អភ័យទោស រាល់ចំណុចខ្វះខាតទាំងនោះ និង រីករាយចំពោះការរិះគន់ទាំងឡាយ នៅក្នុងគោលបំណងដើម្បីស្ថាបនា ឱ្យកាន់តែមានភាពល្អប្រសើរឡើង ហើយក៏រង់ចាំទទួលរាល់ការកែលម្អឡើងវិញពីសំណាក់សាស្ត្រាចារ្យ សិស្ស និស្សិត មិត្តអ្នកអាន ដោយក្តីសោមនស្សរីករាយផងដែរ។

# មាតិកា

ទំព័រ

**សេចក្ដីផ្ដើម** ..................................................................... **១**

## ជំពូកទី ១

## សញ្ញាណទូទៅនៃអំពើសញ្ជារកម្ម

**ផ្នែកទី ១៖ ប្រវត្តិ** ..................................................................... **៦**

កថាខណ្ឌទី ១៖ សម័យសង្គមរាស្ត្រនិយម ..................................................................... **៧**

១. ច្បាប់ព្រហ្មទណ្ឌខ្មែរដែលនៅសេសសល់ពីសម័យអាណានិគមនិយមបារាំង ..................................................................... **៧**

២. ច្បាប់ព្រហ្មទណ្ឌខ្មែរសម័យសង្គមរាស្ត្រនិយម ..................................................................... **៨**

កថាខណ្ឌទី ២៖ សម័យសាធារណៈរដ្ឋខ្មែរ ដល់ រដ្ឋកម្ពុជា ..................................................................... **៨**

១. សម័យសាធារណៈរដ្ឋខ្មែរ ..................................................................... **៨**

២. សម័យកម្ពុជាប្រជាធិបតេយ្យ ..................................................................... **៨**

៣. សម័យសាធារណៈរដ្ឋប្រជាមានិតកម្ពុជា និង រដ្ឋកម្ពុជា ..................................................................... **៨**

កថាខណ្ឌទី ៣៖ សម័យព្រះរាជាណាចក្រកម្ពុជាទី ២ ..................................................................... **៨**

១. ការរៀបចំឡើងវិញនូវប្រព័ន្ធគតិយុត្តិខ្មែរ ..................................................................... **៨**

២. លិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធនឹងការបង្ក្រាបអំពើជួញដូរមនុស្ស ..................................................................... **៩**

**ផ្នែកទី ២៖ លក្ខណៈនៃអំពើសញ្ជារកម្ម** ..................................................................... **១០**

កថាខណ្ឌទី ១៖ ទម្រង់នៃអំពើសញ្ជារកម្ម ..................................................................... **១០**

១. ការទាញយកអត្ថប្រយោជន៍ហិរញ្ញវត្ថុពីអំពើពេស្យាចាររបស់ជនដទៃ ..................................................................... **១០**

២. ជួយ ឬ ការពារអំពើពេស្យាចាររបស់ជនដទៃ ..................................................................... **១១**

៣. ជ្រើសរើស អូសទាញ ឬ បណ្ដុះបណ្ដាលបុគ្គលណាមួយឱ្យធ្វើអំពើពេស្យាចារ ..................................................................... **១២**

៤. ធ្វើការគាបសង្កត់លើបុគ្គលណាមួយ ដើម្បីឱ្យបុគ្គលនោះធ្វើពេស្យាចារ ..................................................................... **១៣**

កថាខណ្ឌទី ២៖ អំពើដែលត្រូវបានចាត់ទុកដូចគ្នាទៅនឹងអំពើសញ្ជារកម្ម........................**១៣**
១. អំពើធ្វើជាអន្តរការី រវាងបុគ្គលដែលធ្វើពេស្យាចារ និង បុគ្គលដែលប្រកបអាជីវកម្ម ឬ ឱ្យលាភការដល់ពេស្យាចារជនដទៃ..........................................................................................**១៣**
២. អំពើរបស់ជនណាដែលបានសម្រួល ឬ បិទបាំង នូវធនធានដែលខ្លួនបានដឹងថាបានមកពីអំពើសញ្ជារកម្ម ..........................................................................................**១៤**
៣. អំពើរារាំងដល់ការបង្ការ ការជួយ ឬ ការអប់រំជាថ្មី ដោយទីភ្នាក់ងារសាធារណៈ ឬ ដោយអង្គការឯកជន ដែលមាននីតិសម្បទា ដែលធ្វើឡើង ដើម្បីជាគុណប្រយោជន៍ ដល់បុគ្គលដែលប្រព្រឹត្តពេស្យាចារ ឬ កំពុងមានគ្រោះដោយការធ្វើពេស្យាចារ .........................**១៥**
កថាខណ្ឌទី ៣៖ សកម្មភាពដែលមិនត្រូវបានចាត់ទុកដូចគ្នាទៅនឹងអំពើសញ្ជារកម្ម..........**១៦**
១. ការប្រព្រឹត្តអំពើពេស្យាចារដោយខ្លួនឯង ..........................................................**១៦**
២. ការគ្មានបំណងលក់ ឬ ផ្តល់ទីកន្លែងឱ្យមេបនប្រកបអាជីវកម្មពេស្យាចារ .................**១៨**
៣. ការបម្រើការងារជាបុគ្គលិកឱ្យគ្រឹះស្ថានពេស្យាចារ ដោយមិនមានចេតនាធ្វើឱ្យមានការរីកចម្រើនដល់អាជីវកម្មពេស្យាចារ..........................................................................**១៩**

## ជំពូកទី ២

## សញ្ញាណគតិយុត្តនៃអំពើសញ្ជារកម្ម

**ផ្នែកទី ១៖ ធាតុផ្សំ នៃបទល្មើសសញ្ជារកម្ម ............................................................២២**
កថាខណ្ឌទី ១៖ ធាតុនីត្យានុកូល ..........................................................................**២២**
១. និយមន័យ ......................................................................................**២២**
២. អត្ថបទច្បាប់.......................................................................................**២២**
កថាខណ្ឌទី ២៖ ធាតុសត្យានុម័ត ..........................................................................**២៣**
១. និយមន័យ ......................................................................................**២៣**
២. សកម្មភាពប្រព្រឹត្ត..............................................................................**២៣**
កថាខណ្ឌទី ៣៖ ធាតុអន្តោម័ត ............................................................................**២៣**
១. និយមន័យ ......................................................................................**២៣**
២. ចេតនាប្រព្រឹត្ត ................................................................................ **២៤**

កថាខណ្ឌទី ៤៖ ការផ្តន្ទាទោសចំពោះអំពើសញ្ចារកម្ម.................................................. ២៤
១. ការផ្តន្ទាទោសទៅលើជនប្រព្រឹត្តសញ្ចារកម្ម.................................................. ២៤
១.១ ស្ថានទម្ងន់ទោសនៃអំពើសញ្ចារកម្ម.................................................. ២៥
១.១.១. មេពេស្យាជាបុព្វញាតិ ឬ បច្ឆាញាតិរបស់បុគ្គលដែលធ្វើពេស្យាចារ.......... ២៦
១.១.២. មេពេស្យា រំលោភអំណាច ដែលមុខងាររបស់ខ្លួន ផ្តល់ឱ្យទៅលើបុគ្គល ដែលធ្វើពេស្យាចារ .................................................. ២៧
១.១.៣. មេពេស្យាប្រើហិង្សា ឬ ការបង្ខិតបង្ខំ ចំពោះបុគ្គលដែលធ្វើពេស្យាចារ ..... ២៨
១.១.៤. កាលបើសញ្ចារកម្មត្រូវបានប្រព្រឹត្តជាក្រុមមានការចាត់តាំង.................. ២៩
១.១.៥. កាលបើសញ្ចារកម្មត្រូវបានប្រព្រឹត្តលើបុគ្គលច្រើននាក់ធ្វើពេស្យាចារ........ ៣០
១.២. សញ្ចារកម្មទាក់ទងនឹងពេស្យាចារកុមារ.................................................. ៣០
១.២.១. និយមន័យ .................................................. ៣១
១.២.២. ការកំណត់អំពីទោស .................................................. ៣១
១.៣. សញ្ចារកម្មដោយមានការធ្វើទារុណកម្ម.................................................. ៣១
១.៣.១. និយមន័យ.................................................. ៣២
១.៣.២. ធាតុផ្សំនៃការធ្វើទារុណកម្ម .................................................. ៣២
១.៣.៣. ការកំណត់អំពីទោស .................................................. ៣២
**ផ្នែកទី ២៖ ការផ្តន្ទាទោសទៅលើ ជនដែលដឹកនាំពេស្យាចារ ដឹកនាំគ្រឹះស្ថាន និង ផ្តល់ទីកន្លែងសម្រាប់ធ្វើពេស្យាចារ.................................................. ៣៣**
កថាខណ្ឌទី ១៖ ការដឹកនាំពេស្យាចារ .................................................. ៣៣
១. ការដឹកនាំ .................................................. ៣៣
២. ការធ្វើអាជីវកម្ម .................................................. ៣៣
៣. ការប្រតិបត្តិការ.................................................. ៣៤
៤. ការចេញប្រាក់ .................................................. ៣៤
៥. គ្រឹះស្ថានពេស្យាចារ .................................................. ៣៤
កថាខណ្ឌទី ២៖ ការដឹកនាំគ្រឹះស្ថានពេស្យាចារ .................................................. ៣៥
១. ការឱ្យបុគ្គលណាម្នាក់ប្រព្រឹត្តពេស្យាចារនៅក្នុងគ្រឹះស្ថាន.................................................. ៣៥

២. ការឱ្យបុគ្គលណាម្នាក់រកភ្ញៀវដើម្បីធ្វើពេស្យាចារនៅក្នុងគ្រឹះស្ថាន ....... ៣៦
កថាខណ្ឌទី ៣៖ ការផ្តល់ទីកន្លែងសម្រាប់ធ្វើពេស្យាចារ ....... ៣៦
១. ការលក់ ....... ៣៦
២. ការជួល ....... ៣៧

## ជំពូកទី ៣

## ស្ថានភាពសង្គមដែលនាំឱ្យមានអំពើសញ្ចារកម្ម

**ផ្នែកទី ១៖ កត្តាសង្គម** ....... ៣៩
កថាខណ្ឌទី ១៖ សេដ្ឋកិច្ច ....... ៣៩
កថាខណ្ឌទី ២៖ ការអប់រំ ....... ៤០
កថាខណ្ឌទី ៣៖ សីលធម៌ ....... ៤០
កថាខណ្ឌទី ៤៖ ការសេពគ្រឿងញៀន ....... ៤០
កថាខណ្ឌទី ៥៖ ទេសចរណ៍ ....... ៤១
កថាខណ្ឌទី ៦៖ វប្បធម៌បរទេស ....... ៤១
កថាខណ្ឌទី ៧៖ បញ្ហាជនអន្តោប្រវេសន៍ខុសច្បាប់ ....... ៤១
**ផ្នែកទី ២៖ កត្តាគ្រួសារ** ....... ៤២
កថាខណ្ឌទី ១៖ បញ្ហាសេដ្ឋកិច្ចគ្រួសារ ....... ៤២
កថាខណ្ឌទី ២៖ ការជំពាក់បំណុល ....... ៤២
កថាខណ្ឌទី ៣៖ អំពើហិង្សាក្នុងគ្រួសារ ....... ៤៣
កថាខណ្ឌទី ៤៖ ខ្វះភាពកក់ក្តៅក្នុងគ្រួសារ ....... ៤៣
កថាខណ្ឌទី ៥៖ ការបោះបង់ចោលគ្រួសារ ....... ៤៤
កថាខណ្ឌទី ៦៖ ការយល់ដឹងនូវមានកម្រិតទាប ....... ៤៤
កថាខណ្ឌទី ៧៖ វិសមភាពរវាងបុរស និងស្ត្រី ....... ៤៥
**ផ្នែកទី ៣៖ កត្តាបុគ្គលជនរងគ្រោះ** ....... ៤៥
កថាខណ្ឌទី ១៖ កើតវិបត្តិផ្លូវចិត្ត ....... ៤៥

កថាខណ្ឌទី ២៖ អនាថា........................................................................ ៤៦
កថាខណ្ឌទី ៣៖ ភ្លើតភ្លើន...................................................................... ៤៦
កថាខណ្ឌទី ៤៖ ភាពគ្មានការងារធ្វើ............................................................ ៤៦
កថាខណ្ឌទី ៥៖ ខូចចិត្តរឿងស្នេហា............................................................ ៤៦
កថាខណ្ឌទី ៦៖ ចាញ់បោកការអូសទាញ ...................................................... ៤៧
កថាខណ្ឌទី ៧៖ ត្រូវគេចាប់ពង្រាត់ ............................................................ ៤៧

**ផ្នែកទី ៤៖ ផលប៉ះពាល់នៃអំពើសញ្ជារកម្ម** ............................................. ៤៨

កថាខណ្ឌទី ១៖ ចំពោះមនុស្ស.................................................................. ៤៨
១. ប៉ះពាល់ដល់ផ្លូវកាយ និង ចិត្ត ................................................................ ៤៨
២. ប៉ះពាល់ដល់កិត្តិយសគ្រួសារ................................................................. ៤៨
៣. ឃ្លាតឆ្ងាយពីគ្រួសារ.............................................................................. ៤៨

កថាខណ្ឌទី ២៖ ចំពោះសង្គម.................................................................... ៤៩
១. បាត់បង់ប្រពៃណី.................................................................................. ៤៩
២. រារាំងដល់ការអភិវឌ្ឍន៍.......................................................................... ៤៩
៣. ភាពអនាធិបតេយ្យ ............................................................................... ៥០

## ជំពូកទី ៤

## យន្តការទប់ស្កាត់រាល់សកម្មភាពនៃអំពើសញ្ជារកម្ម

**ផ្នែកទី ១៖ ពង្រឹងការអនុវត្តន៍ច្បាប់ និងអនុវត្តគោលនយោបាយប្រឆាំងនិងអំពើជួញដូរមនុស្ស** ......................................................................................... ៥១

កថាខណ្ឌទី ១៖ ការអនុវត្តន៍ច្បាប់ឱ្យមានប្រសិទ្ធភាព ...................................... ៥១
កថាខណ្ឌទី ២៖ គោលនយោបាយរបស់រាជរដ្ឋាភិបាល ..................................... ៥២
កថាខណ្ឌទី ៣៖ បញ្ហាប្រឈមផ្សេងៗ.......................................................... ៥៣

**ផ្នែកទី ២៖ ស្ថាប័នជាតិគាំពារស្ត្រី និង ជនងាយរងគ្រោះ**.................................... ៥៤

កថាខណ្ឌទី ១៖ ក្រសួងកិច្ចការនារី.............................................................. ៥៤

កថាខណ្ឌទី ២៖ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ............................ ៥៦
កថាខណ្ឌទី ៣៖ ក្រសួងមហាផ្ទៃ ................................................................................ ៥៨
**ផ្នែកទី ៣៖ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស.......................... ៦១**
កថាខណ្ឌទី ១៖ សមាសភាព ..................................................................................... ៦១
កថាខណ្ឌទី ២៖ តួនាទី និងភារកិច្ច ........................................................................ ៦២
កថាខណ្ឌទី ៣៖ អំពីអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស........................................................................................................៦៣
**ផ្នែកទី ៤៖ ការផ្សព្វផ្សាយឱ្យបានទូលំទូលាយ និង អប់រំដល់ប្រជាពលរដ្ឋឱ្យយល់ដឹងពីអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ .................................. ៦៦**
កថាខណ្ឌទី ១៖ ការផ្សព្វផ្សាយជាសាធារណៈ.......................................................... ៦៦
កថាខណ្ឌទី ២៖ ការបណ្តុះបណ្តាលប្រជាពលរដ្ឋ.......................................................៦៧
កថាខណ្ឌទី ៣៖ ការចុះធ្វើសកម្មភាពអប់រំដោយផ្ទាល់នៅតាមតំបន់ជនបទ.....................៦៧
**សេចក្តីសន្និដ្ឋាន ....................................................................................... ៦៩**
**អនុសាសន៍**
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ព្រះរាជាណាចក្រកម្ពុជាយើង ត្រូវបានចាត់ទុកថាជា ប្រទេសមួយក្នុងចំណោមប្រទេសជាច្រើននៅលើពិភពលោក ដែលមានវប្បធម៌ និងអរិយធម៌ ដ៏ចំណាស់នៅក្នុងភូមិភាគអាស៊ីអាគ្នេយ៍យើងនេះ ។ ប្រទេសកម្ពុជា ជាដែនដីសុវណ្ណភូមិ ដែលសម្បូរទៅដោយធនធានមានតម្លៃយ៉ាងច្រើនឥតគណនា គួរជាទីមោទនៈសម្រាប់ប្រជាជនខ្មែរ ។ ម៉្យាងវិញទៀតខ្មែរយើងជាជាតិសាសន៍មួយដែលប្រកាន់ខ្ជាប់នូវប្រពៃណី ទំនៀមទម្លាប់ យ៉ាងល្អខ្ជាប់ខ្ជួនតាំងពីសម័យ បុរាណមក ហើយការប្រតិបត្តិយ៉ាងល្អបែបនេះបានបន្សល់ទុករហូតមកដល់កូនចៅខ្មែរជំនាន់ក្រោយយើងនេះ។ ជាទូទៅយើងសង្កេតឃើញថា ប្រជាជនខ្មែរយើងនៅតែបន្តអនុវត្តប្រពៃណី ទំនៀមទម្លាប់ពីបុរាណកាលនេះដដែល ប៉ុន្តែការអនុវត្តន៍មិនសូវជាបានខ្ជាប់ខ្ជួននោះទេ ដោយសារតែសម័យកាលមានការផ្លាស់ប្តូរទៅតាម បរិបទនៃសង្គម ហើយការវិវត្តន៍ចេះតែមានការប្រែប្រួលទៅមុខឥតឈប់ឈរ ហេតុនេះហើយធ្វើឱ្យមនុស្សមានការរីកចម្រើនទាំងផ្នែកបញ្ញា និង ស្មារតី ព្រមទាំងរួមផ្សំជាមួយនឹងកត្តាជាច្រើនដែលបានជះឥទ្ធិពលមកលើផ្នត់គំនិតរបស់ពួកគេផងដែរ ម៉្យាងវិញទៀតនៅពេលបច្ចុប្បន្ននេះឥទ្ធិពលនៃ វប្បធម៌បរទេសបានហូរចូលមកប្រទេសកម្ពុជាយ៉ាងសស្រាក់សស្រាំ ដោយនាំយកមកជាមួយនូវ ផលអវិជ្ជមានជាច្រើន មកសាបព្រួសលើចិត្តគំនិតរបស់កូនខ្មែរជំនាន់ក្រោយទៀតផង ។

លើសពីនេះទៅទៀត នៅក្នុងប្រទេសកម្ពុជាសព្វថ្ងៃបានប្រកាន់ខ្ជាប់នូវការឱ្យតម្លៃយ៉ាងខ្លាំងទៅលើសិទ្ធិមនុស្ស ដោយគាំពារមិនឱ្យមានការរំលោភបំពានសិទ្ធិមនុស្ស ការកេងប្រវ័ញ្ចលើកម្លាំងពលកម្ម និងប្រឆាំងដាច់ខាតរាល់ការធ្វើអាជីវកម្មទាំងឡាយណា ដែលនាំឱ្យបាត់បង់សេចក្តីថ្លៃថ្នូររបស់មនុស្ស និងរបៀបរៀបរយសាធារណៈ នៅក្នុងនោះរួមមាន រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣ ដែលជាច្បាប់កំពូលរបស់រដ្ឋ បានការពារនូវសិទ្ធិសេរីភាពរបស់ប្រជាជនកម្ពុជាដោយមិនមានការប្រកាន់ពូជសាសន៍ពណ៌សម្បុរ ភេទ ភាសា សាសនា ឬ និន្នាការនយោបាយអ្វីឡើយ ហើយថែមទាំងបានផ្តល់សិទ្ធិស្មើគ្នាចំពោះមុខច្បាប់ទៀតផង។ ក្រៅពីនេះ រដ្ឋធម្មនុញ្ញបានចែងហាមឃាត់រាល់អំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទដែលនាំឱ្យបាត់បង់តម្លៃរបស់មនុស្ស ជាពិសេស ស្ត្រី និង កុមារ។ ជាទូទៅនៅតាមបណ្តាប្រទេសលើពិភពលោកតែងតែឱ្យតម្លៃយ៉ាងខ្លាំងទៅលើស្ត្រី និង កុមារ ជានិច្ច។ ម្យ៉ាងវិញទៀតដើម្បីការពារ មិនឱ្យមានការរំលោភលើសិទ្ធិរបស់ ស្ត្រី និងកុមារ ឬ សកម្មភាពដែលជាបទល្មើស ដែលប្រឆាំង នឹងមនុស្ស ទើបតម្រូវឱ្យប្រទេសកម្ពុជា បង្កើតនូវក្រមព្រហ្មទណ្ឌ និងច្បាប់ស្តីពីការបង្ក្រាប អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទឡើង ដើម្បីធ្វើការផ្តន្ទាទោសទៅលើជនដែលប្រព្រឹត្តសកម្មភាពល្មើសច្បាប់។

ជាទូទៅចំពោះការប្រកបអាជីវកម្មផ្លូវភេទ ត្រូវបានច្បាប់ហាមឃាត់ មិនឱ្យកើតមានឡើយ ដោយសារតែអាជីវកម្មបែបនេះ បានធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់សេចក្ដីថ្លៃថ្នូររបស់មនុស្ស និង សីលធម៌ ប្រពៃណី ទំនៀមទម្លាប់ដ៏ល្អរបស់ជាតិត្រូវធ្លាក់ចុះផងដែរ។ ហេតុដូច្នេះហើយការលើក យកប្រធានបទ ស្ដីអំពី **អំពើសញ្ចារកម្ម** មកធ្វើការសិក្សាឡើង គឺផ្អែកទៅលើមូលដ្ឋានច្បាប់ដែល មាននៅក្នុងព្រះរាជាណាចក្រកម្ពុជាយើង និងបទដ្ឋានអន្តរជាតិ ទាំងឡាយដែលឆ្លុះបញ្ចាំងពី ទិដ្ឋភាពនៃការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

តាមរយៈការលើកយកប្រធានបទ អំពើសញ្ចារកម្ម មកធ្វើការស្រាវជ្រាវ និងពិភាក្សាវែក ញែក គឺដើម្បីចង់បង្ហាញពីរូបភាពជាច្រើនផ្សេងៗគ្នានៃអំពើសញ្ចារកម្ម ហើយព្រមទាំងសិក្សាទៅ លើ បរិបទនៃសង្គម និង ស្ថានភាពជាក់ស្ដែងទាំងឡាយ ដែលនាំឱ្យកើតមានសញ្ចារកម្មនៅក្នុង សង្គមនាពេលបច្ចុប្បន្ននេះ។ អាស្រ័យហេតុដូច្នេះហើយ អត្ថបទស្រាវជ្រាវមួយនេះ នឹងបង្ហាញពី ចម្លើយជាច្រើននៃសំណួរ ដែលបាន ចោទឡើងដូចខាងក្រោមនេះ៖

តើអំពើសញ្ចារកម្ម ដែលកើតមានឡើងនៅក្នុងប្រទេសកម្ពុជាយើង ស្ដែងចេញក្រោមទម្រង់ បែបណាខ្លះ? ហើយជនដែលប្រព្រឹត្តអំពើសញ្ចារកម្មនេះ ត្រូវបានទទួល ការផ្ដន្ទាទោសដោយ របៀបណា?

តើមូលហេតុអ្វីខ្លះដែលនាំឱ្យកើតមានអំពើសញ្ចារកម្មនៅក្នុងសង្គម? ហើយផ្ដល់ផលវិបាក ដូចម្ដេចខ្លះ?

តើយន្តការអ្វីខ្លះដែលអាចទប់ស្កាត់នូវរាល់អំពើសញ្ចារកម្មដែលកើតមាននៅក្នុងសង្គម?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការលើកយកប្រធានបទអំពើសញ្ចារកម្មមកធ្វើការសិក្សាស្រាវជ្រាវ ក្នុងគោលបំណងដើម្បី៖

- បង្ហាញអំពីស្ថានភាពទូទៅនៅក្នុងសង្គម ដែលនាំឱ្យកើតមានឡើងនូវការធ្វើអាជីវកម្មផ្លូវភេទ ឬ ការប្រព្រឹត្តអំពើកេងប្រវ័ញ្ចយកផលប្រយោជន៍ ពីសកម្មភាពនៃអំពើពេស្យាចារ។
- ឆ្លុះបញ្ចាំងពីការប្រព្រឹត្តទៅ នៃសកម្មភាពរបស់ជនខិលខូច ដែលតែងតែបង្កឱ្យមាន អំពើល្មើស ប្រឆាំងទៅនឹងសេចក្ដីថ្លៃថ្នូររបស់មនុស្សជាតិ។
- វិភាគអំពីបទល្មើស ព្រហ្មទណ្ឌដែលច្បាប់បានកំណត់ និង ធ្វើការវែកញែកខ្លះៗ រវាងច្បាប់ព្រហ្មទណ្ឌទូទៅ និងច្បាប់ព្រហ្មទណ្ឌដែលមានលក្ខណៈពិសេស។
- ចង្អុលបង្ហាញអំពីគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការ ទប់ស្កាត់ និងធ្វើការ បង្ក្រាបរាល់អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

– ផ្តល់អនុសាសន៍មួយចំនួន ដើម្បីធ្វើការប្រយុទ្ធប្រឆាំងទៅ នឹងអំពើធ្វើអាជីវកម្មផ្នែកពេស្យាចារ។

– បង្ហាញពីទស្សនៈវិស័យផ្សេងៗ ក្នុងការចូលរួមលើកស្ទួយសិទ្ធិមនុស្ស នៅកម្ពុជាឱ្យកាន់តែប្រសើរឡើង។

## ៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

តាមរយៈការសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះ គឺផ្តោតសំខាន់ទៅលើអំពើទាំងឡាយដែលពាក់ព័ន្ធនឹង ការកេងចំណេញ នូវផលប្រយោជន៍ហិរញ្ញវត្ថុ ពីសកម្មភាពនៃអំពើពេស្យាចាររបស់ជនដទៃ និង បទដ្ឋានគតិយុត្តពាក់ព័ន្ធដែលមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា មកធ្វើការបង្ហាញដើម្បីឱ្យមានភាពសមស្រប ទៅនឹងស្ថានភាពសង្គមនាពេលបច្ចុប្បន្ននេះ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ដោយយល់ឃើញថា ប្រធានបទនេះពិតជាមានសារៈសំខាន់ណាស់ ចំពោះមនុស្ស និងសង្គមជាតិទាំងមូល ពីព្រោះថាអំពើសញ្ចារកម្ម ជាអំពើដែលធ្វើឱ្យសីលធម៌ វប្បធម៌ ប្រពៃណីដ៏ល្អរបស់ជាតិ ត្រូវអាប់អោន និងនាំឱ្យសេចក្តីថ្លៃថ្នូររបស់មនុស្សត្រូវបាត់បង់ថែមទៀត។ ម្យ៉ាងវិញទៀត អំពើសញ្ចារកម្ម ឆ្លុះបញ្ចាំងឱ្យឃើញពីសកម្មភាពរបស់ជនខិលខូចមួយចំនួនដែលតែងតែប្រើគ្រប់កលល្បិច ដោយធ្វើយ៉ាងណាឱ្យតែខ្លួនទទួលបានផលប្រយោជន៍ពីគេ (បុគ្គលពេស្យា) ទោះដោយបង្ខិតបង្ខំ ឬ ដោយមានការព្រមព្រៀងទៅវិញទៅមកក៏ដោយ។

លើសពីនេះទៅទៀត សារៈសំខាន់នៃការស្រាវជ្រាវ ក៏បានបង្ហាញពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល ក្នុងការជម្រុញឱ្យមានការប្រឆាំងទៅលើករណីដែលនាំឱ្យមានការធ្វើអាជីវកម្មផ្នែកពេស្យាចារ និងមានកិច្ចសហការជាមួយស្ថាប័នជាតិ អង្គការមិនមែនរដ្ឋាភិបាល និងសមាគមន៍ផ្សេងៗ ដែលមាននីតិសម្បទា ក្នុងការការពារសិទ្ធិមនុស្សនៅកម្ពុជា ហើយព្រមទាំងធ្វើការសហការជាមួយបណ្តាប្រទេសនៅជិតខាង និងប្រទេសជាច្រើននៅលើសកលលោក ដើម្បីទប់ស្កាត់នូវ បទល្មើសជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្នែកពេស្យាចារ។ ម្យ៉ាងវិញទៀតការលើកយកប្រធានបទនេះឡើងដើម្បី ជាប្រយោជន៍សម្រាប់អ្នកសិក្សាស្រាវជ្រាវ និងសម្រាប់ជនទូទៅដែលមាន បំណងស្វែងយល់ពីអំពើសញ្ចារកម្ម។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ការចងក្រង និងតាក់តែងចេញជាសារណាមួយនេះគឺផ្អែកទៅលើវិធីសាស្ត្រដូចខាងក្រោម ៖

– ការស្រាវជ្រាវឯកសារច្បាប់ សៀវភៅ របាយការណ៍ និង កម្រងឯកសារផ្សេងៗដែលពាក់ព័ន្ធ នៅតាមបណ្ណាល័យ និង បណ្ណាគារលក់សៀវភៅ ។

– ការប្រមូលទិន្នន័យពីពត៌មាន សន្តិសុខ និងសង្គម តាមរយៈបណ្តាញ អ៊ីនធឺណែត គេហៈទំព័រផ្សេងៗ និងតាមបណ្តាញសង្គម ។

– ការចុះទៅទស្សនានៅតាមទីតាំងដែលធ្លាប់បានកើតមាន អំពើពេស្យាចារ (តំបន់ស្វាយមានជ័យ ត្រឡោកបែក តាមមាត់ទន្លេ វត្តភ្នំ ) ដើម្បីពិនិត្យមើលពីស្ថានភាពនៃអំពើពេស្យាចារក្រោយពេលដែលសមត្ថកិច្ច បានចុះបង្ក្រាបរួចរាល់កាលពីពេលកន្លងទៅ ។

– ធ្វើការ ប្រាស្រ័យទាក់ទងជាមួយនឹង លោកគ្រូទទួលបន្ទុកណែនាំសរសេរសារណា ដើម្បីពិគ្រោះយោបល់អំពីការតាក់តែង និងស្វែងរកប្រភពឯកសារ ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

អត្ថបទស្រាវជ្រាវមួយនេះត្រូវបានរៀបចំជារចនាសម្ព័ន្ធដូចខាងក្រោមៈ

សេចក្តីផ្តើម

ជំពូកទី ១៖ សញ្ញាណទូទៅនៃអំពើសញ្ចារកម្ម

ជំពូកទី ២៖ សញ្ញាណគតិយុត្តនៃអំពើសញ្ចារកម្ម

ជំពូកទី ៣៖ ស្ថានភាពសង្គមដែលនាំឱ្យមានអំពើសញ្ចារកម្ម

ជំពូកទី ៤៖ យន្តការទប់ស្កាត់រាល់សកម្មភាពនៃអំពើសញ្ចារកម្ម

សេចក្តីសន្និដ្ឋាន

អនុសាសន៍

ឯកសារយោង

ឧបសម្ព័ន្ធ

# ជំពូកទី ១

# សញ្ញាណទូទៅនៃអំពើសញ្ចារកម្ម

ជាដំបូង ដើម្បីធ្វើការសិក្សាស្វែងយល់នូវខ្លឹមសារនៃ អំពើសញ្ចារកម្ម ឱ្យកាន់តែស៊ីជម្រៅ យើងគួរគប្បីដឹងនូវសញ្ញាណខ្លះៗជាមុនសិន ពីព្រោះថា សញ្ញាណទូទៅទាំងនេះហើយ នឹងនាំឱ្យយើងយល់ច្បាស់ ថាអ្វីទៅជាអំពើសញ្ចារកម្ម?

**អំពើសញ្ចារកម្ម** គឺជាការធ្វើអាជីវកម្មលើអំពើពេស្យាចាររបស់ជនដទៃ។ មានន័យថា ជាសកម្មភាព នៃមុខរបររកស៊ីជួញដូរផ្លូវភេទ របស់អ្នកប្រព្រឹត្ត សញ្ចារកម្ម ដែលច្បាប់ចាត់ទុកថាជាសញ្ចារិក ឬ សញ្ចារិកា។ ការបើកអាជីវកម្មបែបនេះកើតមានច្រើនណាស់នៅក្នុងសង្គម ជាពិសេសដើម្បីផ្តល់សេវាកម្មបម្រើផ្លូវភេទ ដល់អតិថិជនទូទៅដើម្បីបំពេញនូវកាមតណ្ហាតាមរយៈការរួមភេទ និងសម្រាប់បម្រើឱ្យការសប្បាយខាងចំណង់ផ្លូវភេទជាដើម។ ការធ្វើអាជីវកម្មបែបនេះជាមុខរបរមួយដែលធ្វើឱ្យសីលធម៌សង្គមត្រូវធ្លាក់ចុះ និងមិនត្រូវបានសង្គមឱ្យតម្លៃនោះទេ ពីព្រោះថាការរួមភេទអាវ៉ាសែបែបនេះ មិនមែនជាប្រពៃណីដ៏ល្អឡើយ ហើយថែមទាំងនាំឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សទៀតផង។ ដោយយល់ឃើញដូច្នេះហើយ ទើបរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣ បានចែងនៅក្នុងមាត្រា ៤៦ ដោយមានខ្លឹមសារថា៖ *អំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្នែកពេស្យាកម្ម និងអំពើអាសអាភាសដែលប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់នារី ត្រូវហាមឃាត់។*

**អំពើសញ្ចារកម្ម** នៅក្នុងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ ២០០៨ មានន័យថា គឺជា:

- ការទាញយកអត្ថប្រយោជន៍ហិរញ្ញវត្ថុពីអំពើពេស្យាចាររបស់ជនដទៃ
- ជួយ ឬការពារអំពើពេស្យាចាររបស់ជនដទៃ
- ជ្រើសរើស អូសទាញ ឬ បណ្តុះបណ្តាលបុគ្គលណាមួយឱ្យធ្វើអំពើពេស្យាចារ
- ធ្វើការគាបសង្កត់លើបុគ្គលណាមួយ ដើម្បីឱ្យបុគ្គលនោះធ្វើពេស្យាចារ

**អំពើដូចខាងក្រោមនេះត្រូវចាត់ទុកដូចគ្នាទៅនឹង អំពើសញ្ចារកម្ម:**

– អំពើធ្វើជាអន្តរការី រវាងបុគ្គលដែលធ្វើពេស្យាចារ និង បុគ្គលដែលប្រកបអាជីវកម្ម ឬ ឱ្យលាភការដល់ពេស្យាចារជនដទៃ

– អំពើរបស់ជនណាដែលបានសម្រួល ឬ បិទបាំង នូវធនធានដែលខ្លួនបានដឹងថាបានមកពីអំពើសញ្ចារកម្ម

– អំពើរារាំងដល់ការបង្ការ ការជួយ ឬ ការអប់រំជាថ្មីដោយទីភ្នាក់ងារសាធារណៈ ឬ ដោយអង្គការឯកជនដែលមាននីតិសម្បទា ដែលធ្វើឡើងដើម្បីជាគុណប្រយោជន៍ដល់បុគ្គល ដែលប្រព្រឹត្តពេស្យាចារ ឬ កំពុងមានគ្រោះដោយការធ្វើពេស្យាចារ[1]។

ចំណែកឯនៅក្នុង មាត្រា ២៨៩ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ វិញក៏បានធ្វើការកំណត់និយមន័យប្រហាក់ប្រហែលគ្នាទៅនឹង ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ ២០០៨ ផងដែរ។ ប៉ុន្តែយើងសង្កេតឃើញថា នៅក្នុងក្រមព្រហ្មទណ្ឌបានបន្ថែមនូវទោសពិន័យជាប្រាក់ ហេតុនេះហើយប្រសិនបើមានករណីសញ្ចារកម្មកើតឡើង តើគេត្រូវយកច្បាប់មួយណាមកអនុវត្ត? ត្រង់ចំណុចនេះហើយយើងអាចនិយាយបានថា ប្រសិនបើសញ្ចារកម្មស្ថិតនៅក្នុងបរិបទនៃបទល្មើសជួញដូរមនុស្ស គេត្រូវយកច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទមកធ្វើការអនុវត្តន៍ ព្រោះថាច្បាប់ពិសេសមានអទិភាពជាងច្បាប់ទូទៅ។ អាស្រ័យហេតុនេះហើយទើបអត្ថបទស្រាវជ្រាវ របស់យើងខ្ញុំធ្វើការលើកយកនូវ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទដែលជាច្បាប់ពិសេសនេះឡើង មកពិភាក្សាវែកញែក និងពន្យល់។

ក្រោយពីបានយល់ច្បាស់អំពីនិយមន័យ នៃអំពើសញ្ចារកម្មរួចមក យើងនឹងធ្វើការសិក្សាជាបន្តទៅលើ ប្រវត្តិទូទៅនៃលិខិតបទដ្ឋានគតិយុត្តខ្មែរ ដែលមានតាំងពីសង្គមចាស់ រហូតមកដល់សម័យបច្ចុប្បន្ន (ផ្នែកទី១) ហើយព្រមទាំងធ្វើការលើកឡើងអំពីលក្ខណៈទូទៅនៃអំពើសញ្ចារកម្ម (ផ្នែកទី២) យកមកធ្វើការបកស្រាយដែលមានខ្លឹមសារដូចខាងក្រោម:

## ផ្នែកទី ១៖ ប្រវត្តិ

### កថាខណ្ឌទី ១៖ សម័យសង្គមរាស្ត្រនិយម

#### ១. ច្បាប់ព្រហ្មទណ្ឌខ្មែរដែលនៅសេសសល់ពីសម័យអាណានិគមនិយមបារាំង

ក្រោយពីទទួលបានឯករាជ្យ នៅថ្ងៃទី ៩ ខែ វិច្ឆិកា ឆ្នាំ ១៩៥៣ ប្រទេសកម្ពុជាបានផ្លាស់ប្តូរមុខមាត់សារជាថ្មីពីរបបអាណានិគមនិយមបារាំង ប្រែក្លាយជា ព្រះរាជាណាចក្រកម្ពុជាទី១ (សម័យសង្គមរាស្ត្រនិយម) ដែលត្រូវបានដឹកនាំដោយ ព្រះករុណា ព្រះបាទនរោត្តម សីហនុ។ នៅក្នុងសម័យនោះច្បាប់ព្រហ្មទណ្ឌដែលនៅសេសសល់ពីសម័យអាណានិគម មានដូចជា ក្រមព្រហ្មទណ្ឌខេមរៈ ដែលជាក្រមព្រហ្មទណ្ឌលើកដំបូងបំផុតរបស់ខ្មែរយើង ហើយក្រមនេះត្រូវបានប្រកាសឱ្យប្រើកាលពីថ្ងៃទី ៨ ខែ មេសា ឆ្នាំ ១៩០៩ ដោយព្រះមហាក្សត្រ។ យើងសង្កេតឃើញថាក្រមព្រហ្មទណ្ឌខ្មែរសម័យបារាំងគ្រប់គ្រងនេះ មានតែ ២៩៨ មាត្រាប៉ុណ្ណោះសម្រាប់ធ្វើការអនុវត្តន៍។

[1] មាត្រា ២៥ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទឆ្នាំ ២០០៨

**២. ច្បាប់ព្រហ្មទណ្ឌខ្មែរសម័យសង្គមរាស្ត្រនិយម**

បន្ទាប់ពីប្រទេសកម្ពុជា ទទួលបានឯករាជ្យពេញលេញមក សម័យសង្គមរាស្ត្រនិយម ក៏បានចាប់បដិសន្ធិឡើង ដែលយើងតែងតែហៅថា ព្រះរាជាណាចក្រកម្ពុជាទី១ នៅក្នុងនោះដែរ គេឃើញមានការរៀបចំឡើងវិញនូវលិខិតបទដ្ឋានគតិយុត្តជាច្រើន ជាពិសេស ក្រមព្រហ្មទណ្ឌខ្មែរសម័យសង្គមរាស្ត្រនិយម ដែលត្រូវបានប្រកាស ឱ្យប្រើនៅថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ១៩៥៥ ដោយព្រះមហាក្សត្រ។ ក្រមព្រហ្មទណ្ឌនេះត្រូវបាន បោះពុម្ពឡើង នៅក្នុងឆ្នាំ ១៩៥៦ ដែលមានរហូតទៅដល់ ៥៥០ មាត្រា។

នៅក្នុងសម័យសង្គមរាស្ត្រនិយម បានហាមឃាត់មិនឱ្យមាន ការប្រកបអាជីវកម្មទាំងឡាយណា ដែលនាំឱ្យខូចសីលធម៌សង្គម ជាពិសេស ការជួញដូរមនុស្ស និង ការធ្វើអាជីវកម្មផ្លូវភេទ ឬ ការបើកផ្ទះបនជាដើម។ ហេតុនេះហើយរាល់បទប្បញ្ញត្តិដែលមានចែងក្នុង ក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦ ពាក់ព័ន្ធទៅនឹងអំពើពេស្យាចារ ត្រូវបានចាត់ទុកជាមោឃៈ ពីព្រោះថាអំពើទាំងនោះនាំឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស។ ម្យ៉ាងវិញទៀត ដើម្បីបំពេញបន្ថែមលើក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ពាក់ព័ន្ធនឹងអំពើពេស្យាចារដដែល ទើបត្រូវបានបង្កើតឱ្យមានច្បាប់ស្តីពីការបំបិទផ្ទះបនស្រីពេស្យា ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ៦០ ប.វ ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ១៩៦១។ ដូច្នេះហើយចាប់តាំងពីមាន ច្បាប់ស្តីពីការបំបិទផ្ទះបនស្រីពេស្យាមក រាល់ការធ្វើអាជីវកម្មពេស្យាចារ ការបើកផ្ទះបន ឬ ទីកន្លែងផ្សេងៗដែលនាំឱ្យមានសកម្មភាពពេស្យាចារកើតឡើង ត្រូវបានហាមឃាត់មិនឱ្យមានឡើយ។

**កថាខណ្ឌទី ២៖ សម័យសាធារណៈរដ្ឋខ្មែរ ដល់ រដ្ឋកម្ពុជា**

**១. សម័យសាធារណៈរដ្ឋខ្មែរ**

នៅក្នុងឆ្នាំ ១៩៧០ ប្រទេសកម្ពុជាបានផ្លាស់ប្តូររបបនយោបាយថ្មី ពីរបបរាជានិយម ទៅជាសាធារណរដ្ឋនិយមវិញ ដែលត្រូវបានបង្កើតឡើង ក្រោយរដ្ឋប្រហារ ថ្ងៃទី ១៨ មីនា ឆ្នាំ ១៩៧០។ នៅក្នុងសម័យសាធារណៈរដ្ឋខ្មែរ គេឃើញមានការកើនឡើងនូវអំពើពេស្យាចារ ពេញទីក្រុង យ៉ាងអនាធិបតេយ្យ ហើយក៏ពុំឃើញមានការហាមឃាត់ ឬ ចាត់វិធានការបង្ក្រាបពីសំណាក់រដ្ឋាភិបាលសម័យនោះឡើយ។ ម្យ៉ាងវិញទៀត យើងអាចនិយាយបានថា មូលហេតុដែលនាំឱ្យកើតអំពើពេស្យាចារច្រើននៅសម័យសាធារណៈរដ្ឋខ្មែរ ប្រហែលជាអាចបណ្តាលមកពី វត្តមានរបស់ទាហានអាមេរិក នៅឥណ្ឌូចិន ក្នុងអំឡុងពេល ធ្វើសង្គ្រាមជាមួយប្រទេសវៀតណាម ពីព្រោះថាទាហានអាមេរិកទាំងអស់នោះ បានឆ្លៀតឱកាសយកពេលវេលានេះ ទៅសម្រាកកម្សាន្ត សប្បាយ នៅក្នុងប្រទេសកម្ពុជា។

**២. សម័យកម្ពុជាប្រជាធិបតេយ្យ**

ដូចដែលយើងធ្លាប់បានដឹងហើយថា នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ឬ សម័យខ្មែរក្រហម ដែលបានចាប់បដិសន្ធិឡើងនៅក្នុងឆ្នាំ ១៩៧៥ ដល់ ១៩៧៩ ជារបបប្រល័យពូជសាសន៍ មានការសម្លាប់រង្គាលទៅលើប្រជាពលរដ្ឋខ្មែរ។ រីឯស្ថានភាពរស់នៅរបស់ប្រជាពលរដ្ឋខ្មែរវិញ នៅសម័យនោះ ត្រូវបានគេបំបិទសិទ្ធិសេរីភាពគ្រប់បែបយ៉ាង ហេតុនេះហើយ រាល់ការធ្វើអាជីវកម្មពេស្យាចារ ឬ អំពើសញ្ចារកម្ម ត្រូវបានលុបបំបាត់ចោលអស់ទាំងស្រុងនៅក្នុងរបបនេះ។

**៣. សម័យសាធារណៈរដ្ឋប្រជាមានិតកម្ពុជា និង រដ្ឋកម្ពុជា**

ក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩ របបសាធារណៈរដ្ឋប្រជាមានិតកម្ពុជា បានចាប់បដិសន្ធិឡើងចាប់ពីឆ្នាំ ១៩៧៩ ដល់ ១៩៨៩។ យើងសង្កេតឃើញថា ក្រោយពីប្រទេសកម្ពុជា រួចផុតពីរបបខ្មៅងងឹត (កម្ពុជាប្រជាធិបតេយ្យ) ហើយក៏ដោយ ប៉ុន្តែប្រទេសជាតិនៅតែស្ថិតនៅក្នុងស្ថានភាពវឹកវរ ច្របូកច្របល់ នៅទូទាំងផ្ទៃប្រទេសដដែល ហេតុនេះហើយយើងអាចនិយាយបានថា ប្រទេសកម្ពុជា មិនទាន់ទទួលបាននូវ សន្តិភាពពេញលេញនៅឡើយទេ។ ចំណែកឯ ប្រជាពលរដ្ឋខ្មែរវិញនៅសម័យនោះមានជីវភាព ក្រីក្រលំបាកច្រើន ហើយម្យ៉ាងវិញទៀត នៅក្នុងសម័យសាធារណៈរដ្ឋប្រជាមានិតកម្ពុជា គេឃើញមានការរឹតបន្តឹងសិទ្ធិសេរីភាពយ៉ាងខ្លាំងផងដែរ ពីសំណាក់រដ្ឋាភិបាលនាសម័យនោះ។ ហេតុដូច្នេះហើយ ចំពោះបញ្ហាអំពើពេស្យាចារ ឬ អំពើសញ្ចារកម្មនៅសម័យនោះមិនសូវជាកើតមានច្រើនឡើយ។

នៅអំឡុងឆ្នាំ ១៩៨៩ គឺស្ថិតនៅក្នុងសម័យរដ្ឋកម្ពុជា ដែលមានស្ថានភាពនយោបាយដូចគ្នាទៅនឹងសម័យសាធារណៈរដ្ឋប្រជាមានិតកម្ពុជាផងដែរ។ លុះដល់ ឆ្នាំ ១៩៩២-១៩៩៣ ទើបឃើញមានវត្តមានរបស់ អាជ្ញាធរអន្តរកាលសហប្រជាជាតិនៅកម្ពុជា (អ៊ុនតាក់) បានចូលមកធ្វើការសម្របសម្រួល ឱ្យមានការបោះឆ្នោត ដោយសេរី និងយុត្តិធម៌ ដើម្បីឈានទៅដល់ការបង្កើតនូវរដ្ឋធម្មនុញ្ញថ្មីមួយសម្រាប់ប្រទេសកម្ពុជា។

***<u>គួរកត់សម្គាល់ផងដែរថា:</u>*** នៅក្នុងអំឡុងពេលដែល អាជ្ញាធរអន្តរកាលសហប្រជាជាតិនៅកម្ពុជា ហៅកាត់ថា **អ៊ុនតាក់** មានវត្តមាននៅក្នុងប្រទេសកម្ពុជា គឺជាពេលវេលាដែលធ្វើឱ្យកើតមាននូវអំពើពេស្យាចារយ៉ាងច្រើនពាសពេញទីក្រុងភ្នំពេញ និងនៅតាមបណ្តាខេត្តជាច្រើនផ្សេងទៀត។

**កថាខណ្ឌទី ៣៖ សម័យព្រះរាជាណាចក្រកម្ពុជាទី ២**

**១. ការរៀបចំឡើងវិញនូវប្រព័ន្ធតតិយុត្តខ្មែរ**

ឆ្នាំ ១៩៩៣ ប្រទេសកម្ពុជាបានរៀបចំរចនាសម្ព័ន្ធដឹកនាំប្រទេសសារជាថ្មី ក្រោមកិច្ចជួយជ្រោមជ្រែង ពីសំណាក់ អង្គការសហប្រជាជាតិ ដោយរដ្ឋធម្មនុញ្ញថ្មីមួយ ត្រូវបានប្រកាសឱ្យប្រើនៅ

ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ១៩៩៣។ យោងតាមរដ្ឋធម្មនុញ្ញថ្មីនេះ បានហាមឃាត់នូវការធ្វើអាជីវកម្មផ្នែកពេស្យាចារដែលនាំឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស ជាពិសេស ស្ត្រី និង កុមារ ហើយព្រមទាំងការពារនូវសិទ្ធិរបស់កុមារដោយស្របទៅតាមអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារផងដែរ។

## ២. លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបង្ក្រាបអំពើជួញដូរមនុស្ស

ឆ្នាំ ១៩៩៦ រដ្ឋសភាជាតិ នៃព្រះរាជាណាចក្រកម្ពុជាបានអនុម័ត ច្បាប់ស្តីពីការបង្ក្រាបអំពើពង្រាត់ និងលក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្ស នាសម័យប្រជុំលើកទី ៥ នីតិកាលទី ១ ។ ការអនុម័តច្បាប់នេះឡើងក្នុងគោលបំណងបង្ក្រាបអំពើពង្រាត់មនុស្ស យកទៅលក់ដូរ ឬ អំពើធ្វើអាជីវកម្មលើមនុស្ស និង ដើម្បីលើកកម្ពស់ប្រពៃណីដ៏ល្អរបស់ជាតិ ហើយថែមទាំងការពារសេចក្តីថ្លៃថ្នូររបស់មនុស្សទៀតផង។ ប៉ុន្តែដោយសារច្បាប់នេះនៅមានចំណុចខ្វះចន្លោះ និងមានលក្ខណៈទូលំទូលាយពេកនាំឱ្យមានភាពមិនច្បាស់លាស់ ទើបក្រសួងយុត្តិធម៌បានផ្តួចផ្តើមគំនិតតាក់តែងសេចក្តីព្រាងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទឡើងនៅក្នុងឆ្នាំ ១៩៩៩ ដោយមានការសហការជាមួយវិទ្យាស្ថានអភិវឌ្ឍន៍ផ្នែកច្បាប់នៃប្រទេសជប៉ុន និងមានការគាំទ្រពីអង្គការយូនីសេហ្វ ដើម្បីជំនួសឱ្យច្បាប់ចាស់។

ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទនេះ ស្របទៅតាមអនុសញ្ញាអន្តរជាតិស្តីពីកុមារ និងពិធីសារតាមជំរើសទាក់ទងនិងអនុសញ្ញាស្តីពីសិទ្ធិកុមារ ពាក់ព័ន្ធនឹងការលក់កុមារ ពេស្យាកម្មកុមារ និងរូបភាព ឬសម្ភារៈអាសអាភាសកុមារដែលប្រទេសកម្ពុជាបានចុះហត្ថលេខា នៅខែមិថុនា ឆ្នាំ ២០០០។ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទនេះត្រូវបានអនុម័តឡើង ក្នុងគោលបំណងដើម្បីការពារសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស និងបង្កើននូវសុខភាព និងសុខុមាលភាព របស់ប្រជាពលរដ្ឋ និងរក្សាការពារ លើកកម្ពស់នូវទំនៀមទម្លាប់ប្រពៃណីដ៏ល្អរបស់ជាតិ និងមានគោលបំណងអនុវត្តឱ្យបានសមស្របផងដែរ តាមពិធីសារអង្គការសហប្រជាជាតិ ស្តីពីការទប់ស្កាត់ ការបង្ក្រាប និងការផ្តន្ទាទោសការជួញដូរមនុស្ស ជាពិសេស ស្ត្រីនិងកុមារ បន្ថែមលើអនុសញ្ញាអង្គការសហប្រជាជាតិ ប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន ឬ ឧបករណ៍ ឬ កិច្ចព្រមព្រៀងអន្តរជាតិផ្សេងទៀត ទាក់ទងនឹងការជួញដូរមនុស្ស ដែលព្រះរាជាណាចក្រកម្ពុជាបានឱ្យសច្ចាប័ន ឬ ចុះហត្ថលេខា[2]។

ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទត្រូវបានរៀបចំឡើងមុនក្រមព្រហ្មទណ្ឌ ហើយនៅក្នុងពេលនោះដែរ ក្រមព្រហ្មទណ្ឌ កំពុងនៅជាសេចក្តីព្រាងដូចគ្នានឹង

[2] មាត្រា ១ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទឆ្នាំ ២០០៨

ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទផងដែរ។ ហេតុដូច្នេះហើយទើបកាលបរិច្ឆេទ ប្រកាសឱ្យប្រើច្បាប់ទាំងពីរនេះ មានការខុសគ្នាបន្តិច ប៉ុន្តែខ្លឹមសារនៃច្បាប់មានអត្ថន័យប្រហាក់ប្រហែលគ្នា។

## ផ្នែកទី ២៖ លក្ខណៈនៃអំពើសញ្ចារកម្ម

### កថាខណ្ឌទី ១៖ ទម្រង់នៃអំពើសញ្ចារកម្ម

#### ១. ការទាញយកអត្ថប្រយោជន៍ហិរញ្ញវត្ថុពីអំពើពេស្យាចាររបស់ជនដទៃ[3]

ជាទូទៅអ្នកដែលប្រព្រឹត្តអំពើសញ្ចារកម្ម ត្រូវបានច្បាប់ចាត់ទុកថា **សញ្ចារិក**[4] ឬ **សញ្ចារិកា**[5] ឬ បុគ្គលជាមេពេស្យា ដោយបានធ្វើការទាញយកអត្ថប្រយោជន៍ហិរញ្ញវត្ថុ ពីសេវាកម្មបម្រើផ្លូវភេទរបស់បុគ្គលពេស្យា ។ ការទាញយកអត្ថប្រយោជន៍ហិរញ្ញវត្ថុពីបុគ្គលពេស្យា មិនមែនធ្វើឡើងដោយមានការព្រមព្រៀង ឬ ស្ម័គ្រចិត្តរវាង បុគ្គលពេស្យា និង មេពេស្យាឡើយ ពោល គឺ ធ្វើឡើងដោយការបង្ខិតបង្ខំ ការគំរាមកំហែង គ្រប់រូបភាព ក្នុងគោលបំណងដើម្បីឱ្យបុគ្គលពេស្យាប្រព្រឹត្តនូវអំពើពេស្យាចារ ដូចជា ការរួមសេពសន្ថវៈជាមួយអតិថិជនដើម្បីធ្វើការដោះដូរយកប្រាក់ ក្នុងករណីនេះគឺចង់សំដៅតែទៅលើបុគ្គលរងគ្រោះ ដែលត្រូវបានគេចាប់បង្ខំឱ្យធ្វើជាស្រីពេស្យានោះទេ។ ត្រង់ចំណុចនេះហើយ យើងអាចធ្វើការចោទជាបញ្ហាគតិយុត្តឡើងថា ចុះប្រសិនជាការទាញយកអត្ថប្រយោជន៍ហិរញ្ញវត្ថុ ពីបុគ្គលពេស្យានោះ ប្រព្រឹត្តទៅដោយមានការព្រមព្រៀង ចេញពីឆន្ទៈផ្ទាល់ រវាង បុគ្គលពេស្យា និងមេពេស្យាវិញ តើច្បាប់អាចធ្វើការផ្តន្ទាទោសចំពោះមេពេស្យាបានដែរ ឬ ទេក្នុងករណីនេះ?

ជាគោលការណ៍ នៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ២៨៤ និងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ត្រង់មាត្រា ២៥ ដោយបានបញ្ញត្តិអំពីនិយមន័យនៃសញ្ចារកម្ម ជាច្រើនទម្រង់ ជាពិសេស ការទាញយកអត្ថប្រយោជន៍ហិរញ្ញវត្ថុពីអំពើពេស្យាចាររបស់ជនដទៃ ត្រង់ចំណុចនេះហើយដែលច្បាប់មិនបានបញ្ជាក់អំពី ការទាញយកអត្ថប្រយោជន៍នោះធ្វើឡើងក្នុងរូបភាពបែបណាឡើយ ប៉ុន្តែដោយយោងទៅតាមនិយមន័យនេះអាចឱ្យយើងយល់បានថា ទោះបីជាការទាញយកអត្ថប្រយោជន៍នោះធ្វើឡើងក្រោមទម្រង់រូបភាពបែបណាក៏ដោយ (ព្រមព្រៀង ឬ គ្មានការព្រមព្រៀង) ឱ្យតែមានការទាញយកអត្ថប្រយោជន៍ដោយមេពេស្យា ទៅលើបុគ្គលពេស្យា គឺជាសញ្ចារកម្ម។

---

[3] កថាខណ្ឌទី១ ចំណុចទី១ មាត្រា ២៥ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទឆ្នាំ ២០០៨

[4] **សញ្ចារិក៖** បុរសដែលរកស៊ីបរពេស្យាចារ, បុរសដែលធ្វើអាជីវកម្មពេស្យាចារ

[5] **សញ្ចារិកា៖** ស្ត្រីដែលរកស៊ីបរពេស្យាកម្ម, ស្ត្រីដែលធ្វើអាជីវកម្មពេស្យាចារ

ពាក្យថា ផលប្រយោជន៍ហិរញ្ញវត្ថុនៅទីនេះ មិនមែនសំដៅតែទៅលើប្រាក់កាសប៉ុណ្ណោះទេ ប៉ុន្តែ វត្ថុផ្សេងៗដែលអាចមានតម្លៃ រួមមានដូចជា៖ **ចលនវត្ថុ** (ឡាន ម៉ូតូ គ្រឿងអលង្ការ មាស ពេជ្រ សំលៀកបំពាក់...) **អចលនវត្ថុ** (ផ្ទះ អគារ ដី...) និង **សិទ្ធិប្រត្យក្ស** (សិទ្ធិលើកម្មសិទ្ធិ សិទ្ធិប្រើប្រាស់សិទ្ធិលក់ ឬ សិទ្ធិជួល នៃប្រភេទណាមួយក្នុងចំណោមចលនទ្រព្យ និងអចលនទ្រព្យ ) ជាដើម។ រាល់ការទាញយកអត្ថប្រយោជន៍ហិរញ្ញវត្ថុពីអំពើពេស្យាចាររបស់ជនដទៃ ដោយចេតនាត្រូវចាត់ទុកជាសញ្ចារកម្ម ប៉ុន្តែនៅក្នុងករណីខ្លះទៀត បុគ្គលដែលបានទាញយកផលប្រយោជន៍ទាំងអស់នោះ ពុំបានដឹងថាផលប្រយោជន៍ទាំងនោះ បានមកដោយសារអំពើពេស្យចាររបស់ជនដទៃ ហើយបុគ្គលនោះក៏មិនមានចេតនាឱ្យជនណាមួយប្រព្រឹត្តពេស្យាចារឡើយ ហេតុនេះគាត់មិនគួរទទួលខុសត្រូវ ឬ ត្រូវផ្តន្ទាទោសអ្វីឡើយ។

<u>ឧទាហរណ៍:</u> ម្ចាស់ ហាងស៊ី ផឹក មួយកន្លែង បានជួលហាងរបស់ខ្លួនទៅឱ្យបុគ្គលម្នាក់ទៀតក្នុងរយៈពេលមួយយ៉ាងខ្លី ដើម្បីទទួលបានប្រាក់ពីការជួលនោះយកទៅសងបំណុលគេ ប៉ុន្តែម្ចាស់ហាងពុំបានដឹងថា បុគ្គលដែលជួលហាងរបស់គាត់ ជាជនទុច្ចរិត ដោយយកហាងនោះទៅប្រកបអាជីវកម្មពេស្យាចារ។

ដូច្នេះដើម្បីឱ្យអ្នកប្រព្រឹត្តទទួលទោសបាន លុះត្រាតែជននោះមានចេតនា ដោយដឹងយ៉ាងច្បាស់ថា អត្ថប្រយោជន៍ហិរញ្ញវត្ថុដែលគាត់ទទួលបាននោះ គឺដោយសារអំពើពេស្យាចាររបស់ជនដទៃ។

### ២. ជួយ ឬការពារអំពើពេស្យាចាររបស់ជនដទៃ[6]

ត្រូវបានចាត់ទុកជាអំពើសញ្ចារកម្មផងដែរ ចំពោះបុគ្គលដែលបានជួយសម្រួល ឬ បិទបាំងនូវ អំពើពេស្យាចាររបស់ជនដទៃ។ ចំពោះពាក្យថា ការជួយសម្រួល ឬ បិទបាំង មានន័យថា ជាសកម្មភាពនៃការជួយ ការការពារ ឬ ការបិទបាំងទាំងឡាយណា ដើម្បីឱ្យបានសម្រេចក្នុងគោលបំណងអ្វីមួយ។ ចំណែកឯពាក្យថា អំពើពេស្យាចាររបស់ជនដទៃវិញ មានន័យថា ជាសកម្មភាពនៃអាជីវកម្មពេស្យាចារ។

ដូច្នេះការជួយសម្រួល ឬ ការការពារអំពើពេស្យាចាររបស់ជនដទៃ សំដៅដល់សកម្មភាពទាំងឡាយណា ដែលនាំឱ្យមានការសម្រួល ដោយមានការការពារ និងបិទបាំង ក្នុងគោលបំណងដើម្បីឱ្យការធ្វើអាជីវកម្មពេស្យាចារនោះមានការីកចម្រើន និងប្រព្រឹត្តទៅដោយរលូន។

<u>ឧទាហរណ៍:</u> អ្នកគ្រប់គ្រងផ្ទះបន បានជួលបុគ្គលណាម្នាក់ឱ្យធ្វើជាអ្នកត្រួតពិនិត្យមើលការខុសត្រូវ និងការពារស្រីពេស្យា ដើម្បីឱ្យស្រីពេស្យាទាំងនោះ អាចបម្រើសេវាកម្មផ្លូវភេទដល់

[6] កថាខណ្ឌទី១ ចំណុចទី២ មាត្រា២៥ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទឆ្នាំ ២០០៨

អតិថិជនបាន។ ក្នុងករណីនេះអ្នកគ្រប់គ្រងផ្ទះបន បាននឹងកំពុងការពារអំពើពេស្យាចាររបស់ជនដទៃ។ ម្យ៉ាងវិញទៀត ប្រសិនបើ មានការវាយឆ្មក់ពីនគរបាល បុគ្គលដែលជាអ្នកត្រួតពិនិត្យបានជូនដំណឹងទៅអ្នកគ្រប់គ្រងផ្ទះបន ឱ្យមានការត្រៀមខ្លួនទុកជាមុន ដើម្បីលាក់បាំងសកម្មភាពពេស្យាចារនៅក្នុងផ្ទះបន មានន័យថាបុគ្គលនោះកំពុងតែការពារអំពើពេស្យាចាររបស់ជនដទៃផងដែរ។

ផ្ទុយទៅវិញ ប្រសិនបើជនណាមួយបានជួយសម្រួល ការពារ ឬ លាក់បាំងអំពើពេស្យាចារ ប៉ុន្តែជននោះមិនមានចេតនាទាល់តែសោះ ដើម្បីឱ្យសកម្មភាពពេស្យាចារនៅមានការរីកចម្រើនបន្ត ហេតុនេះគាត់មិនគួរទទួលខុសត្រូវទេ។

ឧទាហរណ៍: គ្រូពេទ្យបានផ្តល់សេវាកម្មព្យាបាលជម្ងឺដល់ មេពេស្យា និង ស្ត្រីពេស្យា ។ល។

### ៣. ជ្រើសរើស អូសទាញ ឬ បណ្តុះបណ្តាលបុគ្គលណាមួយឱ្យធ្វើអំពើពេស្យាចារ[7]

ជាទូទៅរាល់សកម្មភាពទាំងឡាយណាដែលនាំឱ្យមានការជ្រើសរើស អូសទាញ ឬ បណ្តុះ-បណ្តាលបុគ្គលណាម្នាក់ ឱ្យធ្វើអំពើពេស្យាចារ គឺត្រូវចាត់ទុកជាសញ្ចារកម្ម ដោយហេតុថាអ្នកប្រព្រឹត្តមានចេតនាទុច្ចរិត ដោយប្រើប្រាស់មធ្យោបាយ អូសទាញ ឬ បណ្តុះបណ្តាល ក្នុងគោលបំណងដើម្បីធ្វើយ៉ាងណាឱ្យបុគ្គលដែលត្រូវបានអូសទាញទាំងនោះយល់ព្រម និងស្ម័គ្រចិត្តធ្វើអំពើពេស្យាចារ។

ឧទាហរណ៍: ១. មេបនបានសុំឱ្យបុគ្គលណាម្នាក់ ឬ បុគ្គលច្រើននាក់ធ្វើអំពើពេស្យាចារនៅក្នុងផ្ទះបន ដោយសន្យាថា និងផ្តល់កម្រៃឱ្យ ប្រសិនបើបុគ្គលទាំងនោះយល់ព្រមបម្រើសេវាកម្មផ្លូវភេទនៅក្នុងផ្ទះបនរបស់ខ្លួន។

ឧទាហរណ៍: ២. ប្រសិនបើមេបនបានធ្វើការអូសទាញ និងបណ្តុះបណ្តាលជនណាមួយ ឱ្យធ្វើអំពើពេស្យាចារនៅក្នុងគ្រឹះស្ថានរបស់ខ្លួន អំពើនោះក៏ត្រូវចាត់ទុកជាសញ្ចារកម្ម។

ដើម្បីឱ្យអ្នកប្រព្រឹត្តអាចទទួលខុសត្រូវបាន លុះត្រាតែអ្នកប្រព្រឹត្តនោះមានចេតនា ចង់ឱ្យបុគ្គលណាម្នាក់មកធ្វើជាបុគ្គលពេស្យា តាមសកម្មភាពជ្រើសរើស អូសទាញ ឬ ការបណ្តុះបណ្តាលរបស់ខ្លួន។

ទោះបីជាយ៉ាងណាក៏ដោយ ប្រសិនបើអ្នកប្រព្រឹត្តមិនមានចេតនាក្នុងការ អូសទាញ បណ្តុះបណ្តាល បុគ្គលណាមួយឱ្យធ្វើអំពើពេស្យាចារ ឬ ធ្វើឱ្យមានការរីកចម្រើនដល់សកម្មភាពពេស្យាចារទេ អ្នកប្រព្រឹត្តនោះមិនមានកំហុសឡើយ ពីព្រោះការអូសទាញ ឬការបណ្តុះបណ្តាលទាំងនោះ គឺធ្វើឡើងក្នុងគោលបំណងចង់ឱ្យបុគ្គលណាម្នាក់ យល់ដឹងពីបញ្ហានានា ពាក់ព័ន្ធនិងសុខភាព។

---
[7] កថាខណ្ឌទី១ ចំណុចទី៣ មាត្រា២៥ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទឆ្នាំ ២០០៨

ឧទាហរណ៍: អង្គការក្រៅរដ្ឋាភិបាលបានចុះធ្វើសកម្មភាពអប់រំដល់ប្រជាពលរដ្ឋអំពីការទប់ស្កាត់ និងជម្ងឺអេដស៍ជាដើម។ល។

### ៤. ធ្វើការគាបសង្កត់លើបុគ្គលណាមួយ ដើម្បីឱ្យបុគ្គលនោះធ្វើពេស្យាចារ[8]

ការគាបសង្កត់ទៅលើបុគ្គលណាម្នាក់ ក្នុងគោលបំណង ដើម្បីឱ្យបុគ្គលនោះប្រព្រឹត្តអំពើពេស្យាចារ ត្រូវចាត់ទុកជាសញ្ចារកម្ម។ ទម្រង់បែបនេះធ្វើឱ្យយើងគិតដល់ស្ថានភាពនៃការជួញដូរមនុស្សយកទៅធ្វើអាជីវកម្មផ្លូវភេទ ហើយបុគ្គលដែលរងគ្រោះភាគច្រើនជានារីភេទ ត្រូវបានគេចាប់ឃុំឃាំងខ្លួន នៅក្នុងបន្ទប់ជាប់ ដោយទទួលរងនូវការវាយដំ គាបសង្កត់គ្រប់បែបយ៉ាង ពីសំណាក់មេបន។

ពាក្យថា គាបសង្កត់ មានន័យថា ការដាក់សម្ពាធ ការបង្ខំ ការគាបសង្កត់ទៅលើរូបរាងកាយ ឬ ចិត្ត ឬ ធ្វើការគាបសង្កត់ផ្នែកហិរញ្ញវត្ថុជាដើម។

ឧទាហរណ៍: ក្នុងករណីដែលអ្នកប្រព្រឹត្តបានបញ្ចុះបញ្ចូល អ្នកបម្រើស្រីនៅក្នុងផ្ទះរបស់ខ្លួនឱ្យធ្វើជាស្រីពេស្យា ប៉ុន្តែបុគ្គលនោះមិនយល់ព្រម ដូច្នេះអ្នកប្រព្រឹត្តបានធ្វើការគំរាមកំហែង ដោយគាបសង្កត់ទៅលើអ្នកបម្រើនោះ ឱ្យធ្វើជាស្រីពេស្យា។

ផ្ទុយទៅវិញ ប្រសិនអ្នកប្រព្រឹត្តធ្វើការគំរាមកំហែងទៅលើបុគ្គលពេស្យាវិញ ដោយប្រើប្រាស់អំពើហិង្សា វាយដំ លើបុគ្គលពេស្យា ដើម្បីឱ្យបុគ្គលនោះបន្តសកម្មភាពបម្រើសេវាកម្មផ្លូវភេទ ក្នុងករណីនេះមិនមែនជាទម្រង់ ធ្វើការគាបសង្កត់ទៅលើបុគ្គលណាមួយ ដើម្បីឱ្យបុគ្គលនោះធ្វើពេស្យាចារឡើយ ប៉ុន្តែជាអំពើសញ្ចារកម្មដោយមានស្ថានទម្ងន់ទោស ដែល ស្ថិតនៅក្នុង ចំណុចទី ៣ មាត្រា ២៧ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

## កថាខណ្ឌទី ២៖ អំពើដែលត្រូវបានចាត់ទុកដូចគ្នាទៅនឹងអំពើសញ្ចារកម្ម

### ១. អំពើធ្វើជាអន្តរការី រវាងបុគ្គលដែលធ្វើពេស្យាចារ និងបុគ្គលដែលប្រកបអាជីវកម្ម ឬ ឱ្យលាភការដល់ពេស្យាចាររបស់ជនដទៃ[9]

ក្រោយពីបានធ្វើការសិក្សា និងស្វែងយល់អំពីលក្ខណៈនៃអំពើសញ្ចារកម្មរួចមក នាំឱ្យយើងមានការស្គាល់នូវរូបភាពមួយចំនួន ដែលស្តែងចេញជាសកម្មភាពផ្សេងៗគ្នា ក្នុងគោលបំណងដែលសំខាន់បំផុត គឺដើម្បីទាញយកអត្ថប្រយោជន៍ ហិរញ្ញវត្ថុពីអំពើពេស្យាចាររបស់ជនដទៃ។ ហេតុនេះហើយអំពើសញ្ចារកម្ម ត្រូវបានគេចាត់ទុកថាជាអំពើមួយដែលមានលក្ខណៈស្មុគស្មាញ ដែលអាចធ្វើឱ្យយើងយល់តាមរបៀបផ្សេងៗពីគ្នា ដោយស្របតាមការកំណត់និយមន័យជាច្រើនផ្សេងគ្នា នៃសញ្ចារកម្ម។

[8] កថាខណ្ឌទី១ ចំណុចទី៤ មាត្រា២៥ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទឆ្នាំ ២០០៨

[9] កថាខណ្ឌទី២ ចំណុចទី១ មាត្រា២៥ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទឆ្នាំ ២០០៨

ខាងក្រោមនេះ យើងនឹងធ្វើការបកស្រាយទៅលើ អំពើធ្វើជាអន្តរការី រវាងបុគ្គលដែលធ្វើពេស្យាចារ និងបុគ្គលដែលប្រកបអាជីវកម្ម ឬឱ្យលាភការដល់ពេស្យាចារជនដទៃ។

**ការធ្វើជាអន្តរការីរវាបុគ្គល ២ នាក់ ដែលរួមមាន:**

- បុគ្គលពេស្យា និង
- បុគ្គលដែលប្រកបអាជីវកម្ម

មានន័យថាបុគ្គលជាអ្នកប្រព្រឹត្ត ធ្វើជាអន្តរការីតាមរយៈការណែនាំ បុគ្គលពេស្យា ទៅឱ្យបុគ្គលម្នាក់ទៀតដែលជាអ្នកប្រកបអាជីវកម្មពេស្យាចារ។ ជាទូទៅសកម្មភាពបែបនេះ អាចឱ្យយើងយល់បានថា ជាសកម្មភាពមួយដែលធ្វើឱ្យបុគ្គលជាអ្នកប្រព្រឹត្ត រំពឹងទុកថានឹងបានទទួលផលតបស្នងមកវិញ ពីសកម្មភាពនៃអំពើរបស់ខ្លួន។

ឧទាហរណ៍: លោក **ក** បាននាំ កញ្ញា **ខ** ជាស្រីពេស្យា ទៅឱ្យម្ចាស់ផ្ទះបន ដែលធ្វើអាជីវកម្មពេស្យាចារ ហេតុនេះហើយ ម្ចាស់ផ្ទះបន បានឱ្យប្រាក់ ១០ ដុល្លារ ទៅ លោក **ក** ជាតម្លៃតបស្នង។

ដូច្នេះបុគ្គលដែលធ្វើជាអន្តរការី រវាងបុគ្គលពេស្យា និងបុគ្គលដែលប្រកបអាជីវកម្ម ត្រូវទទួលការផ្តន្ទាទោស ប្រសិនបើសកម្មភាពនៃអំពើនោះនាំឱ្យមាន ការសម្រួលដល់ការប្រព្រឹត្តអំពើពេស្យាចារ។ ផ្ទុយទៅវិញ ប្រសិនបើការធ្វើជាអន្តរការីរវាងបុគ្គលពេស្យា និងអ្នកប្រកបអាជីវកម្មមិនមែនធ្វើឡើងក្នុងគោលបំណងជម្រុញឱ្យប្រព្រឹត្តអំពើពេស្យាចារនោះទេ ហេតុនេះគាត់មិនគួរទទួលខុសត្រូវឡើយ ដោយសារតែនៅពេលខ្លះ បុគ្គលដែលធ្វើជាអន្តរការី គ្រាន់តែណែនាំបុគ្គលពេស្យា ឱ្យធ្វើការងារផ្សេង ក្រៅពីអំពើពេស្យាចារ រួមមានដូចជា៖ អ្នកបោសសំអាត អ្នកគិតលុយ ឬចុងភៅដែលម្រើការងារនៅក្នុងផ្ទះបនជាដើម។

**២. អំពើរបស់ជនណាដែលបានសម្រួល ឬ បិទបាំង នូវធនធានដែលខ្លួនបានដឹងថាបានមកពីអំពើសញ្ជារកម្ម**[10]

ត្រូវបានចាត់ទុកដូចគ្នាទៅនឹងអំពើសញ្ជារកម្មផងដែរ ប្រសិនបើ បុគ្គលណាមួយបានជួយសម្រួល ឬ បិទបាំងនូវធនធាន ដែលខ្លួនបានដឹងថា បានមកពីអំពើសញ្ជារកម្ម។ ត្រង់ចំណុចនេះ អាចឱ្យយើងចោទជាសំណួរឡើងថា តើការសម្រួល ឬ ការបិទបាំងនូវធនធាន ដែលបានមកដោយអំពើសញ្ជារកម្មនោះធ្វើឡើងដោយរបៀបណា? ខាងក្រោមនេះយើងនឹងធ្វើការបកស្រាយទៅលើពាក្យថា " ការជួយសម្រួលធនធាន" និង " ការបិទបាំងនូវធនធាន" ដែលបានមកពីអំពើសញ្ជារកម្មមកធ្វើការពន្យល់។

[10] កថាខណ្ឌទី២ ចំណុចទី២ មាត្រា២៥ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទឆ្នាំ ២០០៨

**ការជួយសម្រួលធនធាន** មានន័យថា: ជាការធ្វើឱ្យប្រសើរឡើងចំពោះធនធានដែលបានមកពីការទាញយកអត្ថប្រយោជន៍ហិរញ្ញវត្ថុពីអំពើពេស្យាចាររបស់ជនដទៃ រួមមានដូចជា ការដឹកជញ្ជូន ការផ្ទេរ ការបង់ ឬ ការទទួលប្រាក់ជាដើម។

**ជាទូទៅធនធានទាំងអស់នោះរួមមានជាអាទិ៍:**

- លាភការជាប្រាក់
- វត្ថុឧបករណ៍រូបិយវត្ថុ
- វត្ថុមានតម្លៃ
- ទ្រព្យសម្បត្តិដែលមានរូបរាង
- សិទ្ធិប្រត្យក្ស -ល-។

**ការបិទបាំងនូវធនធាន** មានន័យថា: ជាការក្លែងបន្លំមិនឱ្យដឹងពីប្រភពដើមនៃធនធាន ឬការលាក់បាំងមិនឱ្យស្គាល់ពីទីកន្លែងដែលធនធាននោះបានមកពីអំពើសញ្ចារកម្ម។

ដូច្នេះរាល់អំពើរបស់ជនណាដែលបានជួយសម្រួល ឬ បិទបាំងនូវធនធានដែលខ្លួនបានដឹងថាបានមកពីអំពើសញ្ចារកម្ម ជននោះនឹងត្រូវទទួលរងការផ្តន្ទាទោស ដូចគ្នាទៅនឹងការប្រព្រឹត្តសញ្ចារកម្មផងដែរ។

ផ្ទុយទៅវិញប្រសិនបើបុគ្គលណាមួយមិនបានដឹង ឬ គ្មានចេតនាក្នុងការជួយសម្រួល ឬ បិទបាំងនូវធានធានដែលបានមកដោយអំពើសញ្ចារកម្ម បុគ្គលនោះមិនគួរទទួលខុសត្រូវឡើយ។

<u>ឧទាហរណ៍:</u> មេពេស្យា បានយកប្រាក់ ១០០០ ដុល្លារ ពីការប្រកបអាជីវកម្មពេស្យាចារ ទៅដាក់បញ្ចូលក្នុងគណនីធនាគាររបស់គាត់ ហេតុនេះធនាគារ មិនត្រូវមានការផ្តន្ទាទោសឡើយ ដោយសារតែធនាគារ មិនបានដឹងពីប្រភពធនធានដែលកើតចេញមកពីអំពើសញ្ចារកម្មឡើយ។

អាស្រ័យហេតុនេះ ដើម្បីអាចធ្វើការផ្តន្ទាទោសទៅលើជនដែលបានជួយសម្រួល ឬបិទបាំងនូវធានធាន ដែលបានមកដោយអំពើសញ្ចារកម្មបាន លុះត្រាតែជននោះត្រូវបានដឹងយ៉ាងច្បាស់ពីប្រភពធនធាន ហើយមានចេតនាលាក់បាំង ឬជួយសម្រួលនូវធនធាន ដែលបានមកពីអំពើសញ្ចារកម្ម។

**៣. អំពើរារាំងដល់ការបង្ការ ការជួយ ឬ ការអប់រំជាថ្មី ដោយទីភ្នាក់ងារសាធារណៈ ឬ ដោយអង្គការឯកជនដែលមាននីតិសម្បទា ដែលធ្វើឡើងដើម្បីជាគុណប្រយោជន៍ដល់បុគ្គលដែលប្រព្រឹត្តពេស្យាចារ ឬ កំពុងមានគ្រោះដោយការធ្វើពេស្យាចារ**[11]

ចំពោះអំពើរារាំងដល់ការបង្ការ ការជួយ ឬការអប់រំជាថ្មី ដោយទីភ្នាក់ងារសាធារណៈ ឬ អង្គការឯកជន ដែលមាននីតិសម្បទា ដែលធ្វើឡើងដើម្បីជាគុណប្រយោជន៍ដល់បុគ្គលដែលប្រព្រឹត្ត

[11] កថាខណ្ឌទី២ ចំណុចទី៣ មាត្រា២៥ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទឆ្នាំ ២០០៨

ពេស្យាចារ ឬ កំពុងមានគ្រោះដោយការធ្វើពេស្យាចារ គឺត្រូវចាត់ទុកដូចគ្នាទៅនឹងអំពើសញ្ចារកម្ម ផងដែរ។ ពីព្រោះថាការរារាំងទាំងនោះ មានចេតនាជម្រុញឱ្យមានអំពើពេស្យាចារកើតឡើង។ ហេតុនេះប្រសិនបើមានជនណាមួយ បានរារាំងដល់ការជួយ ឬការអប់រំជាថ្មីដោយទីភ្នាក់ងារសាធារណៈ ឬ អង្គការឯកជនដែលធ្វើឡើងដើម្បីជាប្រយោជន៍សម្រាប់បុគ្គលដែលប្រព្រឹត្តពេស្យាចារ ឬ បុគ្គលកំពុងរងគ្រោះដោយអំពើពេស្យាចារ ជននោះនឹងត្រូវទទួលរងការផ្តន្ទាទោស ពីបទរារាំងដល់ការបង្ការអំពើពេស្យាចារ ឬ បទសញ្ចារកម្ម ដោយស្របទៅតាម ក្រមព្រហ្មទណ្ឌ និងច្បាប់ស្តីពីការបង្រ្កាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

<u>ឧទាហរណ៍:</u> ក្រោយពីការធ្វើប្រតិបត្តិការជួយសង្រ្គោះជនរងគ្រោះដោយនគរបាល ពីការធ្វើអាជីវកម្មផ្លូវភេទរួចមក ហេតុនេះជនរងគ្រោះត្រូវបានបញ្ជូនទៅមជ្ឈមណ្ឌលអប់រំ និង បណ្តុះបណ្តាល ដើម្បីផ្តល់ជាកន្លែងសម្រាប់ស្នាក់នៅបណ្តោះអាសន្ន សម្រាប់ពួកគាត់[12]។ ក្នុងករណីនេះប្រសិនបើមានជនណាមួយ បានរារាំងដល់ការជួយរបស់ភ្នាក់ងារសាធារណៈ ក្នុងគោលបំណងទុច្ចរិត (ជម្រុញឱ្យមានការប្រព្រឹត្តអំពើពេស្យា) មានន័យថាជននោះ កំពុងប្រព្រឹត្តអំពើសញ្ចារកម្ម។

ទោះបីជាយ៉ាងណាក៏ដោយ ប្រសិនបើអំពើរារាំង នូវការជួយ ឬការអប់រំជាថ្មីដោយភ្នាក់ងារសាធារណៈ ឬ អង្គការឯកជនក្នុងគោលបំណងដើម្បីជាគុណប្រយោជន៍ដល់បុគ្គលដែលប្រព្រឹត្តពេស្យាចារ ឬកំពុងមានគ្រោះដោយការធ្វើពេស្យាចារ ពុំអាចត្រូវផ្តន្ទាទោសឡើយ កាលបើអំពើនោះ ប្រព្រឹត្តឡើងក្នុងគោលដៅដើម្បីការពារសិទ្ធិសេរីភាពដល់បុគ្គលរងគ្រោះ។

<u>ឧទាហរណ៍:</u> មេធាវីការពារបុគ្គលពេស្យា ពីការរក្សាទុក ជនរងគ្រោះនៅក្នុងមជ្ឈមណ្ឌលអប់រំថៃទាំ របស់ភ្នាក់ងារសាធារណៈ ដោយតម្រូវឱ្យមានការដោះលែងជាបន្ទាន់ ដើម្បីឱ្យបុគ្គលពេស្យានោះមានសិទ្ធិសេរីភាពឡើងវិញ ពីព្រោះថាកាលដែលនៅក្នុងមជ្ឈមណ្ឌល អប់រំថៃទាំនោះមានការរឹតបន្តឹងសិទ្ធិសេរីភាពខ្លាំងពេក។

អាស្រ័យហេតុនេះ ដើម្បីឱ្យជនប្រព្រឹត្តទទួលរងនូវការផ្តន្ទាទោសបាន លុះត្រាតែជននោះមានចេតនាក្នុងការជួយសម្រួល ឬ ជម្រុញឱ្យមានអំពើពេស្យាចារកើតឡើង។

### **កថាខណ្ឌទី ៣៖ សកម្មភាពដែលមិនត្រូវបានចាត់ទុកដូចគ្នាទៅនឹងអំពើសញ្ចារកម្ម**

#### **១. ការប្រព្រឹត្តអំពើពេស្យាចារដោយខ្លួនឯង**

ជាការពិតណាស់នៅក្នុង ច្បាប់ស្តីពីការបង្រ្កាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ មិនបានចែងដាក់ទោស ចំពោះបុគ្គលណាមួយ ដែលបានប្រព្រឹត្តអំពើពេស្យាចារដោយខ្លួនឯង

[12] សូមមើល សេចក្តីណែនាំរបស់អគ្គស្នងការដ្ឋាននគរបាលជាតិ នៃក្រសួងមហាផ្ទៃ លេខ ០០៩ សណន ចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ ២០១០ ស្តីពីការអនុវត្តន៍កិច្ចប្រតិបត្តការសង្រ្គោះជនរងគ្រោះដោយអំពើជួញដូរមនុស្ស និង/ឬការធ្វើអាជីវកម្មផ្លូវភេទ នៅតាមបណ្តាទីតាំងដែលបានកំណត់

នោះទេ ដោយសារ តែការប្រព្រឹត្តនេះពុំមានលក្ខណៈទាញយកផលប្រយោជន៍ហិរញ្ញវត្ថុពីបុគ្គលពេស្យាដទៃ ហើយការប្រព្រឹត្តអំពើពេស្យាចារដោយខ្លួនឯងនេះ គឺដើម្បីទាញយកផលប្រយោជន៍សម្រាប់ខ្លួនឯង ដែលមានលក្ខណៈខុសពីសញ្ចារិក ឬ សញ្ចារិកា។

**អំពើពេស្យាចារ** មានន័យថា ការរួមភេទជាមួយជនណាម្នាក់ដែលមិនកំណត់ ឬ អំពើគ្រប់រូបភាពផ្សេងទៀត ដែលទាក់ទងនឹងភេទ ដោយផ្លោះប្តូរ និងវត្ថុមានតម្លៃអ្វីមួយ[13]។

នៅក្នុងប្រទេសកម្ពុជាយើង បើតាមការសង្កេតឃើញពីស្ថានភាពសង្គមជាក់ស្តែង ចំពោះសកម្មភាពបម្រើសេវាកម្មផ្លូវភេទរបស់បុគ្គលពេស្យាមាន ពីរប្រភេទគឺៈ

**ទី ១ ការលួចប្រព្រឹត្តអំពើពេស្យាចារដោយមានការចល័តទីតាំង**

សំដៅដល់ការធ្វើសកម្មភាពរបស់បុគ្គលពេស្យានៅតាមទីសាធារណៈរួមមានដូចជាៈ

- សកម្មភាពដើរទាក់ម៉ូយ ដោយផ្ទាល់នៅតាមដងផ្លូវសារធារណៈ
- ការអង្គុយចាំនៅទីកន្លែងណាមួយ ដើម្បីឱ្យអតិថិជនមកចរចារតម្លៃ រួចស្វែងរកទីតាំងណាមួយដើម្បីរួមភេទ[14]។
- ការប្រើប្រាស់បណ្តាញអ៊ីនធឺណេត ជាមធ្យោបាយក្នុងការប្រព្រឹត្តអំពើពេស្យាចារ

**ទី ២ ការលួចបង្កប់សេវាកម្មបម្រើផ្លូវភេទរបស់បុគ្គលពេស្យាដោយមានទីតាំងត្រឹមត្រូវ**

ដើម្បីធ្វើការបិទបាំង ការប្រព្រឹត្តអំពើពេស្យាចារ ពីការឃាយី ឬ ការអនុវត្តន៍បេសកកម្មចុះបង្រ្កាបរបស់ នគរបាល យើងសង្កេតឃើញថាក្រុមស្ត្រីពេស្យា មួយចំនួន បានលួចបង្កប់នូវសេវាកម្មបម្រើផ្លូវភេទ សម្រាប់បំពេញតម្រូវការឱ្យអតិថិជននៅតាមទីតាំងជាច្រើនដូចជាៈ

- សណ្ឋាគារ
- ផ្ទះសំណាក់
- ក្លឹបខារ៉ាអូខេ
- ហាងផឹកស៊ី
- ទីកន្លែង ម៉ាស្សា កោសជប់ -ល-។

<u>**គួរកត់សម្គាល់ថាៈ**</u> ប្រសិនបើបុគ្គលពេស្យា បានធ្វើសកម្មភាពទាញយកផលប្រយោជន៍ហិរញ្ញវត្ថុពីការប្រព្រឹត្តដោយខ្លួនឯង បុគ្គលពេស្យា នោះពុំមានទោសទេ ប៉ុន្តែកាលបើសកម្មភាពនោះនាំឱ្យបាត់បង់សណ្តាប់ធ្នាប់សាធារណៈ ដូចជាការអូសទាញនូវជនដទៃក្នុងទីសារធារណៈក្នុងគោលដៅប្រព្រឹត្តពេស្យាចារផ្ទាល់ខ្លួន នឹងត្រូវ ផ្តន្ទាទោស ពីបទអំពើអូសទាញ[15]។

---

[13] កថាខណ្ឌទី ១ មាត្រា ២៣ នៃច្បាប់ស្តីពីការបង្រ្កាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ ២០០៨

[14] សូមមើលអង្គហេតុនៅក្នុង សាលក្រមលេខ ០៤ (ង) ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៦ របស់តុលាការខេត្ត សៀមរាប

[15] មាត្រា ២៤ នៃច្បាប់ស្តីពីការបង្រ្កាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ ២០០៨

សូមចំណាំថា ទាក់ទងនឹងច្បាប់ព្រហ្មទណ្ឌណាមួយ ត្រូវតែមានភស្តុតាងនៃចេតនារបស់ជនល្មើសក្នុងការប្រព្រឹត្ត ពេស្យាចារផ្ទាល់ខ្លួន។ ជាទូទៅខាងក្រោមនេះ មិនត្រូវចាត់ទុកថា ជាអំពើអូសទាញ ឬភស្តុតាងនៃចេតនាក្នុងការប្រព្រឹត្តអំពើអូសទាញទេះ

- ការឈររងចាំ ក្នុងទីសាធារណៈ
- ការស្លៀកសំលៀកបំពាក់ ធ្វើឱ្យឃើញ ធ្វើឱ្យស្រើប ឬ ស៊ិចស៊ី
- ការញញឹម ឬ ការបក់ដៃហៅមនុស្ស
- ការមាន ឬ កាន់ស្រោមអនាម័យ ទឹករំអិល ឬ សម្ភារៈផ្សេងទៀត ដែលទាក់ទងនឹងការផ្សព្វផ្សាយ ពីសុវត្ថិភាពផ្លូវភេទ និងការកាត់បន្ថយជម្ងឺហ៊ីវ/អេដស៍
- ការធ្វើការនៅកន្លែងណាមួយ(ដូចជា ប៉ៀហ្គាឌិន ក្លឹបខារ៉ាអូខេ កន្លែងម៉ាស្សា -ល-)។

សូម្បី តែមានករណីដែលមានការប្រព្រឹត្តឡើងនូវអំពើខាងលើ នៅតែមានអង្គហេតុផ្សេងទៀតដែលអាចបម្រើជាភស្តុតាង ដែលជនជាប់ចោទមានចេតនាដោយឆន្ទៈ ក្នុងការប្រព្រឹត្តអំពើពេស្យាចារដោយខ្លួនឯងនៅទីសាធារណៈ[16]។

លើសពីនេះទៅទៀត បើការអូសទាញនោះ ធ្វើឡើងតាមរយៈបុគ្គលពេស្យានៅទីកន្លែងឯកជនជនវិញ មិនត្រូវមានការផ្តន្ទាទោសឡើយ ប៉ុន្តែបើទីកន្លែងឯកជននោះ អាចឱ្យសាធារណៈជនមើលឃើញ ឬ ស្តាប់ឮ ពីសកម្មភាពឈរអូសទាញ បកដៃ ស្រែកហៅ នៅពីខាងក្នុងទ្វានៃទីកន្លែងណាមួយនោះ សកម្មភាពបែបនេះនិងត្រូវផ្តន្ទាទោស។

### ២. ការគ្មានបំណងលក់ ឬផ្តល់ទីកន្លែងឱ្យមេបនប្រកបអាជីវកម្មពេស្យាចារ

នៅក្នុងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ បានចែងដាក់ទោសទៅលើបុគ្គលណាមួយដែលបានផ្តល់ទីកន្លែង តាមរយៈការលក់ ឬ ដាក់ឱ្យបុគ្គលណាម្នាក់ប្រើប្រាស់ទីកន្លែង ដែលមិនមែនប្រើប្រាស់ ដោយសាធារណៈជន ដោយដឹងថាបុគ្គលនោះ នឹងប្រើប្រាស់ទីកន្លែងនោះ សម្រាប់ធ្វើសកម្មភាពពេស្យាចារ ត្រូវផ្តន្ទាទោសពីបទ ការផ្តល់ទីកន្លែងសម្រាប់ធ្វើពេស្យាចារ[17]។

<u>ឧទាហរណ៍:</u> លោក **ក** បានលក់ផ្ទះល្វែងរបស់ខ្លួនទៅឱ្យបុគ្គលម្នាក់ទៀតក្នុងគោលបំណងដើម្បីប្រកបអាជីវកម្មពេស្យាចារ។

---

[16] ទំព័រទី ១០៧ បន្ទាត់ទី ១-១១ នៃសៀវភៅ កំណត់ពន្យល់មាត្រានីមួយៗនៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ បោះពុម្ពលើកទី ២ ឆ្នាំ ២០១៣

[17] មាត្រា ៣២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ ២០០៨

ផ្ទុយទៅវិញ ប្រសិនបើនៅពេលលក់ផ្ទះនោះ អ្នកលក់មិនបានដឹងថាបុគ្គលដែលជាអ្នកទិញជាអ្នកប្រកបអាជីវកម្មពេស្យាចារ ប៉ុន្តែគាត់បានផ្ទេរកម្មសិទ្ធិនៃផ្ទះនោះទៅឱ្យអ្នកទិញរួចជាស្រេចហើយ ក្រោយមកទើបដឹងថា អ្នកទិញ បានយកផ្ទះនោះទៅប្រើប្រាស់សម្រាប់អំពើពេស្យាចារ ក្នុងករណីនេះអ្នកលក់មិនទទួលខុសត្រូវឡើយ ដោយសារតែការលក់នោះក្នុងគោលបំណងមិនមែនដើម្បីឱ្យបុគ្គលណាមួយយកទៅប្រព្រឹត្តអំពើពេស្យាចារឡើយ ម្យ៉ាងវិញទៀត អ្នកលក់លែងជាម្ចាស់កម្មសិទ្ធិលើផ្ទះនោះទៀតហើយ។

ចំពោះការជួលផ្ទះវិញ ប្រសិនបើម្ចាស់ផ្ទះមានចេតនាជួលផ្ទះនោះ ទៅឱ្យបុគ្គលណាមួយប្រព្រឹត្តអំពើពេស្យាចារ ម្ចាស់ផ្ទះនោះនឹងត្រូវទទួលទោសតាមច្បាប់ ដោយសារបុគ្គលដែលជាម្ចាស់ផ្ទះមានឆន្ទៈក្នុងការជួលឱ្យគេ ដើម្បីប្រព្រឹត្តអំពើពេស្យាចារ។ ប៉ុន្តែ ប្រសិនបើការជួលនោះមិនមែនប្រើដើម្បីប្រព្រឹត្តអំពើពេស្យាចារ ទោះបីជាភាគីអ្នកជួលនោះ ជាសញ្ចារិក ឬ សញ្ចារិកា ឬជាបុគ្គលបែបណាក៏ដោយ ម្ចាស់ផ្ទះមិនត្រូវទទួលការផ្តន្ទាទោសឡើយ។

<u>ឧទាហរណ៍:</u> ក្នុងករណីដែល សញ្ចារិក ឬ សញ្ចារិកា បានស្នាក់នៅក្នុងផ្ទះជួល ប៉ុន្តែគាត់មិនបានប្រើប្រាស់ផ្ទះនោះដើម្បី ប្រកបអាជីវកម្មពេស្យាចារទេ ដូច្នេះម្ចាស់ផ្ទះដែលជួលយកកម្រៃមិនទទួលរងការផ្តន្ទាទោសឡើយ។

**៣. ការបម្រើការងារជាបុគ្គលិកឱ្យគ្រឹះស្ថានពេស្យាចារ ដោយមិនមានចេតនាធ្វើឱ្យមានការរីកចម្រើនដល់អាជីវកម្មពេស្យាចារ**

ជាគោលការណ៍ នៅក្នុងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ បានចាត់ទុកថា ការទាញយកអត្ថប្រយោជន៍ហិរញ្ញវត្ថុពីអំពើពេស្យាចាររបស់ជនដទៃ ជាអំពើល្មើសត្រូវទទួលការផ្តន្ទាទោស ប៉ុន្តែក្នុងករណីដែលការទាញយកអត្ថប្រយោជន៍នោះ មិនមានគោលបំណងណាមួយឱ្យជនដទៃប្រព្រឹត្តអំពើពេស្យាចារ ឬ នាំមានការរីកចម្រើនដល់សកម្មភាពពេស្យាចារ ហេតុដូច្នេះបុគ្គលដែលបានទាញយកអត្ថប្រយោជន៍នោះ មិនគួរត្រូវផ្តន្ទាទោសឡើយ។

ជាក់ស្តែងដូចជា បុគ្គលិកដែលបម្រើការងារនៅក្នុងគ្រឹះស្ថានពេស្យាចារ ដោយគាត់មានតួនាទី ជាអ្នកបម្រើការ ចុងភៅ អ្នកអនាម័យ សន្តិសុខយាមឡាន-ម៉ូតូ ឬ អ្នកគិតលុយ ជាដើម។ ដោយសារតែបុគ្គលិកទាំងអស់នោះ ជានិយោជិត ដែលត្រូវបំពេញតារកាលិកឱ្យទៅនិយោជក(មេបន) ដើម្បីទទួលបានប្រាក់ឈ្នួល (អត្ថប្រយោជន៍ហិរញ្ញវត្ថុ) ពីគ្រឹះស្ថានពេស្យាចារនោះ ប៉ុន្តែដោយសារតែបុគ្គលិកទាំងនោះ មិនមានចេតនាឱ្យបុគ្គលពេស្យា នៅក្នុងគ្រឹះស្ថាននោះ ប្រព្រឹត្តពេស្យាចារឡើយ។

ក្នុងករណីនេះតើបុគ្គលិកទាំងនោះគួរតែត្រូវមានការផ្តន្ទាទោសដែរឬទេ? ហើយតាមរយៈសំណួរខាងលើនេះ ប្រសិនបើបុគ្គលិកទាំងអស់នោះត្រូវផ្តន្ទាទោស សួរថាតើការដាក់ទោសនោះយុត្តិធម៌សម្រាប់ពួកគាត់ដែរ ឬយ៉ាងណា?

ដើម្បីឆ្លើយតបទៅនឹងសំណួរខាងលើ យើងត្រូវដឹងថា ការដាក់ទោសទៅលើជនណាមួយបានលុះត្រាតែមានច្បាប់ចែង ហើយការប្រព្រឹត្តរបស់ជននោះត្រូវតែមានចេតនាផង។ ម៉្យាងវិញទៀត បើយោងតាម មាត្រា ៤ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ ចែងថា៖ *ពុំមានបទល្មើសទេ ប្រសិនបើគ្មានចេតនាប្រព្រឹត្ត ប៉ុន្តែក្នុងករណីដែលច្បាប់បានចែងទុកមុន បទល្មើសមួយអាចកើតចេញពីការមិន ប្រុងប្រយ័ត្ន ការខ្ជីខ្ជា ការធ្វេសប្រហែស ឬការមិនគោរពកាតព្វកិច្ចដោយឡែកណាមួយ*[18]។

ក្នុងករណីនេះ បុគ្គលិកដែលបម្រើការងារនៅក្នុងគ្រឹះស្ថានពេស្យាចារ មិនត្រូវមានទោសឡើយ ទោះបីជាបុគ្គលិកនោះបានទាញយកអត្ថប្រយោជន៍ហិរញ្ញវត្ថុ (ប្រាក់ឈ្នួល) ពីទីកន្លែងនោះក៏ដោយ ប៉ុន្តែគាត់មិនមានបំណងឱ្យបុគ្គលពេស្យា ប្រព្រឹត្តអំពើពេស្យាចារទេ។

[18] មាត្រា ៤ ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩

# ជំពូកទី ២

# សញ្ញាណគតិយុត្តនៃអំពើសញ្ចារកម្ម

ជាការពិតណាស់នៅក្នុងសង្គមតែងតែកើតមាននូវអំពើល្មើសជាច្រើន ដែលស្តែងចេញមកពីសកម្មភាពប្រព្រឹត្តរបស់មនុស្ស ជាហេតុនាំឱ្យសង្គមជួបនូវផលវិបាកយ៉ាងធ្ងន់ធ្ងរ ដោយសារតែអំពើទាំងអស់នោះ បានបង្កនូវការអន្តរាយដល់មនុស្ស ហើយព្រមទាំងបង្កឱ្យមានភាព អសន្តិសុខ បាត់បង់សណ្តាប់ធ្នាប់ នៅក្នុងសង្គមផងដែរ។ ជាទូទៅ អំពើល្មើសច្បាប់ទាំងនោះ រួមមានជាអាទិ៍: ការ លួច ឆក់ ប្លន់ អំពើឃាតកម្ម បញ្ហាគ្រឿងញៀន អំពើហិង្សា ការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ -ល-។ ហេតុនេះហើយ ដើម្បីធ្វើការប្រយុទ្ធប្រឆាំងទៅនឹងអំពើទាំងអស់នោះ ទើបត្រូវបានបង្កើតឱ្យមានច្បាប់ព្រហ្មទណ្ឌឡើង ដើម្បីធ្វើការដាក់ទណ្ឌកម្មទៅលើជនទាំងឡាយណាដែលបានប្រព្រឹត្តនូវបទល្មើស។

ទន្ទឹមនឹងនេះ អំពើសញ្ចារកម្ម គឺជាអំពើមួយក្នុងចំណោមអំពើទាំងឡាយ ដែលមានលក្ខណៈបង្កគ្រោះថ្នាក់ដល់មនុស្ស ជាពិសេស ការគាបសង្កត់ បំបិទសិទ្ធិសេរីភាព ការកេងប្រវ័ញ្ចលើមនុស្សជាដើម។ អំពើសញ្ចារកម្មគឺជាអំពើដែលមិនត្រឹមតែធ្វើឱ្យប៉ះពាល់ដល់មនុស្សប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធ្វើឱ្យប៉ះពាល់ដល់សង្គមផងដែរ ពីព្រោះថា កាលបើជនប្រព្រឹត្តសញ្ចារកម្មបានធ្វើអាជីវកម្មពេស្យាចារ នៅតាមទីសាធារណៈ ហេតុនេះនឹងធ្វើឱ្យសង្គម បាត់បង់សណ្តាប់ធ្នាប់ និងធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សថែមទៀត។ បញ្ហាទាំងអស់នេះហើយដែលទាមទារ ឱ្យមានការយកចិត្តទុកដាក់យ៉ាងខ្លាំងពីស្ថាប័នជំនាញ ពាក់ព័ន្ធ ដើម្បីអនុវត្តសមត្ថកិច្ច ក្នុងការចុះទៅបង្ក្រាប និង ទប់សង្កាត់រាល់បទល្មើសទាំងឡាយដែលកើតមាននៅក្នុងសង្គម ដើម្បីធានា ការពារសន្តិសុខ សុវត្ថិភាព ជូនប្រជាពលរដ្ឋ ដោយធ្វើការចាប់ខ្លួនជនដែលប្រព្រឹត្តបទល្មើសទាំងនោះ យកមកផ្តន្ទាទោស ទៅតាមច្បាប់ជាធរមាន ដើម្បី ឱ្យពួកគេមានការ រាងចាលពីទង្វើររបស់ខ្លួន និងឈប់ប្រព្រឹត្តនូវអំពើដែលសង្គមមិនឱ្យតម្លៃតទៅទៀត ហើយកែប្រែខ្លួនទៅជាពលរដ្ឋល្អឡើងវិញ។

អាស្រ័យហេតុនេះហើយ ទើបអត្ថបទស្រាវជ្រាវស្តីពី ប្រធានបទ **អំពើសញ្ចារកម្ម** នឹងធ្វើការបង្ហាញអំពី សញ្ញាណគតិយុត្ត នៃបទល្មើសសញ្ចារកម្ម ដោយធ្វើការកំណត់ជាធាតុផ្សំនៃបទល្មើសជាមុនសិន ដើម្បីអាចឈានទៅដល់ការផ្តន្ទាទោស ចំពោះជនដែលប្រព្រឹត្ត អំពើសញ្ចារកម្ម (ផ្នែកទី ១) និងធ្វើការផ្តន្ទាទោសទៅលើជនដែលដឹកនាំពេស្យាចារ ដឹកនាំគ្រឹះស្ថាន ឬជនដែលផ្តល់ទីកន្លែងសម្រាប់ធ្វើពេស្យាចារ (ផ្នែកទី ២) មកធ្វើការបកស្រាយដោយមានខ្លឹមសារដូចខាងក្រោម:

# ផ្នែកទី ១៖ ធាតុផ្សំ នៃបទល្មើសសញ្ចារកម្ម

## កថាខណ្ឌទី ១៖ ធាតុនីត្យានុកូល

### ១. និយមន័យ

ធាតុនីត្យានុកូល ឬ ធាតុច្បាប់គឺ ជាធាតុដែលសំដៅទៅលើអំពើមួយដែលត្រូវបានបំពារបំពាន ហើយអំពើនោះបានធ្វើឱ្យប៉ះពាល់ទៅដល់សណ្តាប់ធ្នាប់សាធារណៈ និង ប៉ះពាល់ទៅដល់សង្គមជាតិទាំងមូល។ ជាទូទៅ សកម្មភាពទាំងនោះត្រូវបានឆ្លើយតបទៅនឹងច្បាប់ដែលបានចែងអំពីអំពើទាំងនោះត្រូវចាត់ទុកថាមានបទល្មើស ។ ធាតុនីត្យានុកូល មិនអាចចាត់ទុកដូចជាសមាសភាពនៃបទល្មើសនោះទេ ។ ធាតុនីត្យានុកូល គឺជាសំនួនវោហារ៍នៃគោលការណ៍នីត្យានុកូលភាព យោងទៅតាមគោលការណ៍នេះ មិនមានបទល្មើសណាមួយ ត្រូវបានកើតឡើង ដោយគ្មានច្បាប់ចែងនោះទេ ។ វាអាចជាការចោទប្រកាន់ ដែលប្រកាន់យកដោយអ្នកច្បាប់ ដែលយល់ ពីកិច្ចការពារនៃតំលៃសង្គម ដែលចាត់ទុកជាមោទនភាពនៃផលប្រយោជន៍ ។

ដោយយោងទៅតាម ក្រមព្រហ្មណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ បានកំណត់អំពីគោលការណ៍នីត្យានុកូលភាពថាមានតែអំពើដែលបង្កើតជាបទល្មើស នៅពេលដែលអំពើនោះមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ ទើបត្រូវផ្តន្ទាទោសព្រហ្មទណ្ឌបាន ។ មានតែទោសដែលមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមាន នៅពេលដែលបទល្មើសត្រូវបានប្រព្រឹត្តប៉ុណ្ណោះទើបអាចត្រូវប្រកាសបាន[19] ។ យ៉ាងណាមិញ បទសញ្ចារកម្ម ជាបទល្មើសមួយដែលស្ថិតក្នុងចំណោមបទល្មើសជាច្រើនដែលមានកំណត់នៅក្នុងក្រមព្រហ្មណ្ឌថ្មី និង ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

### ២. អត្ថបទច្បាប់

យោងទៅតាមមាត្រា ២៥ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទឆ្នាំ២០០៨ បានអោយនិយមន័យទៅលើអំពើសញ្ចារកម្មគឺជាៈ

១. ការទាញយកអត្ថប្រយោជន៍ហិរញ្ញវត្ថុពីអំពើពេស្យាចាររបស់ជនដទៃ

២. ជួយ ឬការពារអំពើពេស្យាចាររបស់ជនដទៃ

៣. ជ្រើសរើស អូសទាញ ឬ បណ្តុះបណ្តាលបុគ្គលណាមួយឱ្យធ្វើអំពើពេស្យាចារ

៤. ធ្វើការគាបសង្កត់លើបុគ្គលណាមួយ ដើម្បីឱ្យបុគ្គលនោះធ្វើពេស្យាចារ។

**អំពើដូចខាងក្រោមនេះ ត្រូវចាត់ទុកថា ដូចគ្នាទៅនឹងសញ្ចារកម្មៈ**

១. អំពើធ្វើជាអន្តរការី រវាងបុគ្គលដែលធ្វើពេស្យាចារ និងបុគ្គលដែលប្រកបអាជីវកម្ម ឬ ឱ្យលាភការដល់ពេស្យាចារជនដទៃ

[19] មាត្រា ៣ ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩

២. អំពើរបស់ជនណាដែលបានសម្រួល ឬ បិទបាំង នូវធនធាន ដែលខ្លួនបានដឹងថាបានមកពីអំពើសញ្ចារកម្ម

៣. អំពើរារាំងដល់ការបង្ការ ការជួយ ឬ ការអប់រំជាថ្មី ដោយទីភ្នាក់ងារសាធារណៈ ឬ ដោយអង្គការឯកជនដែលមាននីតិសម្បទា ដែលធ្វើឡើងដើម្បីជាគុណប្រយោជន៍ដល់បុគ្គលដែលប្រព្រឹត្តពេស្យាចារ ឬ កំពុងមានគ្រោះដោយការធ្វើពេស្យាចារ។

**កថាខណ្ឌទី ២៖ ធាតុសត្យានុម័ត**

**១. និយមន័យ**

ធាតុសត្យានុម័ត ស្ថិតនៅក្នុងអំពើបង្កអន្តរាយមួយ ចេញពីអាកប្បកិរិយាគួរបន្ទោស ឬ ពីអំពើគួរបន្ទោស។ តែក្រៅពី ការប្រព្រឹត្ត អំពើវិជ្ជមាន ចារីអាចត្រូវទទួលយកជាពិរុទ្ធជន ដោយការខ្វះការប្រុងប្រយ័ត្ន ( ដោយផ្អែកតាមប្រព័ន្ធ Common law ) វាបង្កើតឡើងដោយខ្លួនឯងនូវបទល្មើស[20]។ ធាតុសត្យានុម័តនេះ ស្តែងចេញឱ្យឃើញពីសកម្មភាពរបស់ជនប្រព្រឹត្ត ដែលបានបង្កជាបទល្មើសកើតឡើង ជាពិសេសអំពើបង្កគ្រោះថ្នាក់ដល់សង្គមដែលនាំឱ្យមានព្យាសនកម្មកើតឡើង ហើយអំពើទាំងនោះមានទំនាក់ទំនងគ្នារវាងហេតុ និងផល។ ម្យ៉ាងវិញទៀត ប្រសិនបើអំពើបង្កទាំងនោះ មិននាំឱ្យមានព្យាសនកម្មកើតឡើងទេ ដោយសារតែមានឧបសគ្គ មករាំងស្ទះ នាំឱ្យអំពើល្មើសទាំងនោះត្រូវបានបញ្ឈប់ក្នុងការធ្វើឱ្យបានសម្រេច នៃធាតុសត្យានុម័ត មានន័យថាអំពើល្មើសនោះគឺជាការប៉ុនប៉ងតែប៉ុណ្ណោះ។

**២. សកម្មភាពប្រព្រឹត្ត**

នៅក្នុងបទសញ្ចារកម្ម ជនល្មើសបាន ធ្វើសកម្មភាពតាម មធ្យោបាយផ្សេងៗ រួមមាន ដូចជាការទាញយកផលប្រយោជន៍ហិរញ្ញវត្ថុពីអំពើពេស្យារបស់ជនដទៃ ដោយផ្ទាល់ ឬ ដោយប្រយោលតាមរយៈការ ជួយ ឬ ការពារអំពើពេស្យារបស់ជនដទៃ ឬ ធ្វើសកម្មភាព អូសទាញ ឬ បណ្តុះបណ្តាលទៅលើបុគ្គលណាមួយ ឱ្យ ធ្វើអំពើពេស្យាចារ និង ធ្វើការគាបសង្កត់លើបុគ្គលណាមួយ ដើម្បី ឱ្យបុគ្គលនោះធ្វើពេស្យាចារជាដើម។

**កថាខណ្ឌទី ៣៖ ធាតុអត្តនោម័ត**

**១. និយមន័យ**

ធាតុអត្តនោម័ត គឺជាធាតុផ្សំដ៏សំខាន់នៅក្នុងចំណោមធាតុផ្សំទាំង៣ ពីព្រោះថាធាតុនេះបានបង្ហាញពីឆន្ទៈ ឬ កិរិយាផ្លូវចិត្ត ផ្នែកខាងក្នុងនៃបទល្មើស ចំពោះអំពើដែលបុគ្គលនោះបានប្រព្រឹត្ត និងបច្ច័យដែលបានកើតឡើងពីសកម្មភាពនៃអំពើរបស់បុគ្គលនោះ។

[20] ទំព័រទី ២២ នៃសៀវភៅ នីតិព្រហ្មទណ្ឌទូទៅ របស់ សាស្ត្រាចារ្យ គង់ សាផន បោះពុម្ពលើកទី ១ ឆ្នាំ ២០១៧

**ធាតុអត្តនោម័តនៃបទល្មើសបង្ហាញពីសារៈសំខាន់ ៖**

- កំហុសដោយចេតនា និង អចេតនា
- ការភាន់ច្រឡំលើអង្គហេតុ និងលើអង្គច្បាប់
- ចេតនាទុច្ចរិតទូទៅ និង ទុច្ចរិតដោយ យថាហេតុ
- ទស្សនៈក្រមព្រហ្មទណ្ឌថ្មីរបស់ប្រទេសកម្ពុជាទៅលើ:
  - កំហុសដោយចេតនា។
  - កំហុសក្នុងស្ថានភាពគ្រោះថ្នាក់ដែលបានគិតទុកជាមុនរបស់បុគ្គលដទៃ[21] ។

**២. ចេតនាប្រព្រឹត្ត**

នៅក្នុងករណីនេះ សញ្ចារិក ឬ សញ្ចារិកា មានចេតនាក្នុងការប្រព្រឹត្តបទសញ្ចារកម្ម តាមរយៈការទាញយក អត្ថប្រយោជន៍ហិរញ្ញវត្ថុ ពីអំពើពេស្យាចាររបស់ជនដទៃ ដោយផ្ទាល់ ឬ ការពារអំពើពេស្យារបស់ជនដទៃ ឬ ធ្វើសកម្មភាព អូសទាញ ឬ បណ្តុះបណ្តាលបុគ្គលណាមួយឱ្យ ធ្វើអំពើពេស្យាចារ និង ធ្វើការគាបសង្កត់លើបុគ្គលណាមួយ ដើម្បីអោយបុគ្គលនោះធ្វើពេស្យាចារ។

រាល់សកម្មភាពដូចបានរៀបរាប់ខាងលើ តម្រូវឱ្យជនល្មើស មានឆន្ទៈ ដោយដឹងយ៉ាងច្បាស់ថាអំពើដែលខ្លួនបានប្រព្រឹត្ត ស្តែងចេញ ដោយមានគោលបំណង ធ្វើការទាញយកផលប្រយោជន៍ហិរញ្ញវត្ថុពីអំពើពេស្យាចាររបស់ជនដទៃ។

**កថាខណ្ឌទី ៤៖ ការផ្តន្ទាទោសចំពោះអំពើសញ្ចារកម្ម**

**១. ការផ្តន្ទាទោសទៅលើជនប្រព្រឹត្តសញ្ចារកម្ម**

ជាគោលការណ៍ នៅក្នុងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ បានចែងពីការផ្តន្ទាទោសទៅលើជនណាមួយដែលបានប្រព្រឹត្តអំពើសញ្ចារកម្ម ដោយច្បាប់នេះបានកំណត់ពីនិយមន័យនៅក្នុងមាត្រា ២៥ និងមាត្រា ២៦ ជាបទប្បញ្ញត្តិ សម្រាប់ផ្តន្ទាទោសរីឯ នៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ មាត្រា ២៨៤ បានចែងពីនិយមន័យ និង ការផ្តន្ទាទោសប្រហាក់ប្រហែលគ្នាទៅ នឹងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទផងដែរ។

បទល្មើសសញ្ចារកម្មនេះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ២ (ពីរ) ឆ្នាំ ដល់ ៥ (ប្រាំ) ឆ្នាំ[22]។ យោងតាមក្រមព្រហ្មទណ្ឌ មាត្រា ២៨៤ បានបានបញ្ចូលនូវទោសពិន័យជាប្រាក់បន្ថែមលើទោសដាក់ពន្ធនាគារ ដោយក្រមព្រហ្មទណ្ឌ មាត្រា ៩៧ បានចែងពីការប្រកាសទោស ដែលមានខ្លឹមសារ

[21] ទំព័រទី ១៥៦ នៃសៀវភៅ នីតិព្រហ្មទណ្ឌទូទៅ របស់ សាស្ត្រាចារ្យ គង់ សាផន បោះពុម្ពលើកទី ១ ឆ្នាំ ២០១៧

[22] មាត្រា ២៦ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ ២០០៨

ថា៖ *នៅគ្រប់ករណីដែលបទល្មើសត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារផង និងពិន័យផង តុលាការអាចប្រកាស ទោសដាក់ពន្ធនាគារ និងទោសពិន័យជាមួយគ្នា ឬ ទោសដាក់ពន្ធនាគារតែមួយមុខប៉ុណ្ណោះ ឬ ទោសពិន័យជាប្រាក់តែមួយមុខប៉ុណ្ណោះ*[23]។

ដូច្នេះយោងតាមក្រមព្រហ្មទណ្ឌ តុលាការអាចធ្វើការផ្តន្ទាទោស ចំពោះបទល្មើសសញ្ចារកម្ម ដោយដាក់ទោសមួយណាក៏បានក្នុងចំណោមទោសទាំង បី ខាងលើ។ ប៉ុន្តែ នៅក្នុងក្រមព្រហ្មទណ្ឌ មាត្រា ៩៦ បានចែងពី គោលការណ៍ឯកត្តកម្មនៃទោស ដោយមានខ្លឹមសារថា៖ *តុលាការប្រកាសទោសដោយផ្អែកលើស្ថានទម្ងន់ និង កាលៈទេសៈ នៃបទល្មើសទៅលើបុគ្គលិក លក្ខណៈនៃជនជាប់ចោទ ទៅលើសភាពផ្លូវចិត្ត ទៅលើធនធាននិងបន្ទុក ទៅលើមូលហេតុ ព្រមទាំងទៅលើកិរិយាមាយាទរបស់ជនល្មើស ក្រោយពេលប្រព្រឹត្តបទល្មើស ជាអាទិ៍ ចំពោះជនរងគ្រោះ*[24]។

អាស្រ័យហេតុនេះ ប្រសិនបើបទសញ្ចារកម្មនោះមានសភាពធ្ងន់ធ្ងរ គួរតែត្រូវដាក់ទោសពន្ធនាគារ ជាជាងទោសពិន័យជាប្រាក់ ។ ផ្ទុយទៅវិញ ប្រសិនបើបទសញ្ចារកម្ម ប្រព្រឹត្តឡើងក្នុងបរិបទ នៃទម្រង់ជួញដូរមនុស្ស ការផ្តន្ទាទោសត្រូវធ្វើឡើង តាមរយៈច្បាប់ស្តីពីការបង្រ្កាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ មិនមែនយកក្រមព្រហ្មទណ្ឌមកអនុវត្តទេ ដោយសារតែច្បាប់នេះមានលក្ខណៈពិសេស ហើយមានអត្ថិភាពជាងក្រមព្រហ្មទណ្ឌ ព្រោះថាច្បាប់នេះគ្របដណ្តប់ទៅលើវិស័យជួញដូរមនុស្សទាំងស្រុង។

ទោះបីជាយ៉ាងណាក៏ដោយ ជនល្មើសអាចជាប់ពន្ធនាគារយូរជាងនេះ ប្រសិនបើជននោះបានប្រព្រឹត្តអំពើសញ្ចារកម្ម ដោយមានស្ថានទម្ងន់ទោស ឬ បានប្រព្រឹត្តសញ្ចារកម្ម ទាក់ទងនឹងកុមារ ឬ ប្រព្រឹត្តសញ្ចារកម្មដោយមានការប្រើទារុណកម្ម ជាអាទិ៍។

### ១.១ ស្ថានទម្ងន់ទោសនៃអំពើសញ្ចារកម្ម

ច្បាប់ស្តីពីការបង្រ្កាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ មាត្រា ២៧ បានកំណត់ពីស្ថានទម្ងន់ទោសនៃសញ្ចារកម្ម ដោយបានចែងថា ជនណាប្រព្រឹត្តសញ្ចារកម្មត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ៥ (ប្រាំ) ឆ្នាំ ដល់ ១០ (ដប់) ឆ្នាំ ក្នុងករណីដូចខាងក្រោមនេះ៖

១- កាលបើសញ្ចារិក សញ្ចារិកា ឬ ជនជាមេពេស្យាចារជាបុព្វញាតិ ឬ បច្ឆាញាតិ មានខាន់ស្លា អត់ខាន់ស្លា សាច់បង្កើត ឬ ចិញ្ចឹម របស់បុគ្គលដែលធ្វើពេស្យាចារ។

២- កាលបើសញ្ចារិក សញ្ចារិកា ឬ ជនជាមេពេស្យា រំលោភអំណាច ដែលមុខងាររបស់ខ្លួនផ្តល់ឱ្យទៅលើបុគ្គលដែលធ្វើពេស្យាចារ។

[23] មាត្រា ៩៧ ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩

[24] មាត្រា ៩៦ ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩

៣- កាលបើសញ្ជារិក សញ្ជារិកា ឬ ជនជាមេពេស្យាចារប្រើហិង្សា ឬការបង្ខិតបង្ខំ ចំពោះបុគ្គលដែលធ្វើពេស្យាចារ។

៤- កាលបើសញ្ជារកម្មត្រូវបានប្រព្រឹត្តជាក្រុមមានការចាត់តាំង។

៥- កាលបើសញ្ជារកម្មត្រូវបានប្រព្រឹត្តលើបុគ្គលច្រើននាក់ធ្វើពេស្យាចារ[25]។

ចំណែកឯ ក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ មាត្រា ២៨៨ បានចែងពីស្ថានទម្ងន់ទោសនៃសញ្ជារកម្ម ប្រហាក់ប្រហែលគ្នាទៅនឹង ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទផងដែរ។

លើសពីនេះទៅទៀត ដើម្បីធ្វើការផ្តន្ទាទោសចំពោះជនប្រព្រឹត្តសញ្ជារកម្ម ដែលមានស្ថានទម្ងន់ទោសដូចបានកំណត់ក្នុងមាត្រា ២៧ លុះត្រាតែ ជននោះត្រូវមានទោសដូចបានកំណត់ ក្នុងមាត្រា ២៥ (និយមន័យនៃសញ្ជារកម្ម) ជាមុនសិន និងបានប្រព្រឹត្តអំពើណាមួយដូចបានកំណត់ក្នុងមាត្រា២៧ (ស្ថានទម្ងន់ទោសនៃសញ្ជារកម្ម) ជនដែលប្រព្រឹត្តនោះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ៥ (ប្រាំ) ឆ្នាំ ដល់ ១០ (ដប់) ឆ្នាំ។

**១.១.១. មេពេស្យាជាបុព្វញាតិ ឬ បច្ឆាញាតិរបស់បុគ្គលដែលធ្វើពេស្យាចារ**

ជាគោលការណ៍ ដូចបានកំណត់ក្នុង ចំណុចទី ១ មាត្រា ២៧ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ចែងថា៖ *កាលបើសញ្ជារិក សញ្ជារិកា ឬ ជនជាមេពេស្យាជាបុព្វញាតិ ឬបច្ឆាញាតិ មានខាន់ស្លា អត់ខាន់ស្លា សាច់បង្កើត ឬ ចិញ្ចឹម របស់បុគ្គលដែលធ្វើពេស្យាចារ*[26]។

**បុព្វញាតិ** មានន័យថា: ពួកជនដែលកើតមុនពួកជនមួយទៀត (ឧទាហរណ៍: ឪពុកម្តាយ ជីដូនជីតា ។ល។ ជាបុព្វញាតិរបស់កូន ចៅ ចៅទួត )[27]។

**បច្ឆាញាតិផ្ទាល់** មានន័យថា: ជន ឬពួកជន ដែលកើតពីជនមួយពួកទៀត ( ឧទាហរណ៍: កូនជាបច្ឆាញាតិរបស់ឪពុកម្តាយ។ ចៅជាបច្ឆាញាតិរបស់ជីដូនជីតា)[28]។

ក្នុងករណីនេះជនល្មើសមានទំនាក់ទំនងជាមួយបុគ្គលពេស្យា ដែលអាចជា បុព្វញាតិ ឬជាបច្ឆាញាតិ បានន័យថា ប្រសិនបើ ឪពុកម្តាយ បានយកកូនរបស់ខ្លួន ទោះជាសាច់បង្កើតក្តី ឬសាច់ចិញ្ចឹមក្តី ទៅធ្វើអាជីវកម្មពេស្យាចារ ក្នុងគោលបំណងដើម្បីស្វែងរកប្រាក់កម្រៃ ច្បាប់កំណត់ថាជា

[25] មាត្រា ២៧ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ ២០០៨

[26] ចំណុចទី ១ មាត្រា ២៧ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ ២០០៨

[27] វចនានុក្រមច្បាប់ ខ្មែរ-អង់គ្លេស របស់ ភូ ឡាយស៊ុន- ភូ វួចចេង បោះពុម្ពលើកទី១ ឆ្នាំ ២០១២

[28] សទ្ទានុក្រមផ្នែករដ្ឋប្បវេណី ខ្មែរ-អង់គ្លេស-បារាំងឆ្នាំ ២០០៧

ស្ថានភាពមួយដែលស្ថិតនៅក្នុង ស្ថានទម្ងន់ទោសនៃសញ្ចារកម្ម។ ជាទូទៅនៅក្នុងសង្គមយើង កម្រ ឃើញមានទិដ្ឋភាពបែបនេះកើតឡើងណាស់ ពីព្រោះថា គ្មានបុគ្គលណាមួយ ដែលចង់ឱ្យកូនបង្កើតជាទីស្រលាញ់របស់ខ្លួនទៅធ្វើជាស្រីបន បម្រើឱ្យការសប្បាយ របស់ជនដែលល្មោភកាមតណ្ហានោះទេ ទោះជាគ្រួសារស្ថិតនៅក្នុងស្ថានភាពលំបាកបែបណាក៏ដោយ។ ដោយឡែក នៅក្នុងករណីខ្លះទៀត ដូចជា ការសុំកូន យកទៅធ្វើជាកូនចិញ្ចឹម ក្នុងគោលបំណងទុច្ចរិត មានន័យថា ជនខិលខូច អាចប្រើប្រាស់រូបភាពបែបនេះ ក្នុងការកេងប្រវ័ញ្ច លើកូនចិញ្ចឹម ដោយធ្វើការបណ្ដុះបណ្ដាលឱ្យចេះបម្រើសេវាផ្លូវភេទដល់អតិថិជនជាដើម ដើម្បីទទួលបានកម្រៃពីកូនចិញ្ចឹម។

ទោះបីជាយ៉ាណាក៏ដោយ ប្រសិនបើជនដែលជាមេពេស្យា នោះបានប្រព្រឹត្តទៅលើសាច់ញាតិរបស់ខ្លួនជាអនីតិជនវិញ ជននោះនឹងត្រូវផ្ដន្ទាទោសដោយយោងតាមបញ្ញត្តិនៃមាត្រា ២៨ (សញ្ចារកម្មទាក់ទងនឹងកុមារ) មិនមែនផ្ដន្ទាទោសទៅលើមាត្រា ២៧ (ស្ថានទម្ងន់ទោសនៃសញ្ចារកម្ម)ទេ។

### ១.១.២. មេពេស្យារំលោភអំណាច ដែលមុខងាររបស់ខ្លួនផ្ដល់ឱ្យនៅលើបុគ្គលដែលធ្វើពេស្យាចារ

សំដៅលើជនល្មើសបានបំពានអំណាចរបស់ខ្លួនក្នុងការប្រព្រឹត្តអំពើសញ្ចារកម្ម។ មានន័យថា ប្រសិនបើមន្ត្រីរាជការសាធារណៈបានប្រើអំណាចរបស់ខ្លួនក្នុងការប្រព្រឹត្តអំពើសញ្ចារកម្ម តាមរយៈការប្រកបអាជីវកម្មពេស្យាចារ ឬ ការទាញយកអត្ថប្រយោជន៍ហិរញ្ញវត្ថុពីអំពើពេស្យាចាររបស់ជនដទៃ ហេតុដូចនេះមន្ត្រីរាជការនោះកំពុងតែប្រព្រឹត្តអំពើសញ្ចារកម្មដោយមានស្ថានទម្ងន់ទោសស្ថិតក្នុងចំណុចទី ២ នៃមាត្រា ២៧ នៃច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

ជាការពិតណាស់ ការប្រើសិទ្ធិអំណាចក្នុងនាមជាមន្ត្រីរាជការសាធារណៈ ទៅប្រព្រឹត្តអំពើខុសច្បាប់បែបនេះ នាំឱ្យខូចក្រមសីលធម៌របស់មន្ត្រីរាជការ និងជាបញ្ហាធំបំផុត សម្រាប់ប្រជារាស្ត្រព្រមទាំងសង្គមជាតិទាំងមូលផងដែរ។ ករណីបែបនេះ អាចឱ្យយើងយល់បានថា ប្រសិនបើការប្រកបអាជីវកម្មផ្លូវភេទ ដែលធ្វើឡើងដោយមាន ខ្នងបង្អែកធំ ឬ នៅពីក្រោយការប្រកបអាជីវកម្មនោះ មានការគាំទ្រពីសំណាក់មន្ត្រីដែលមានបុណ្យស័ក្តិខ្ពង់ខ្ពស់ មានអំណាច និងធ្វើឱ្យអាជីវកម្មកាន់តែរឹងមាំថែមទៀត សូម្បីតែសមត្ថកិច្ចដែលចុះទៅធ្វើការបង្ក្រាប ក៏ញញើត ខ្លាច ស្ទើរតែមិនហ៊ានអនុវត្តមុខងាររបស់ខ្លួនផងដែរ ដោយសារតែខ្លាចបាត់បង់តួនាទី និងមុខតំណែងរបស់ខ្លួន។ កន្លងទៅករណីបែបនេះធ្លាប់បានកើតមានឡើងនៅក្នុងសង្គមខ្មែរយើងផងដែរ ដោយហេតុថា មាន

ខ្លួង លោកនេះ ខ្លួងលោកនោះ ជាអ្នកបើកអាជីវកម្មរកស៊ីដោយផ្ទាល់។ ដូច្នេះហើយ រាជរដ្ឋាភិបាលត្រូវតែ គិតគូរឡើងវិញអំពីបញ្ហានេះ និងមិនត្រូវឱ្យកើតមានអំពើបែបនេះនៅក្នុងសង្គមឡើយ។

### ១.១.៣. មេពេស្យាប្រើហិង្សា ឬ ការបង្ខិតបង្ខំ ចំពោះបុគ្គលដែលធ្វើពេស្យាចារ

ជាគោលការណ៍ ចំពោះការប្រើប្រាស់អំពើហិង្សា ឬ ការបង្ខិតបង្ខំដោយមេពេស្យាទៅលើបុគ្គលពេស្យា ត្រូវបានចាត់ទុកជាស្ថានទម្ងន់ទោសមួយផងដែរនៃសញ្ជារកម្ម។

ឧទាហរណ៍: មេបន បានប្រើប្រាស់អំពើហិង្សា ដោយការវាយដំ និង គំរាមកំហែងទៅលើបុគ្គលពេស្យា ដោយហេតុមកពីបុគ្គលពេស្យា នោះ ពុំព្រមបម្រើភ្ញៀវតាមការបង្គាប់បញ្ជា របស់ខ្លួននៅក្នុងផ្ទះបន។

តាមរយៈការបកស្រាយខាងលើ យើងអាចធ្វើការពន្យល់នូវពាក្យមួយចំនួនដែលរួមមាន " អំពើហិង្សា " និង " ការបង្ខិតបង្ខំ " ដូចខាងក្រោម៖

**អំពើហិង្សា** មានន័យថា: ការប្រើប្រាស់កម្លាំងរាងកាយដើម្បីបណ្តាលឱ្យស្លាប់ ឈឺចាប់ ឬរបួសរូបកាយ មិនថារយ:ពេលវែង ឬ រយ:ពេលខ្លី (ដែលរួមមាន ការរំលោភសេពសន្ថវ: និងទម្រង់ផ្សេងទៀតនៃការឈ្លានពានផ្លូវភេទ ឬការប្រើប្រាស់ថ្នាំញៀនដោយបង្ខំទៅលើជនរងគ្រោះ) -ល- ។ ព្រមទាំងបំពារបំពានទៅលើផ្នែកស្មារតីផងដែរ។ អំពើហិង្សាក្នុងន័យនេះ គឺជាអំពើដែលធ្វើឡើងប្រឆាំងនឹងរូបរាងកាយ សុខភាព ឬ ផ្លូវចិត្តរបស់ជនណាម្នាក់។

**ការបង្ខិតបង្ខំ** មានន័យថា: ជាការប្រើប្រាស់កម្លាំង ឬ ការប្រើប្រាស់ការគំរាមកំហែងដោយផ្ទាល់ ឬ ដោយប្រយោល ដែលរួមមានទម្រង់ខ្លះៗ នៃការប្រើប្រាស់កម្លាំង ឬ ការគំរាមកំហែងដោយអហិង្សា ឬ ចិត្តសាស្ត្រ។ ទាំងនេះរួមមានដូចជា៖

ក) ការប្រើប្រាស់កម្លាំង ឬ ការគំរាមកំហែងបង្កឱ្យមានគ្រោះថ្នាក់ (រួមមានបណ្តាលឱ្យស្លាប់ រងរបួសរូបកាយ ឬ រំលោភសេពសន្ថវ: និង ការឈ្លានពានផ្លូវភេទ) ឬ បង្ខាំងរូបកាយដល់ជនណាម្នាក់។

ខ) គ្រោងការណ៍ ផែនការ ឬ គំរូ ដែលមានចេតនាបណ្តាលឱ្យជនណាម្នាក់ជឿថា ការខកខានមិនបានប្រព្រឹត្តអំពើណាមួយ នឹងនាំឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ឬ បង្ខាំងរូបកាយដល់ជនណាម្នាក់។

គ) ការបំពាន ឬ ការគំរាមកំហែងណាមួយ ដែលជាប់ទាក់ទងនឹង ឋាន:នៃជនណាម្នាក់

ឃ) ការគាបសង្កត់ផ្លូវចិត្ត ដែលរួមមានបណ្តាលឱ្យជនណាម្នាក់ជឿថា គាត់ ឬ បុគ្គលផ្សេងទៀត នឹងត្រូវគេនាំចេញទៅ លក់ ឬ បង្ខាំងដោយខុសច្បាប់។

ការបង្ខិតបង្ខំក្នុងន័យនេះ គឺជាអំពើដែលធ្វើឡើងប្រឆាំងនឹងជនម្នាក់ផ្សេងទៀត ដើម្បីឱ្យជននោះមិនអាចបញ្ចេញឆន្ទៈដោយសេរីរបស់ខ្លួនបាន[29]។

### ១.១.៤. កាលបើសញ្ចារកម្មត្រូវបានប្រព្រឹត្តជាក្រុមមានការចាត់តាំង

ក្នុងករណីដែលអំពើសញ្ចារកម្មត្រូវបានប្រព្រឹត្តឡើងដោយក្រុមមានការចាត់តាំង មានន័យថាអំពើនោះគឺស្ថិតនៅក្នុងផ្នែកស្ថានទម្ងន់ទោស ដែលបានកំណត់នៅ ក្នុងមាត្រា ២៧ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

**ក្រុមមានការចាត់តាំង** មានន័យថា: គឺជាការប្រមូលផ្តុំដែលបានបង្កើតឡើង ឬ ជាសន្និដ្ឋិភាពដែលបានធ្វើឡើង ដើម្បីត្រៀមរៀបចំ ឬ ប្រព្រឹត្តបទល្មើសមួយ ឬ ច្រើន[30]។ យោងតាមអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីឧក្រិដ្ឋកម្មឆ្លងដែនដែលភ្ជាប់នឹងពិធីសារប៉ាឡឺម៉ូ ហើយដែលប្រទេសកម្ពុជាបានឱ្យសច្ចាប័ន បានឱ្យនិយមន័យថា ក្រុមឧក្រិដ្ឋកម្មមានការចាត់តាំង គឺជាក្រុមដែលមានរចនាសម្ព័ន្ធ ដែលមានគ្នា ពី ៣នាក់ ឬច្រើននាក់ជាងនេះ ដែលកើតមានឡើងសម្រាប់រយៈពេលមួយ និងធ្វើសកម្មភាពរួមគ្នា ដោយមានគោលបំណង បទឧក្រិដ្ឋ ឬ ប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរ មួយ ឬ ច្រើនដែលធ្វើឡើងស្របទៅនឹងអនុសញ្ញានេះ ដើម្បីទទួលដោយផ្ទាល់ ឬប្រយោលនូវផលប្រយោជន៍ហិរញ្ញវត្ថុ ឬសម្ភារៈផ្សេងទៀត។

ក្នុងករណីនេះ ការប្រកបអាជីវកម្មពេស្យាចារ ត្រូវបានប្រព្រឹត្តឡើងដោយមានបុគ្គលជាមេពេស្យា មានគ្នាច្រើននាក់ នឹងបានរួបរួមគ្នាជាប្រព័ន្ធ ដើម្បីសម្រួលដល់កាធ្វើអាជីវកម្មពេស្យាចារឱ្យមានការរីកចម្រើនឡើង ជាពិសេស ដើម្បីងាយស្រួលក្នុងការគេចផុតពីការ យាយីរបស់នគរបាល នៅពេលដែលចុះទៅធ្វើការបង្ក្រាប ពីព្រោះថាការប្រព្រឹត្តដោយមានក្រុមចាត់តាំងបែបនេះ ប្រៀបដូចជាការរៀបចំគម្រោងទុកជាមុន ដើម្បីការពារសុវត្ថិភាព ក្នុងករណីដែលមានសកម្មភាពបង្ក្រាបកើតឡើង។ បញ្ហានេះជាការលំបាកមួយ សម្រាប់សមត្ថកិច្ចក្នុងការចុះទៅអនុវត្តតួនាទីរបស់ខ្លួន ដូច្នេះត្រូវទាមទារឱ្យមានការស្រាវជ្រាវ និង ស្វែងរកភស្តុតាងអំពីបទល្មើសយ៉ាងម៉ត់ចត់បំផុត ដើម្បីចាប់ជនល្មើសមកធ្វើការផ្តន្ទាទោសតាមច្បាប់។

### ១.១.៥. កាលបើសញ្ចារកម្មត្រូវបានប្រព្រឹត្តលើបុគ្គលច្រើននាក់ធ្វើពេស្យាចារ

ត្រូវបានចាត់ទុកជាស្ថានទម្ងន់ទោសនៃសញ្ចារកម្មផងដែរ ប្រសិនបើសញ្ចារកម្មត្រូវបានប្រព្រឹត្តលើបុគ្គលច្រើននាក់ធ្វើពេស្យាចារ។ មានន័យថា មេពេស្យា បានធ្វើអាជីវកម្មលើបុគ្គល

[29] ទំព័រទី ១២១-១២២ នៃសៀវភៅ កំណត់ពន្យល់មាត្រានីមួយៗនៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ បោះពុម្ពលើកទី ២ ឆ្នាំ ២០១៣

[30] មាត្រា ៧៧ ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៩

ពេស្យាដោយមានគ្នាច្រើននាក់ ព្រមទាំងឱ្យបុគ្គលទាំងនោះ បម្រើសេវាផ្លូវភេទដល់អតិថិជន ក្នុងគោលដៅបានទទួលប្រាក់ចំណេញច្រើនពីអំពើពេស្យាចារ។ ជារឿយៗ ការប្រកបអាជីវកម្មបែបនេះទាមទារឱ្យមានបុគ្គលពេស្យាច្រើននាក់ទើបអាចបំពេញតម្រូវការឱ្យអតិថិជនបាន ការលើកឡើងបែបនេះមិនមែនចង់មានន័យថា ជាអាជីវកម្មដែលអាចទាក់ទាញអតិថិជនបានច្រើននោះទេ ប៉ុន្តែការទាមទារ ឱ្យមានបុគ្គលពេស្យាច្រើនបែបនេះ គឺ ដើម្បីជាជម្រើសសម្រាប់ឱ្យភ្ញៀវជ្រើសរើស។ ហេតុនេះហើយ ការប្រកបអាជីវកម្មពេស្យាចារ គេកម្រ ឃើញមានបុគ្គលដែលបម្រើផ្លូវភេទតិចណាស់នៅក្នុងផ្ទះបន ពោលគឺចាប់ពី ៥នាក់ឡើងទៅ ឬ តិចជាងនេះប្រសិនបើមេបនបានលួចលាក់បង្កប់សេវាផ្លូវភេទនូវទីកន្លែងតូចតាច ដូចជាកន្លែងម៉ាស្សា-កោសជប់ ជាដើម។

ក្នុងករណីនេះ ការចោទប្រកាន់ទៅលើជនល្មើស ដែលប្រព្រឹត្តសញ្ចារកម្មដោយមានស្ថានទម្ងន់ទោស ពាក់ព័ន្ធ នឹងការទាញយកអត្ថប្រយោជន៍ហិរញ្ញវត្ថុ ពីអំពើពេស្យាចាររបស់ជនដទៃដោយច្រើននាក់ មិនចាំបាច់ធ្វើការចោទប្រកាន់ច្រើន ដូចបទល្មើសត្រួតគ្នានោះទេ។ យោងតាមមាត្រា ២៧ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ អាចធ្វើការចោទប្រកាន់តែម្តង ប្រសិនបើជនប្រព្រឹត្តត្រូវបានគេរកឃើញថាមានទោស។

### ១.២. សញ្ចារកម្មទាក់ទងនឹងពេស្យាចារកុមារ

#### ១.២.១. និយមន័យ

**សញ្ចារកម្មទាក់ទងទៅនឹងកុមារ** មានន័យថា: គឺ ជាអំពើ ឬ សកម្មភាពទាំងឡាយណា ដែលត្រូវបានកំណត់នៅក្នុង មាត្រា ២៥ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និង មាត្រា ២៨៤ នៃ ក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩ ហើយ សញ្ចារិក សញ្ចារិកា ឬ បុគ្គលដែលជនជាមេពេស្យា បានប្រព្រឹត្តសញ្ចារកម្មទៅលើបុគ្គលពេស្យា ជា **អនីតិជន**។

**អនីតិជន** មានន័យថា: ជាជនដែលមានអាយុក្រោម ១៨ ឆ្នាំ។ ជនណាដែលបានរក្សាទុកអនីតិជន ឱ្យស្ថិតនៅក្រោមការគ្រប់គ្រង ឬ ត្រួតពិនិត្យរបស់ខ្លួននឹងត្រូវចាត់ទុកថា បាន ដឹងពីអាយុរបស់អនីតិជននោះ លើកលែងតែជននោះបង្ហាញឃើញថា ខ្លួនមានការជឿជាក់ដោយសមហេតុផលថា អនីតិជននោះ មានអាយុ ១៨ ឆ្នាំ ឬច្រើនជាង ១៨ ឆ្នាំ[31]។

**ពេស្យាកម្មកុមារ** មានន័យថា: គឺជាការប្រើប្រាស់កុមារក្នុងសកម្មភាពផ្លូវភេទ បំណងយកម្រៃ ឬអត្ថប្រយោជន៍តាមទម្រង់ផ្សេងៗ[32]។

---

[31] មាត្រា ៧ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ ២០០៨

[32] មាត្រា ២ (ខ) នៃពិធីសារជាប់នឹងអនុសញ្ញាស្តីពីសិទ្ធិកុមារពាក់ព័ន្ធនឹងការលក់កុមារ ពេស្យាកម្មកុមារ និងកាមសាស្ត្រកុមារ ឆ្នាំ ២០០២

ទោះបីជាយ៉ាងណាក៏ដោយ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ បានផ្តល់ឱ្យអនីតិជននូវសមត្ថភាពក្នុងការរួមភេទ ចាប់ពី អាយុ ១៥ ឡើងទៅ។ ប៉ុន្តែមិនមែនមានន័យថា ច្បាប់ផ្តល់ឱ្យអនីតិជនក្នុងការប្រព្រឹត្តអំពើពេស្យាចារឡើយ។ ម្យ៉ាងវិញទៀត សូម្បីតែនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាយើង ក៏បានចែងហាមឃាត់ចំពោះការធ្វើអាជីវកម្មទៅលើកុមារ ដោយស្របទៅតាមអនុសញ្ញាស្តីពីសិទ្ធិកុមារផងដែរ[33]។ ដូច្នេះហើយប្រសិនបើបុគ្គលជាមេពេស្យា បានដឹកនាំធ្វើអាជីវកម្មផ្លូវភេទលើកុមារ ដើម្បីកេងប្រវ័ញ្ចលើកុមារ ជននោះនឹងត្រូវទទួលការផ្តន្ទាទោសដោយស្របទៅតាមច្បាប់ជាធរមាន។

**១.២.២. ការកំណត់អំពីទោស**

ជាគោលការណ៍ ដូចបានកំណត់នៅក្នុង មាត្រា ២៨ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ រួមទាំង ក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩ មាត្រា ២៨៩ ដោយបានធ្វើការផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ដល់ ១៥ (ដប់ប្រាំ) ឆ្នាំ ទៅលើជនណាមួយ ដែលប្រព្រឹត្តអំពើសញ្ជារកម្មទាក់ទងនឹងពេស្យាចារកុមារ។

ដូច្នេះ ដើម្បីធ្វើការផ្តន្ទាទោសទៅលើជនល្មើសបាន លុះត្រា ជនល្មើសនោះមានទោសពីបទសញ្ជារកម្ម ដូចបានកំណត់ក្នុងនិយមន័យ នៃមាត្រា ២៥ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងក្រមព្រហ្មទណ្ឌ មាត្រា ២៨៤ ហើយបានប្រព្រឹត្តទៅលើបុគ្គលពេស្យា ជា**អនីតិជន**។

**១.៣. សញ្ជារកម្មដោយមានការធ្វើទារុណកម្ម**

**១.៣១. និយមន័យ**

**សញ្ជារកម្មដោយមានការធ្វើទារុណកម្ម** មានន័យថា: អំពើដែលធ្វើឱ្យមានការឈឺចាប់ រងទុក្ខវេទនា ដោយការដាក់ទណ្ឌកម្ម ឬ ទារុណកម្មយ៉ាងសាហាវព្រៃផ្សៃ ទៅលើបុគ្គលដែលជាជនពេស្យា។

**ទារុណកម្ម** មានន័យថា: អំពើទាំងឡាយណាដែលនាំឱ្យមានការឈឺចាប់ ឬរងទុក្ខយ៉ាងខ្លាំង ទោះផ្លូវកាយ ឬ ផ្លូវចិត្តក្តី ដែលត្រូវបានបង្កឡើងដោយចេតនាលើជនម្នាក់ទៀត ក្នុងគោលបំណងទាំងឡាយដូចជា ទាញយកពត៌មានពីជននោះ ឬ តតិយជនណាម្នាក់ ដាក់ទណ្ឌកម្មជននោះចំពោះអំពើណាមួយ ដែលជននោះ ឬតតិយជនណាម្នាក់ បានប្រព្រឹត្ត ឬសង្ស័យថាបានប្រព្រឹត្ត ឬបំភិតបំភ័យ ឬបង្ខិតបង្ខំជននោះ ឬតតិយជនណាម្នាក់ ឬដើម្បីមូលហេតុផ្សេងទៀតដោយផ្អែកទៅលើការរើសអើងណាមួយ [...][34]។

[33] មាត្រា ៤៨ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

[34] មាត្រា ១ អនុសញ្ញាអន្តរជាតិ ស្តីពី ការប្រឆាំងនឹងការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ចូលជាធរមាននៅថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៨៧

**អំពើឃោរឃៅ** មានន័យថា: អំពើបៀតបៀនធ្វើទុក្ខបុកម្នេញ លើរូបរាងកាយមនុស្ស។ អំពើឃោរឃៅនេះមានន័យប្រហាក់ប្រហែលនឹងទារុណកម្មដែរ។

ក្នុងករណីនេះ បុគ្គលពេស្យា បានទទួលរងនូវការធ្វើទារុណកម្មយ៉ាងព្រៃផ្សៃ ពីសំណាក់មេពេស្យា ហើយការធ្វើទារុណកម្មនោះនាំឱ្យមានការឈឺចាប់ និងរងទុក្ខវេទនាយ៉ាងខ្លាំង ដូចបានកំណត់នៅក្នុងមាត្រា ១ នៃអនុសញ្ញាអន្តរជាតិ ស្តីពីការប្រឆាំងនឹងការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាបជាដើម។ នៅក្នុងអនុសញ្ញាអន្តរជាតិនេះ មិនបានកំណត់ថា តើរូបភាពបែបណា? និង សកម្មភាពបែបណាខ្លះ? ទើបអាចចាត់ទុកថាជាការធ្វើទារុណកម្មឡើយ ដោយគ្រាន់តែបញ្ជាក់ថា៖ *អំពើទាំងឡាយណាដែលនាំឱ្យមានការឈឺចាប់ ឬរងទុក្ខយ៉ាងខ្លាំង ទោះផ្លូវកាយ ឬផ្លូវចិត្ត ដែលត្រូវបង្កឡើងដោយចេតនាទៅលើជនម្នាក់ទៀត[...]*។ ដូច្នេះការចែងបែបនេះ ដែលពេលខ្លះអាចធ្វើឱ្យយើងមានការភាន់ច្រឡំបន្តិច រវាង ការធ្វើទារុណកម្ម និងអំពើហិង្សា ពីព្រោះថាអំពើហិង្សា អាចនាំឱ្យមានការស្លាប់ ការឈឺចាប់ ការរបួស ទាំងផ្លូវកាយ និងផ្លូវចិត្ត មិនថារយៈពេលវែង ឬខ្លីនោះទេ ចំណែកឯការធ្វើទារុណកម្មវិញ មានលក្ខណៈប្រហាក់ប្រហែល និងអំពើហិង្សាដែរ ប៉ុន្តែធ្ងន់ធ្ងរជាងអំពើហិង្សា។

<u>ឧទាហរណ៍:</u> មេពេស្យា បានចងបុគ្គលពេស្យា ជាប់នឹងជញ្ជាំង រួចយកកាំបិតមុតស្រួច ទៅកាត់ម្រាមដៃ និងម្រាមជើងរបស់បុគ្គលពេស្យា។ ដូច្នេះទង្វើសាហាវព្រៃផ្សៃបែបនេះមិនអាចចាត់ទុកជាអំពើហិង្សាឡើយ។

### ១.៣.២. ធាតុផ្សំនៃការធ្វើទារុណកម្ម

ដើម្បីធ្វើការកំណត់អំពីធាតុផ្សំ នៃការធ្វើទារុណកម្មតាមរយៈ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទបានលុះត្រាតែ:

- ការធ្វើទារុណកម្មនោះបណ្តាលឱ្យជនរងគ្រោះ រងទុក្ខវេទនា ឈឺចុកចាប់ ដល់ ផ្លូវកាយ ឬ ផ្លូវចិត្ត។
- ជនល្មើសត្រូវបានដឹងយ៉ាងច្បាស់ពីការធ្វើទារុណកម្ម និង មានចេតនាធ្វើឱ្យបុគ្គលណាមួយឈឺចាប់។

### ១.៣.៣. ការកំណត់អំពីទោស

យោងតាមមាត្រា ២៩ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ បានចែងថា សញ្ចារកម្ម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ១០ (ដប់) ឆ្នាំ ដល់ ២០ (ម្ភៃ) ឆ្នាំ កាលបើសញ្ចារិក សញ្ចារិកា ឬ មេពេស្យាចារបានប្រើប្រាស់ទារុណកម្ម ឬ អំពើឃោរឃៅចំពោះបុគ្គលដែលធ្វើពេស្យាចារ[35]។

[35] មាត្រា ២៩ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ ២០០៨

**ផ្នែកទី ២៖ ការផ្តន្ទាទោសទៅលើជនដែលដឹកនាំពេស្យាចារ ដឹកនាំគ្រឹះស្ថាន និងផ្តល់ទីកន្លែងសម្រាប់ធ្វើពេស្យាចារ**

ក្រោយពីបានធ្វើការសិក្សាទៅលើករណី ផ្តន្ទាទោសចំពោះជនដែលបាន ប្រព្រឹត្តសញ្ចារកម្មរួចមក នៅក្នុងច្បាប់ស្តីពីការបង្រ្កាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ រួមទាំងក្រមព្រហ្មទណ្ឌ ក៏បានបញ្ញត្តិដាក់ទោសទៅលើជនណា ដែលបានធ្វើការដឹកនាំពេស្យាចារ (កថាខណ្ឌទី ១) ឬដឹកនាំគ្រឹះស្ថានពេស្យាចារ(កថាខណ្ឌទី ២) និង ជនដែលបានផ្តល់ទីកន្លែងសម្រាប់ធ្វើពេស្យាចារ (កថាខណ្ឌទី ៣) ផងដែរ។

**កថាខណ្ឌទី ១៖ ការដឹកនាំពេស្យាចារ**

ជនណាដឹកនាំ ធ្វើអាជីវកម្ម ធ្វើប្រតិបត្តិការ ឬចេញប្រាក់ឱ្យគ្រឹះស្ថាន ដោយផ្ទាល់ ឬតាមរយៈអន្តរការី ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ២ (ពីរ) ឆ្នាំ ដល់ ៥ (ប្រាំ) ឆ្នាំ[36]។

**១. ការដឹកនាំ**

ចំពោះការដឹកនាំពេស្យាចារ សំដៅដល់ ការមានសិទ្ធិអំណាច នៅក្នុងការអនុវត្តន៍ការគ្រប់គ្រងទៅលើគ្រឹះស្ថានពេស្យាចារតែម្តង។ មានន័យថា បុគ្គលដែលធ្វើការដឹកនាំ អាចនិយាយបានថាជាម្ចាស់នៃគ្រឹះស្ថានពេស្យាចារ ឬជាបុគ្គលដែលមានសិទ្ធិអំណាចចំពោះគ្រឹះស្ថានដែលបានធ្វើការដឹកនាំនោះ ទោះដោយផ្ទាល់ ឬតាមរយៈអន្តរការីក៏ដោយ។ ហើយការដឹកនាំនោះនាំឱ្យមានសកម្មភាពប្រព្រឹត្តអំពើពេស្យាចារកើតឡើង នៅក្នុងគ្រឹះស្ថាន។

<u>ឧទាហរណ៍:</u> ទី១ មេបន បានធ្វើការគ្រប់គ្រង ទៅលើផ្ទះបនដែលជាទីតាំងប្រកបអាជីវកម្មពេស្យាចារ។

<u>ឧទាហរណ៍:</u> ទី២ ក្នុងករណីដែល លោក **ក** ជាមេបន បានសុំឱ្យឈ្មោះ **ខ** ដែលជាជំនួយការរបស់ខ្លួនធ្វើការដឹកនាំ និង គ្រប់គ្រងផ្ទះ បន។ ហេតុនេះ **ក** និង **ខ** មានទំនាក់ទំនង នឹងការដឹកនាំគ្រឹះស្ថានពេស្យាចារ។

ដូច្នេះ ប្រសិនបើមានបុគ្គលណាមួយបានធ្វើការដឹកនាំគ្រឹះស្ថានពេស្យាចារ ឬបានគ្រប់គ្រងគ្រឹះស្ថាននេះដោយផ្ទាល់ ឬតាមរយៈអន្តរការី នឹងត្រូវធ្វើការផ្តន្ទាទោស ដាក់ពន្ធនាគារពី ២(ពីរ) ឆ្នាំដល់ ៥ (ប្រាំ)ឆ្នាំ ដោយស្របទៅតាមច្បាប់ស្តីពីការបង្រ្កាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

**២. ការធ្វើអាជីវកម្ម**

ការធ្វើអាជីវកម្ម សំដៅដល់ការប្រកបមុខរបរណាមួយ ក្នុងគោលបំណង ដើម្បីទទួលបានអត្ថប្រយោជន៍ពីមុខរបរនោះ។ ការប្រកបអាជីវកម្មនៅត្រង់នេះ មានន័យថាការធ្វើអាជីវកម្មពេស្យាចារ ដែលត្រូវបានដឹកនាំដោយ សញ្ចារិក សញ្ចារិកា ឬ ជនជាមេពេស្យា ។

[36] មាត្រា ៣០ នៃច្បាប់ស្តីពីការបង្រ្កាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ ២០០៨

ដូច្នេះ ប្រសិនបើមានបុគ្គលណាមួយបានធ្វើអាជីវកម្មពេស្យាចារនៅក្នុង គ្រឹះស្ថានពេស្យាចារ ក្នុងគោលបំណងដើម្បីទាញយកអត្ថប្រយោជន៍ពីអាជីវកម្មនោះ ទោះធ្វើដោយផ្ទាល់ ឬតាមរយៈអន្តរការី នឹងត្រូវធ្វើការផ្តន្ទាទោស ដាក់ពន្ធនាគារពី ២(ពីរ) ឆ្នាំ ដល់ ៥ (ប្រាំ)ឆ្នាំ ដោយស្របទៅតាមច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

**៣. ការប្រតិបត្តិការ**

ចំពោះការធ្វើប្រតិបត្តិការ នៅត្រង់នេះមានន័យថា ជាការធ្វើឱ្យអាជីវកម្មពេស្យាចារ មានការរីកចម្រើនតាមរយៈការថែរក្សាគ្រឹះស្ថានពេស្យាចារ និងធ្វើសកម្មភាពផ្សេងៗទៀត ក្នុងនាមជាម្ចាស់គ្រឹះស្ថាន ដែលទទួលផលប្រយោជន៍ពីគ្រឹះស្ថាននោះ។ ហេតុដូចច្នេះហើយ ប្រសិនបើមានជនណាមួយបានធ្វើឱ្យមានការរីកចម្រើនដល់ គ្រឹះស្ថានពេស្យាចារ ជននោះ នឹងត្រូវធ្វើការផ្តន្ទាទោស ដាក់ពន្ធនាគារពី ២(ពីរ) ឆ្នាំ ដល់ ៥ (ប្រាំ)ឆ្នាំ ដោយស្របទៅតាមច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

**៤. ការចេញប្រាក់**

ការចេញប្រាក់ នៅក្នុងចំណុចនេះ សំដៅដល់ជនទាំងឡាយណា ដែលបានឧបត្ថម្ភ ឬបានសម្រួលដោយការផ្គត់ផ្គង់ប្រាក់ ឬធនធានផ្សេងៗដល់គ្រឹះស្ថានពេស្យាចារ ដើម្បីឱ្យគ្រឹះស្ថាននោះអាចដំណើរការទៅបាន។ ក្នុងករណីនេះជនដែលបានចេញប្រាក់ ដើម្បីឱ្យមានការប្រតិបត្តិការលើគ្រឹះស្ថាននោះក៏ត្រូវបានផ្តន្ទាទោសផងដែរ។

<u>ឧទាហរណ៍:</u> លោក **ក** បានចំណាយប្រាក់របស់ខ្លួន ៥០០០ ដុល្លារ ដល់ផ្ទះបន ដើម្បីឱ្យមេបន ធ្វើការចាត់ចែង និងរៀបចំ ដំណើរការអាជីវកម្មពេស្យាចារ។

ដូច្នេះ ក្នុងករណីដែលមានបុគ្គលណាមួយបានធ្វើការចេញប្រាក់ ឬការផ្គត់ផ្គង់ផ្សេងៗ ដល់គ្រឹះស្ថានពេស្យាចារ ដើម្បីឱ្យគ្រឹះស្ថាននោះមានការរីកចម្រើន នឹងត្រូវធ្វើការផ្តន្ទាទោស ដាក់ពន្ធនាគារពី ២(ពីរ) ឆ្នាំ ដល់ ៥ (ប្រាំ)ឆ្នាំ ដោយស្របទៅតាមច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

**៥. គ្រឹះស្ថានពេស្យាចារ**

ជាទូទៅគ្រឹះស្ថានពេស្យាចារ ជាទីកន្លែងសម្រាប់ប្រព្រឹត្តអំពើពេស្យាចារ។ ទីកន្លែងទាំងអស់នោះរួមមាន ផ្ទះ អគារ ឬ ជាទីកន្លែងផ្សេងៗ អាចហៅដោយសាមញ្ញថា **ផ្ទះបន**។

<u>ឧទាហរណ៍:</u> អគារ A មួយកន្លែងដែលស្ថិតនៅម្តុំ ស្ទឹងមានជ័យ ជាគ្រឹះស្ថានពេស្យាចារសម្រាប់បម្រើសេវាកម្មផ្លូវភេទ ដល់អតិថិជន។

ទោះបីជាយ៉ាណាក៏ដោយ ប្រសិនបើគ្រឹះស្ថានណាមួយ មិនមានគោលដៅសំខាន់ក្នុងការយកទីកន្លែងនោះ ដើម្បីប្រកបអាជីវកម្មពេស្យាចារទេ ប៉ុន្តែគ្រឹះស្ថាននោះបានកើតមាននូវអំពើ

ពេស្យាចារ មានន័យថា សកម្មភាពនៃអំពើពេស្យាចារនោះអាចនិងត្រូវបានម្ចាស់គ្រឹះស្ថានអនុញ្ញាត ឱ្យបុគ្គលណាមួយប្រព្រឹត្តពេស្យាចារនៅក្នុងគ្រឹះស្ថានរបស់ខ្លួន ហេតុនេះម្ចាស់គ្រឹះស្ថាន ឬ អ្នកដឹកនាំគ្រឹះស្ថាន ត្រូវតែទទួលខុសត្រូវ និងរងការផ្តន្ទាទោសទៅតាមច្បាប់។

**កថាខណ្ឌទី ២៖ ការដឹកនាំគ្រឹះស្ថានពេស្យាចារ**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ កាលបើបានយល់ព្រម ឬបានអនុគ្រោះ ឱ្យបុគ្គលណាម្នាក់ប្រព្រឹត្តពេស្យាចារនៅក្នុងគ្រឹះស្ថាន ឬ នៅក្នុងឧបសម្ព័ន្ធរបស់គ្រឹះស្ថាន ឬ ឱ្យបុគ្គលណាម្នាក់រកភ្ញៀវដើម្បីធ្វើពេស្យាចារនៅក្នុងគ្រឹះស្ថានឬនៅក្នុងឧបសម្ព័ន្ធរបស់ គ្រឹះស្ថាន នេះ[37]។

**១.ការឱ្យបុគ្គលណាម្នាក់ប្រព្រឹត្តពេស្យាចារនៅក្នុងគ្រឹះស្ថាន**

ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ បានធ្វើការផ្តន្ទាទោសចំពោះជនណាដែលបានយល់ព្រម ឱ្យបុគ្គលណាម្នាក់ប្រព្រឹត្តពេស្យាចារ នៅក្នុងគ្រឹះស្ថានរបស់ខ្លួន។ រីឯក្រមព្រហ្មទណ្ឌក៏បានចែងប្រហាក់ប្រហែលគ្នាផងដែរ ពីបទយល់ព្រមឱ្យធ្វើសកម្មភាពនៅក្នុងគ្រឹះស្ថាន។

ក្នុងករណីនេះ បុគ្គលដែលជាអ្នកគ្រប់គ្រង និងដឹកនាំគ្រឹះស្ថានមានចេតនា យល់ព្រមឱ្យមានការប្រព្រឹត្តអំពើពេស្យាចារនៅក្នុងគ្រឹះស្ថាន ឬឧបសម្ព័ន្ធនៃគ្រឹះស្ថានរបស់ខ្លួន។ ហេតុនេះម្ចាស់គ្រឹះស្ថានត្រូវទទួលការផ្តន្ទាទោសទៅតាមច្បាប់។

ផ្ទុយទៅវិញ ប្រសិនបើម្ចាស់គ្រឹះស្ថាន មិនបានដឹងពីការធ្វើអាជីវកម្មពេស្យាចារ នៅក្នុងគ្រឹះស្ថានរបស់ខ្លួនទេ ប៉ុន្តែសកម្មភាពពេស្យាចារនោះ បានកើតឡើងនៅលើគ្រឹះស្ថានរបស់គាត់ ក្នុងករណីនេះម្ចាស់គ្រឹះស្ថានមិនគួរទទួលការផ្តន្ទាទោសឡើយ។

<u>ឧទាហរណ៍:</u> ម្ចាស់សណ្ឋាគារ បានផ្តល់ទីកន្លែងឱ្យភ្ញៀវ ឬអតិថិជន ធ្វើការស្នាក់នៅធម្មតា ដើម្បីបានប្រាក់ចំណូលខ្លះ ប៉ុន្តែបុគ្គលិករបស់សណ្ឋាគារនៅទីនោះបានយកបន្ទប់មួយចំនួន ទៅប្រព្រឹត្តអំពើពេស្យាចារ ដោយមិនមានការយល់ព្រមពីម្ចាស់សណ្ឋាគារ។ ក្នុងករណីនេះម្ចាស់សណ្ឋាគារ មិនទទួលខុសត្រូវឡើយ។

ម្យ៉ាងវិញទៀត ដើម្បីធ្វើការផ្តន្ទាទោសចំពោះជនប្រព្រឹត្តបាន លុះត្រាតែ ជននោះបានដឹងយ៉ាងច្បាស់ពីសកម្មភាពនៃអំពើពេស្យាចារ នៅក្នុងគ្រឹះស្ថាន ឬ ឧបសម្ព័ន្ធ នៃគ្រឹះស្ថានរបស់ខ្លួន ហើយជននោះបានយល់ព្រម ឬ បានអនុគ្រោះឱ្យមាននូវសកម្មភាពពេស្យាចារកើតឡើង។

[37] មាត្រា ៣១ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ ២០០៨

**២. ការឱ្យបុគ្គលណាម្នាក់រកភ្ញៀវដើម្បីធ្វើពេស្យាចារនៅក្នុងគ្រឹះស្ថាន**

ជាគោលការណ៍ ដូចមានចែងនៅក្នុង ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ និងក្រមព្រហ្មទណ្ឌ បានបញ្ញត្តិដាក់ទោសទៅលើជនណាដែលបានយល់ព្រម ឬ អនុគ្រោះឱ្យបុគ្គលណាម្នាក់រកភ្ញៀវដើម្បីធ្វើពេស្យាចារនៅក្នុងគ្រឹះស្ថាន។ នៅក្នុងន័យនេះសំដៅដល់ម្ចាស់គ្រឹះស្ថានបានអនុញ្ញាតឱ្យបុគ្គលពេស្យា ឬ ជនមេពេស្យា ស្វែងរកភ្ញៀវ ឬ អតិថិជនសម្រាប់អំពើពេស្យាចារ។

ឧទាហរណ៍: ប្រសិនបើម្ចាស់ហាង ខារ៉ាអូខេ បានយល់ព្រមឱ្យមេពេស្យា បង្កប់នូវសេវាកម្មបម្រើផ្លូវភេទ ដល់អតិថិជន ឬ ភ្ញៀវដើម្បីធ្វើអំពើពេស្យាចារនៅក្នុងហាង មានន័យថាម្ចាស់ហាងខារ៉ាអូខេ នោះបានអនុគ្រោះឱ្យមានសកម្មភាពពេស្យាចារនៅក្នុងហាងរបស់ខ្លួន។ ដូច្នេះ ម្ចាស់ហាងខារ៉ាអូខេ ត្រូវទទួលរងការផ្តន្ទាទោសទៅតាមច្បាប់។

លើពីនេះទៅទៀត ការផ្តន្ទាទោសចំពោះជនល្មើសអាចធ្វើទៅបាន លុះត្រាតែមានភស្តុតាងច្បាស់លាស់បញ្ជាក់ពីចេតនាប្រព្រឹត្តរបស់ជនល្មើស ដោយមានការយល់ព្រម ឬ បានអនុគ្រោះឱ្យមានអំពើពេស្យាចារនៅក្នុងគ្រឹះស្ថាន ឬ ឧបសម្ព័ន្ធនៃគ្រឹះស្ថានរបស់ខ្លួន។ ពាក្យថា ឧបសម្ព័ន្ធនៃគ្រឹះស្ថាននេះ មានន័យថាជា ក្រុមនៃអគារ ដែលនៅជិតគ្នា ឬ ជាប់គ្នា ហើយត្រូវបានដឹកនាំ និងគ្រប់គ្រងដោយ រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលជាម្ចាស់នៃគ្រឹះស្ថានធំ។

**កថាខណ្ឌទី ៣៖ ការផ្តល់ទីកន្លែងសម្រាប់ធ្វើពេស្យាចារ**

ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ បានចែងដាក់ទោសទៅលើជនណាដែល លក់ ឬ ផ្តល់ឱ្យបុគ្គលណាម្នាក់ប្រើប្រាស់ទីកន្លែង ដែលមិនមែនប្រើប្រាស់ដោយសាធារណជន ដោយដឹងថាបុគ្គលនោះនឹងប្រើប្រាស់ទីកន្លែងនោះ សម្រាប់ធ្វើសកម្មភាពពេស្យាចារ ត្រូវផ្តន្ទាទោស ដាក់ពន្ធនាគារពី ២(ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ[38]។

ជាការពិតណាស់ ច្បាប់បានបញ្ញត្តិដាក់ទោស ចំពោះជនណា ដែលបានផ្តល់ទីកន្លែងសម្រាប់ប្រព្រឹត្តអំពើពេស្យាចារ ទោះបីជាការផ្តល់នោះធ្វើឡើងតាមរយៈ ការលក់ ការជួល ឬការផ្តល់ទីកន្លែងដោយមិនគិតផលប្រយោជន៍ក៏ដោយ។

**១. ការលក់**

ចំពោះការលក់ទីកន្លែងដូចជា ផ្ទះ ឬអគារ ដែលមិនមែនប្រើប្រាស់ដោយសាធារណៈជនទៅឱ្យបុគ្គលណាមួយដើម្បីប្រព្រឹត្តអំពើពេស្យាចារ ជាការខុសច្បាប់ និងទទួលរងការផ្តន្ទាទោស។ ក្នុង

[38] មាត្រា ៣២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ ២០០៨

ករណីនេះ សំដៅដល់ម្ចាស់ទ្រព្យ មានគោលបំណងលក់ទីកន្លែងដែលជាកម្មសិទ្ធិរបស់ខ្លួន ឱ្យទៅមេពេស្យា សម្រាប់ប្រព្រឹត្តសកម្មភាពពេស្យាចារ។

ឧទាហរណ៍: លោក **ក** ជាម្ចាស់នៃផ្ទះល្វែងមួយខ្នង បានព្រមព្រៀងលក់ផ្ទះល្វែងរបស់ខ្លួនឱ្យទៅលោក **ខ** ក្នុងតម្លៃ ១០ ម៉ឺន ដុល្លារ។ តាមរយៈការលក់នេះ លោក **ក** បានដឹងថា លោក **ខ** នឹងយកផ្ទះល្វែងនោះទៅបើកអាជីវកម្មពេស្យាចារ (ផ្ទះបន) ពីព្រោះថាលោក **ក** ធ្លាប់បានស្គាល់លោក **ខ** កាលពីមុនមក រួមទាំងបានដឹងពីមុខរបររកស៊ីរបស់ លោក **ខ** ដែលតែងតែបើកផ្ទះបន សម្រាប់បម្រើសេវាកម្មផ្លូវភេទ ហើយលោក **ក** ក៏ធ្លាប់ជាម៉ូយ ប្រចាំផ្ទះបននោះថែមទៀត។ ដូច្នេះ លោក **ក** ត្រូវតែទទួលការផ្តន្ទាទោសទៅតាមច្បាប់ ទោះបីជាគាត់បានផ្ទេរកម្មសិទ្ធិឱ្យទៅលោក **ខ** ហើយក៏ដោយ។

ផ្ទុយទៅវិញ ប្រសិនបើនៅអំឡុងពេលលក់ ម្ចាស់ទ្រព្យ មិនបានដឹងថាអ្នកទិញជាជនទុច្ចរិត ប៉ុន្តែក្រោយពេលលក់រួច ទើបដឹងថាអ្នកទិញនោះយកទីកន្លែងនោះទៅបើកផ្ទះបន ហេតុនេះម្ចាស់ទ្រព្យមិនគួរទទួលខុសត្រូវឡើយ។ ម្យ៉ាងវិញទៀត អ្នកលក់លែងជាម្ចាស់កម្មសិទ្ធិលើទ្រព្យនោះទៀតហើយ។

### ២. ការជួល

ការផ្តល់ជាទីកន្លែងឱ្យបុគ្គលណាមួយ សម្រាប់ប្រព្រឹត្តអំពើពេស្យាចារ តាមរយៈការជួល គឺជាអំពើខុសច្បាប់។ ក្នុងករណីនេះ សំដៅលើបុគ្គលដែលជាម្ចាស់ទ្រព្យ នឹងត្រូវផ្តន្ទាទោស ប្រសិនបើគាត់បានដឹងថា ក្នុងអំឡុងពេលណាមួយនៃការជួល ភាគីម្ខាងទៀតបានយកទីកន្លែងជួលនោះទៅប្រព្រឹត្តអំពើពេស្យាចារ ប៉ុន្តែភាគីម្ចាស់ទ្រព្យមិនព្រមបញ្ឈប់កិច្ចសន្យាជួលពីមេពេស្យាចារ ដែលរកស៊ីផ្លូវភេទទេ ហើយបែរជាបន្តការជួលទៅឱ្យមេពេស្យា នោះទៀត មានន័យថាម្ចាស់ទ្រព្យមានចេតនាផ្តល់ ទីកន្លែងឱ្យជនទុច្ចរិតប្រកបអាជីវកម្មពេស្យាចារ ហេតុនេះម្ចាស់ទ្រព្យត្រូវទទួលទោសដូចបានកំណត់ក្នុងច្បាប់។

ឧទាហរណ៍: លោក **ក** បានយកផ្ទះល្វែងរបស់គាត់ជួលឱ្យទៅ លោក **ខ** ក្នុងតម្លៃ ៥០០ ដុល្លារ ក្នុងមួយខែ។ រយៈពេល ៣ខែក្រោយមក លោក **ក** បានដឹងថា លោក **ខ** យកផ្ទះជួលទៅបើកជាផ្ទះបន ប៉ុន្តែលោក **ក** បែរជាមិនខ្វាយខ្វល់ពីសកម្មភាពពេស្យាចារអ្វីឡើយ ព្រោះគាត់គិតថាការជួលនេះ គឺដើម្បីទទួលបានប្រាក់ចំណូល ហើយគាត់នៅតែបន្តកិច្ចសន្យាជួលទៅឱ្យ លោក **ខ** ដដែល។

ម្យ៉ាងវិញទៀត ការជួលទីតាំងឱ្យជនណាមួយសម្រាប់ប្រព្រឹត្តអំពើពេស្យាចារជា អំពើខុសច្បាប់ ដោយសារតែការជួលទីកន្លែងនោះ ម្ចាស់ទ្រព្យគឺជាម្ចាស់កម្មសិទ្ធិ លើទ្រព្យសម្បត្តិ ដែលមានភាពផ្ទុយពីការលក់ ព្រោះថាម្ចាស់ទ្រព្យ ត្រូវផ្ទេរកម្មសិទ្ធិទៅឱ្យអ្នកទិញ។

# ជំពូកទី ៣

# ស្ថានភាពសង្គមដែលនាំឱ្យមានអំពើសញ្ចារកម្ម

ក្រោយពីប្រទេសជាតិយើង ទទួលបាននូវ សុខសន្តិភាពពេញលេញ និង មានស្ថេរភាពខាងនយោបាយរួចមក ធ្វើឱ្យប្រទេសកម្ពុជាបានប្រកាន់យកនូវរបបសេដ្ឋកិច្ចទីផ្សារសេរី ហើយចរន្តនៃសកលភាវូបនីយកម្មទំនើបបាននាំឱ្យមាន ការធ្វើវិនិយោគយ៉ាងច្រើនសន្ធឹកសន្ធាប់ ហើយព្រមទាំងបានទាក់ទាញនូវភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិ ចូលមកកម្ពុជាយ៉ាងច្រើនគួរឱ្យកត់សម្គាល់។ ហេតុនេះហើយ ឥទ្ធិពលនៃ វប្បធម៌បរទេសទាំងនោះ បានចាប់ផ្តើម រីកសាយភាយ ចូលមកប្រទេសកម្ពុជា យ៉ាងខ្លាំងដែលនាំឱ្យកើតមាន ទាំងផលវិជ្ជមាន និង ផលអវិជ្ជមាន ផងដែរ។ ដោយសារតែបញ្ហាដូចបានរៀបរាប់ទាំងអស់នេះហើយ ទើបជាមូលហេតុដែលនាំឱ្យមនុស្ស ចាប់យកនូវវប្បធម៌បរទេស ដែលមាន លក្ខណៈប្លែកៗជាច្រើនផ្សេងគ្នា រហូតជ្រុលខ្លួនធ្លាក់ចូលទៅក្នុងការប្រព្រឹត្តនូវសកម្មភាពល្មើសផ្សេងៗ ដែលសង្គមខ្មែរយើងមិនឱ្យតម្លៃឡើយ ជាពិសេស ការប្រព្រឹត្តអំពើពេស្យាចារ ឬ ការប្រកបអាជីវកម្មពេស្យាចារជាដើម ដែលជាទូទៅអាជីវកម្មបែបនេះបានធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំង ដល់ សេចក្តីថ្លៃថ្នូររបស់មនុស្ស។

ដូច្នេះហើយ ដើម្បីធ្វើការសិក្សាទៅលើមូលហេតុដែលនាំឱ្យកើតមាន អំពើសញ្ចារកម្មឡើង យើងត្រូវស្វែងយល់អំពីស្ថានភាពនៅក្នុងសង្គមជាក់ស្តែង ជាមុនសិន ជាពិសេស កត្តាជាច្រើនដែល ជម្រុញឱ្យកើតមាននូវអំពើសញ្ចារកម្ម រួមមានដូចជា កត្តាសង្គម (ផ្នែកទី ១) កត្តាគ្រួសារ (ផ្នែកទី ២) និង កត្តានៃបុគ្គលដែលជាជនរងគ្រោះផ្ទាល់ (ផ្នែកទី ៣) ហើយព្រមទាំងធ្វើការសិក្សាទៅលើផលវិបាកនៃអំពើសញ្ចារកម្ម (ផ្នែកទី ៤) ដែលបានកើតមានឡើងនៅក្នុងសង្គម មកធ្វើការបកស្រាយ។

## ផ្នែកទី ១៖ កត្តាសង្គម

### កថាខណ្ឌទី ១៖ សេដ្ឋកិច្ច

នៅក្នុងប្រទេសកំពុងអភិវឌ្ឍ វិស័យសេដ្ឋកិច្ចជាតិ មិនសូវជាមានការរីកចម្រើនដូចប្រទេសអភិវឌ្ឍឡើយ ហើយជារឿយៗតែងតែជួបប្រទះនូវបញ្ហាជាច្រើន ជាក់ស្តែងដូចជា ការខ្វះទីផ្សារក្នុងការនាំចេញនូវផលិតផលកសិកម្ម។ កសិករជាច្រើនបានខាតបង់ធនធាន ដោយសារតែ ទិន្នផលដែលទទួលបានពីការ ដាំដុះ គ្មានទីផ្សារនាំចេញ ហើយតម្លៃលក់ចុះថោក ដែលនាំឱ្យកសិករជួបនូវវិបត្តិ ខាតបង់យ៉ាងធ្ងន់ធ្ងរ។

ទន្ទឹមនឹងនេះ កម្រិតជីវភាពរបស់ប្រជាជនទូទៅមានការខ្វះខាតច្រើន ហើយប្រឈមមុខនិងភាពក្រីក្រ ភាពអត់ឃ្លាន ភាពគ្មានការងារធ្វើ ការធ្វើចំណាក់ស្រុក គ្រួសារជំពាក់បំណុល ជាហេតុ

ជម្រុញឱ្យមានការប្រព្រឹត្តនូវអំពើអបាយមុខផ្សេងៗ ដែលធ្វើឱ្យបាត់បង់សណ្តាប់ធ្នាប់សង្គម ដូចជាការលួច ឆក់ ប្លន់ ឬ ការកើតមាននូវអំពើពេស្យាចារច្រើន។ បញ្ហាទាំងអស់នេះតែងតែចោទឡើងនៅក្នុងប្រទេសកំពុងអភិវឌ្ឍច្រើនជាង ប្រទេសដែលមានសេដ្ឋកិច្ចរីកចម្រើន ពីព្រោះថាប្រទេសកំពុងអភិវឌ្ឍ ផ្នែកវិស័យសេដ្ឋកិច្ចពុំសូវមានការរីកចម្រើន ហើយកម្រិតនៃការយល់ដឹងរបស់ប្រជាពលរដ្ឋនៅទាប ដែលនាំឱ្យប្រជាពលរដ្ឋស្ថិតនៅក្នុងបន្ទាត់នៃភាពក្រីក្រច្រើន។

**កថាខណ្ឌទី ២៖ ការអប់រំ**

វិស័យអប់រំជាកត្តាសំខាន់ណាស់ដែលនាំឱ្យមនុស្សមានចំណេះដឹង មានសមត្ថភាព ដែលធ្វើឱ្យប្រទសជាតិសម្បូរនូវធនធានមនុស្ស។ កាលណាមនុស្សមានចំណេះដឹង និងសមត្ថភាព ពួកគេអាចរកការងារល្អបានធ្វើ ហើយអាចកាត់បន្ថយនូវអត្រានៃភាពក្រីក្របាន។

នៅក្នុងប្រទេសកម្ពុជា វិស័យអប់រំនៅមានកម្រិតនៅឡើយ ហើយព្រមទាំងមានការខ្វះខាតសាលារៀនជាច្រើនផងដែរ ជាពិសេសនៅតាមបណ្តាខេត្តមួយចំនួន។ ដោយសារតែប្រជាជនមានជីវភាពក្រីក្រច្រើន មានគ្រួសារខ្លះ មិនបានបញ្ជូនកូនឱ្យទៅរៀនទេ ដូច្នេះហើយ ការខ្វះចំណេះដឹងធ្វើឱ្យមនុស្សធ្លាក់ក្នុងភាពល្ងង់ខ្លៅ ងាយនឹងចាញ់បោក ការអូសទាញរបស់ជនទុច្ចរិត ដែលតែងតែប្រើ ល្បិចកលគ្រប់បែបយ៉ាង ក្នុងការកេងប្រវ័ញ្ច ឬ បោកប្រាស់យកទៅធ្វើជាជនពេស្យា បម្រើសកម្មភាពផ្លូវភេទជាដើម។

**កថាខណ្ឌទី ៣៖ សីលធម៌**

ការរស់នៅក្នុងសង្គមមួយ មនុស្សត្រូវចេះឱ្យតម្លៃលើខ្លួនឯង និងអ្នកដទៃ ក្នុងនាមជាមនុស្សដូចគ្នា។ ប្រសិនបើយើងម្នាក់ៗប្រកាន់ខ្ជាប់នូវក្រមសីលធម៌ និងឥរិយាបថថ្លៃថ្នូរ នោះយើងទាំងអស់គ្នាដែលរស់នៅក្នុងសង្គមនឹងប្រកបទៅដោយសេចក្តីថ្លៃថ្នូរ ព្រមទាំងមានកិត្តិយសល្អប្រពៃ។

ផ្ទុយទៅវិញ ប្រសិនបើយើងខ្លួនឯងមិនចេះឱ្យតម្លៃខ្លួនឯងទេ ហើយទៅប្រព្រឹត្តនូវអំពើអសីលធម៌ ដែលធ្វើឱ្យបាត់បង់កិត្តិយស ប្រពៃណីល្អ ឬបន្ទាបបន្ថោកខ្លួនឯងទៅនឹង ទំនិញទិញដូរ ឱ្យអ្នកដទៃរើសតាមចិត្តបែបនេះ នឹងធ្វើឱ្យសេចក្តីថ្លៃថ្នូររបស់មនុស្សត្រូវធ្លាក់ចុះ តាមរយៈការធ្វើអំពើល្ងង់ខ្លៅ ពាលាអាវាសែ លក់ខ្លួនធ្វើជា ស្ត្រី ឬបុរស ពេស្យា -ល-។ ទង្វើរបែបនេះសង្គមមិនឱ្យតម្លៃទេ ព្រមទាំងធ្វើឱ្យបាត់បង់កិត្តិយសខ្លួនឯង គ្រួសារ និងសង្គមជាតិទៀតផង។

**កថាខណ្ឌទី ៤៖ ការសេពគ្រឿងញៀន**

បញ្ហាគ្រឿងញៀននៅក្នុងសង្គម បានជះឥទ្ធិពលយ៉ាងខ្លាំងដល់យុវជន ដែលនាំឱ្យប៉ះពាល់ដល់សុខភាពចំពោះជនដែលប្រើប្រាស់គ្រឿងញៀន។ សព្វថ្ងៃនេះប្រទេសកម្ពុជាកំពុងតែជួបប្រទះនូវការចរាចរណ៍គ្រឿងញៀនទូទាំងប្រទេស។ លើសពីនេះទៅទៀត អ្នកដែលប្រើប្រាស់គ្រឿង

ញៀន ភាគច្រើន គឺ យុវវ័យ ដែលត្រូវបានមិត្តភក្តិ អូសទាញឱ្យសេពគ្រឿងញៀន។ យុវជនដែលញៀនថ្នាំទាំងអស់នោះ មានមួយចំនួនធ្លាក់ខ្លួនគេចសាលា ហើយទៅប្រព្រឹត្តសកម្មភាពដែលនាំឱ្យបាត់បង់សណ្តាប់ធ្នាប់សាធារណៈ និង ប្រព្រឹត្តបទល្មើសផ្សេងៗ ចំណែកឯបុគ្គលមួយចំនួនទៀតបានជ្រុលខ្លួនធ្វើជាស្រីពេស្យា លក់ខ្លួនដើម្បីយកលុយទៅទិញថ្នាំញៀន សម្រាប់ប្រើប្រាស់។

បញ្ហាគ្រឿងញៀនជាបញ្ហាប្រឈមមួយ ដែលរាជរដ្ឋាភិបាលត្រូវតែចេញវិធានការ ដើម្បីកម្ចាត់ ឬ លុបបំបាត់ចោលឱ្យអស់ ព្រោះថាគ្រឿងញៀនជាសារធាតុម្យ៉ាង ដែលអាចបំផ្លាញដល់សុខភាព ឬ អាយុជីវិត របស់មនុស្សទៀតផង។

**កថាខណ្ឌទី ៥៖ ទេសចរណ៍**

នៅក្នុងប្រទេសកម្ពុជា សម្បូរទៅដោយ ទីកន្លែងកម្សាន្តប្លែកៗជាច្រើន សម្រាប់បម្រើឱ្យវិស័យទេសចរណ៍ ជាពិសេសទៅទៀតនោះ មានភ្ញៀវទេសចរ អន្តរជាតិជុំវិញពិភពលោកមកកម្សាន្តលេងយ៉ាងច្រើន ហេតុនេះហើយនាំឱ្យកម្ពុជា ទទួលបានចំណូលយ៉ាងច្រើន ពីវិស័យទេសចរណ៍។ ទន្ទឹមនឹងនេះ វិស័យទេសចរណ៍បានជះឥទ្ធិពលអាក្រក់មកកម្ពុជាផងដែរ ដូចជាការហូរចូលនូវគ្រឿងញៀន ទេសចរណ៍ផ្លូវភេទ និងបញ្ហាជាច្រើនផ្សេងទៀត។

ភ្ញៀវទេសចរដែលចូលមកកម្ពុជាមួយចំនួន មានគោលបំណងទុច្ចរិត មានន័យថាគេធ្វើដំណើរកម្សាន្តមកកម្ពុជាដើម្បីប្រព្រឹត្តសកម្មភាពផ្លូវភេទ ឬ នាំយកនូវគ្រឿងញៀនមកធ្វើការចែកចាយ។ ក្រៅពីនេះមានភ្ញៀវទេសចរដែលមកកម្សាន្តជាលក្ខណៈធម្មតា ទេសចរណ៍ជំនួញ ឬការមកធ្វើទស្សនៈកិច្ចផ្លូវការផ្សេងទៀត។

**កថាខណ្ឌទី ៦៖ វប្បធម៌បរទេស**

យើងដឹងស្រាប់ហើយថា ប្រទេសកម្ពុជាយើងនាពេលសព្វថ្ងៃនេះ បានទទួលរងនូវ ឥទ្ធិពលនៃវប្បធម៌បរទេសយ៉ាងខ្លាំង ដែលជាហេតុ នាំឱ្យកើតមានបញ្ហាស្មុគស្មាញ ជាច្រើនកើតឡើងនៅក្នុងសង្គម។

វប្បធម៌បរទេសទាំងអស់នោះ បានធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរ និង ទំនៀមទម្លាប់ល្អរបស់ប្រជាជនខ្មែរ និង ប្រទេសជាតិរបស់យើង។ ដោយសារតែវប្បធម៌បរទេស បានសាយភាយឥទ្ធិពលមកលើសង្គមខ្មែរ នាំឱ្យមានការចម្លងយកតាម ហើយបានប្រតិបត្តិនូវសកម្មភាពទាំងឡាយដែលផ្ទុយនិង ប្រពៃណី វប្បធម៌របស់ខ្មែរយើង ជាក់ស្តែងដូចជា ការយកគ្នាជាប្តីប្រពន្ធតាមដងផ្លូវ ឬការរួមភេទនៅតាមទីសាធារណៈ ឬ ការបម្រើសេវាកម្មផ្លូវភេទ ដោយបើកចំហានៅតាមផ្ទះបន ។ល។

**កថាខណ្ឌទី ៧៖ បញ្ហាជនអន្តោប្រវេសន៍ខុសច្បាប់**

ជាទូទៅបញ្ហាជនអន្តោប្រវេសន៍ខុសច្បាប់ ដែលចូលមកកម្ពុជាមានចំនួនយ៉ាងច្រើន គួរឱ្យកត់សម្គាល់។ ដោយសារតែបញ្ហាទាំងអស់នេះហើយ ទើបធ្វើឱ្យកម្ពុជា មានភាពអនាធិបតេយ្យ

បាត់បង់សណ្តាប់ធ្នាប់សង្គមយ៉ាងខ្លាំង។ ជនអន្តោប្រវេសន៍ដែលបានលួចចូលមកកម្ពុជា ដោយមិនស្របច្បាប់ ភាគច្រើនត្រូវបានគេនាំយកទៅលក់ធ្វើជាស្ត្រីពេស្យាបម្រើផ្លូវភេទ ហើយមួយចំនួនទៀតប្រកបរបរ រកស៊ីលក់ដូរតាមចិញ្ចើមផ្លូវសាធារណៈ។ ទន្ទឹមនឹងនេះ យើងឃើញថាមានសកម្មភាពរបស់សមត្ថកិច្ចបានចុះទៅត្រួតពិនិត្យ និងបង្ក្រាបនូវបទល្មើសជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទរបស់មេបន ទៅលើបុគ្គលពេស្យា ដែលជាជនអន្តោប្រវេសន៍ខុសច្បាប់ទាំងអស់នោះទៀតផង។

ដូច្នេះកត្តាដែលនាំឱ្យកើតមាននូវអំពើសញ្ចារកម្ម ឬការកេងប្រវ័ញ្ចណាមួយដែលនាំឱ្យមានការរំលោភសិទ្ធិមនុស្ស ការបង្ខិតបង្ខំ ឬសកម្មភាពផ្សេងៗដែលធ្វើឱ្យបាត់បង់សណ្តាប់ធ្នាប់សាធារណៈ អាចកើតចេញពីបញ្ហាជនអន្តោប្រវេសន៍ខុសច្បាប់ទាំងនេះផងដែរ។

## ផ្នែកទី ២៖ កត្តាគ្រួសារ

### កថាខណ្ឌទី ១៖ បញ្ហាសេដ្ឋកិច្ចគ្រួសារ

ដោយសារតែ ជីវភាព ក្រីក្រ លំបាក ទើបធ្វើឱ្យនារីមួយចំនួនត្រូវបង្ខំចិត្តធ្វើជាស្ត្រីពេស្យា ដើម្បីបានកម្រៃទុកសម្រាប់ចិញ្ចឹមគ្រួសារ។ នៅតាមទីជនបទស្ត្រីក្មេងៗ បានចាញ់បោកការលួងលោមរបស់ជនទុច្ចរិត (មេខ្យល់) ដែលបានអូសទាញឱ្យទៅធ្វើការនៅឯទីក្រុង ដោយសារតែនៅទីនោះសម្បូរការងារល្អៗធ្វើ ប៉ុន្តែផ្ទុយទៅវិញស្ត្រីទាំងអស់នោះត្រូវបានមេខ្យល់យកទៅលក់ឱ្យឈ្មួញរកស៊ីផ្លូវភេទយ៉ាងអាណោចអាធ័ម។

អាស្រ័យហេតុនេះភាពក្រីក្រ គឺជាកត្តាដ៏សំខាន់មួយ ដែលធ្វើឱ្យមនុស្ស ត្រូវបង្ខំចិត្តធ្វើជាបុគ្គលពេស្យា ហើយម្យ៉ាងវិញទៀត ភាពក្រីក្រអាចធ្វើឱ្យមនុស្សងាយនិងធ្លាក់ខ្លួនចាញ់បោក ការអូសទាញរបស់ជនទុច្ចរិត ដែលនាំទៅធ្វើការនៅកន្លែងឆ្ងាយៗ ដើម្បីងាយស្រួលក្នុងការប្រព្រឹត្តសកម្មភាពជួញដូរមនុស្ស និងការកេងប្រវ័ញ្ចនានា ជាពិសេស ស្ត្រី និងកុមារ។ ចំណែកឯបុរសវិញត្រូវបានគេនាំយកទៅក្រៅប្រទេសដោយខុសច្បាប់ តាមរយៈការដឹកនាំរបស់ជនទុច្ចរិតយកពលករទៅក្រៅប្រទេស ដើម្បីធ្វើការងារធ្ងន់ៗ នៅតាម ទូកនេសាទ នាវា កប៉ាល ឬ ទីកន្លែងផ្សេងៗទៀត ។

### កថាខណ្ឌទី ២៖ ការជំពាក់បំណុល

បញ្ហាបំណុល ដែលភាគច្រើនកើតឡើងចំពោះបុគ្គលណាដែលខ្វះខាត ទីទ័ល ឬមានតម្រូវការអ្វីមួយដែលចាំបាច់បន្ទាន់ ទើបត្រូវបង្ខំចិត្ត ខ្ចីប្រាក់ដើម្បីធ្វើការដោះទ័ល។ ម្យ៉ាងវិញទៀតដោយសារអត្រាការប្រាក់ខ្ពស់ខ្លាំងពេក នាំឱ្យកូនបំណុលខ្វះលទ្ធភាពសងទៅម្ចាស់បំណុល ពេលខ្លះកូនបំណុលត្រូវខិតខំធ្វើការងារលើសម៉ោង ឬ ទៅចងការប្រាក់ពីបុគ្គលផ្សេងទៀត ដើម្បីដោះ

បំណុល។ ជូនកាលកូនបំណុលត្រូវបានទទួលរងការគំរាមកំហែងពីម្ចាស់បំណុល រហូតធ្វើអត្តឃាតសម្លាប់ខ្លួនក៏មាន។ នៅពេលខ្លះទៀត កូនបំណុលមានការភ័យខ្លាច ដោយដឹងថាមិនអាចសងប្រាក់ទៅម្ចាស់បំណុលបាន ទើបត្រូវបង្ខំចិត្ត លក់ទីលំនៅ លក់ដីស្រែចម្ការ ឬ លក់កេរ្តិ៍អាករគ្រប់បែបយ៉ាង ហើយថែមទាំងលក់កូនស្រីរបស់ខ្លួនដើម្បីដោះបំណុល ពីព្រោះថាបើមិនធ្វើបែបនេះទេ គាត់និងត្រូវជាប់បំណុលគេអស់មួយជីវិត ឬត្រូវបានម្ចាស់បំណុលគំរាមចាប់ដាក់គុក ប្រសិនបើគាត់មិនសងបំណុល។

**កថាខណ្ឌទី ៣៖ អំពើហិង្សាក្នុងគ្រួសារ**

អំពើហិង្សាក្នុងគ្រួសារ សំដៅលើអំពើហិង្សាដែលកើតមាន និង អាចកើតមានទៅលើប្តី ឬ ប្រពន្ធ កូនក្នុងបន្ទុក និង ជនទាំងឡាយដែលរស់នៅក្រោមដំបូលផ្ទះ និង ក្នុងបន្ទុកគ្រួសារ។ អំពើហិង្សានេះរួមមាន អំពើ បំពានដល់ជីវិត (ដូចមនុស្សឃាត...) អំពើប៉ះពាល់ដល់បូរណភាពរូបកាយ (ដូចជាការបំពារបំពានលើរូបរាងកាយ...) ការធ្វើទារុណកម្ម ឬ ការធ្វើអំពើឃោរឃៅ (ដូចជាការធ្វើទុក្ខបុកម្នេញបង្កឱ្យមានការឈឺចុកចាប់ផ្លូវចិត្ត សតិអារម្មណ៍ បញ្ញាស្មារតី...) និងការឈ្លានពានខាងផ្លូវភេទ (ដូចជាការប្រើហិង្សា សេពសន្ថវៈ...)[39]។

យោងតាមការបកស្រាយខាងលើ យើងអាចនិយាយបានថា ស្ត្រី និងកុមារ ឬបុគ្គលដែលរងគ្រោះដោយសារអំពើហិង្សា ភាគច្រើនត្រូវបង្ខំចិត្តចាក់ចេញពីផ្ទះ ដោយមិនអាចទ្រាំទ្រ និងការគាបសង្កត់ដោយហិង្សា ដែលប្រព្រឹត្តដោយសាមាជិកណាមួយក្នុងគ្រួសារ ដែលអាចកើតមានទៅលើប្តី ឬ ប្រពន្ធ កូនក្នុងបន្ទុក ឬជនទាំងឡាយដែលរស់នៅក្រោមដំបូលផ្ទះ និងក្នុងបន្ទុកគ្រួសារ។

**កថាខណ្ឌទី ៤៖ ខ្វះភាពកក់ក្តៅក្នុងគ្រួសារ**

ការរស់នៅក្នុងជីវិតដែលរីករាយ ធ្វើឱ្យមនុស្សមានសេក្តីសុខ និងមានសុភមង្គល។ គ្រួសារដែលមានសុភមង្គលមិនមែនសំដៅលើគ្រួសារដែល មានទ្រព្យសម្បត្តិស្តុកស្តម្ភ ច្រើនហូរហៀរ ឬមានបុណ្យស័ក្តិខ្ពង់ខ្ពស់នោះទេ ប៉ុន្តែជាគ្រួសារដែលប្រកបដោយភាពរីករាយ ភាពកក់ក្តៅ និងមានសេចក្តីសុខទាំងផ្លូវកាយ និងចិត្ត ទើបជាគ្រួសារដែលមានសុភមង្គល។ ប្រសិនបើគ្រួសារមួយបានឈានទៅដល់ ការបែកបាក់សាមគ្គី នឹងនាំឱ្យសមាជិកក្នុងគ្រួសារនោះខ្វះភាពកក់ក្តៅ ខ្វះសេចក្តីស្រលាញ់ ខ្វះការថែទាំ ហើយគ្រួសារពោរពេញទៅដោយភាពអាប់អួលជាដើម។ ការខ្វះភាពកក់ក្តៅក្នុងគ្រួសារនេះអាចកើតចេញពីអំពើហិង្សា ឬ ទង្វើរផ្សេងៗរបស់សមាជិកណាមួយដែលស្តែងចេញនាំឱ្យប៉ះពាល់ ឬ ធ្វើឱ្យបែកបាក់សាមគ្គីភាពនៅក្នុងគ្រួសារ។ ជាក់ស្តែងដូចជាការចាកចេញពីផ្ទះសម្បែងដោយសារមានអំពើហិង្សាក្នុងគ្រួសារ ឬ ការដាក់សម្ពាធពីគ្រួសារ។ ជាទូទៅបុគ្គល

[39] ទំព័រទី ៥០ នៃសទ្ទានុក្រម ស្តីពីការជួញដូរមនុស្ស និងចិត្តវិទ្យា បោះពុម្ពលើកទី ២ ខែ កញ្ញា ឆ្នាំ ២០១៣

ដែលរងគ្រោះទាំងនេះ អាចនឹងធ្លាក់ខ្លួនទៅជាស្រីពេស្យា ឬ ត្រូវជនខិលខូច ឆ្លៀតឱកាស ប្រើមធ្យោបាយ បោកប្រាស់នាំយកទៅលក់ជាដើម។

**កថាខណ្ឌទី ៥៖ ការបោះបង់ចោលគ្រួសារ**

នៅក្នុងរបបខ្មែរក្រហម ប្រជាពលរដ្ឋខ្មែរត្រូវបានពួកប៉ុលពត ជម្លៀស ចេញពីលំនៅឋាន ទៅកាន់ទីកន្លែងឆ្ងាយដាច់ស្រយាល រស់នៅយ៉ាងលំបាកវេទនា ហើយត្រូវពួកប៉ុលពត បំបិទសិទ្ធិសេរីភាព ថែមទាំងបង្ខំឱ្យធ្វើការងារធ្ងន់ៗលើសកម្លាំង។ គ្រួសារជាច្រើនត្រូវរស់បែកបាក់សមាជិក និងខ្លះទៀតត្រូវបានខ្មែរក្រហមសម្លាប់ចោលទាំងគ្រួសារ។ ក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩ ប្រជាពលរដ្ឋខ្មែរមានក្តីសង្ឃឹមឡើងវិញ ហើយបានវិលត្រលប់ទៅស្រុកកំណើត ដើម្បីជួបជុំគ្រួសារ បងប្អូន សាច់ញាតិ ប៉ុន្តែដោយសារប្រទេសជាតិទើបរួចផុតពីសង្គ្រាមភ្លាមៗ ប្រជាពលរដ្ឋរស់នៅផ្តើមជីវិតសារជាថ្មី ដោយខំប្រឹងរកស៊ី ធ្វើស្រែចម្ការ គិតតែពីផលប្រយោជន៍រៀងៗខ្លួន ហើយក្មេងៗដែលនៅសល់ពីជំនាន់ប៉ុលពត អ្នកខ្លះត្រូវឪពុកម្តាយ ស្លាប់ ចោល រស់នៅកំព្រា រសាត់អណ្តែតគ្មានទីពឹង ចំណែកឯសាច់ញាតិ បងប្អូន ក៏បាត់ដំណឹងសូន្យ។ យើងសង្កេតឃើញថា ក្មេងៗ ដែលឯកកោរ មួយចំនួន អាចនឹងងាយធ្លាក់ខ្លួន ចាញ់បោកជនខិលខូច ដែលឆ្លៀតឱកាស ក្នុងអំឡុងពេលប្រទេសកំពុងតែដុនដាប់ ទន់ខ្សោយ។ ជាពិសេសកុមារអាចនឹង ត្រូវជនខិលខូច កេងចំណេញ ឬ បណ្តុះបណ្តាលឱ្យធ្វើជា បុគ្គលពេស្យាផងដែរ។

**កថាខណ្ឌទី ៦៖ ការយល់ដឹងនូវមានកម្រិតទាប**

ការអប់រំមានសារៈសំខាន់ណាស់ ចំពោះមនុស្សទូទៅ ដែលអាចធ្វើឱ្យមនុស្សជៀសផុតពីភាពល្ងង់ខ្លៅ និងភាពក្រីក្រផងដែរ។ បើកាលណាមនុស្សមានចំណេះដឹងទាបអាចងាយប្រឈមមុខទៅនឹងការចាញ់បោកគេ ការទទួលរងនូវអំពើកេងប្រវ័ញ្ចផ្សេងៗ ឬ ត្រូវចាញ់បោកការបញ្ចុះបញ្ចូលរបស់បុគ្គលណាមួយឱ្យប្រព្រឹត្តអំពើពេស្យាចារ។ ឧទាហរណ៍: ស្ត្រីក្មេងៗនៅជនបទត្រូវបានឈ្មួញរកស៊ីជួញដូរផ្លូវភេទ កុហកថានឹងរក ការងារល្អឱ្យធ្វើ ប្រសិនបើក្មេងស្រីទាំងអស់នោះយល់ព្រមទៅជាមួយខ្លួន។

ដោយសារតែការយល់ដឹងនៅមានកម្រិតទាប និងជីវភាពគ្រួសារលំបាក មិនអាចបំពេញតម្រូវការរស់នៅប្រចាំថ្ងៃបាន ជាហេតុនាំឱ្យគ្រួសារដែលមានជីវភាពក្រីក្រមួយចំនួនត្រូវធ្លាក់ខ្លួនចាញ់បោកការអូសទាញរបស់ជនទុច្ចរិត ដោយនាំយកទៅលក់ធ្វើជាស្ត្រីពេស្យា។ ក្នុងករណីនេះ រាជរដ្ឋាភិបាល ត្រូវតែចាត់វិធានការ លុបបំបាត់នូវសកម្មភាពជួញដូរមនុស្ស ដោយអនុវត្តច្បាប់ឱ្យបានតឹងរឹង អនុវត្តសកម្មភាពឱ្យមានប្រសិទ្ធភាព ធ្វើការបណ្តុះបណ្តាល និងអប់រំប្រជាពលរដ្ឋឱ្យមានចំណេះដឹង។

### កថាខណ្ឌទី ៧៖ វិសមភាពរវាងបុរស និងស្ត្រី

ជាទូទៅនៅក្នុងសង្គម តែងតែមានគ្រួសារខ្លះប្រកាន់ខ្ជាប់នូវគំនិតចាស់គំរិល ដែលឱ្យតម្លៃទៅលើកូនប្រុស ច្រើនជាងកូនស្រី ដោយសារតែពួកគេគិតថា កូនប្រុសជាក្តីសង្ឃឹមតែមួយគត់សម្រាប់គ្រួសារ ជាលាភសំណាងដែលអាចស្នងត្រកូលឱ្យគ្រួសារ ជាពិសេសអ្នកដែលមានសែស្រឡាយកាត់ចិន ឬ ជនជាតិចិន ដែលជាជាតិសាសន៍មួយនិយមឱ្យតម្លៃទៅលើកូនប្រុសច្រើនជាងកូនស្រី។ ផ្ទុយទៅវិញ ការគិតបែបនេះគឺ មិនយុត្តិធម៌សម្រាប់កូនស្រីឡើយ ពីព្រោះថានៅពេលបច្ចុប្បន្ននេះ ស្ត្រីត្រូវបានបណ្តាប្រទេសជាច្រើននៅលើសកលលោកឱ្យតម្លៃ និងលើកម្ពស់សិទ្ធិសេរីភាព ស្មើនិងបុរស ហើយព្រមទាំងជាមាតាពិភពលោកទៀតផង។

ការប្រកាន់ខ្ជាប់នូវគំនិតរើសអើងផ្សេងៗ ដែលនាំឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពរបស់ស្ត្រីត្រូវបានលុបបំបាត់ចោលទាំងស្រុង ប៉ុន្តែរហូតមកដល់បច្ចុប្បន្ននេះមានគ្រួសារខ្លះ នៅតែមានផ្នត់គំនិតឱ្យតម្លៃលើកូនប្រុសច្រើនជាងកូនស្រីដដែល ហេតុនេះនាំឱ្យគ្រួសារខ្វះភាពកក់ក្តៅ ដោយសារតែវិសមភាពរវាងបុរស និងស្ត្រី។

## ផ្នែកទី ៣៖ កត្តាបុគ្គលជនរងគ្រោះ

### កថាខណ្ឌទី ១៖ កើតវិបត្តិផ្លូវចិត្ត

បុគ្គលដែលកើតមាននូវបញ្ហាផ្លូវចិត្ត ភាគច្រើនជាមនុស្សដែលរងនូវសម្ពាធធ្ងន់ធ្ងរ ពីគ្រប់មជ្ឈដ្ឋានជុំវិញខ្លួន ហើយធ្វើឱ្យស្ថានភាពផ្លូវចិត្តរបស់គេកាន់តែយ៉ាប់យ៉ឺនឡើង រហូតឈានទៅដល់បាត់បង់ស្មារតី លែងម្ចាស់ការលើខ្លួនបាន។ បុគ្គលដែលមានវិបត្តិខាងផ្លូវចិត្តអាចបណ្តាលមកពីកត្តាច្រើនយ៉ាងដូចជា: ការដាក់សម្ពាធដោយគ្រួសារ ការទទួលរងទណ្ឌកម្មធ្ងន់ធ្ងរ ការប្រើប្រាស់ថ្នាំញៀន ឬការកើតមានវិបត្តិស្នេហា -ល-។

ដោយសារតែបញ្ហាផ្លូវចិត្តនាំឱ្យបុគ្គលជាជនរងគ្រោះ ប្រព្រឹត្តនូវទង្វើរផ្សេងៗ ដែលនាំឱ្យប៉ះពាល់ដល់អាយុជីវិត ឬ គ្រោះថ្នាក់ផ្សេងៗដែលនឹកស្មានមិនដល់។ ឧទាហរណ៍: ការធ្វើអត្តឃាតសម្លាប់ខ្លួន ដោយសារតែធុញទ្រាន់ និង ជីវិតដែលក្រលំបាក ហើយជំពាក់បំណុលគេថែមទៀត។ ប៉ុន្តែក្នុងករណីខ្លះទៀត ការធ្វើអត្តឃាតសម្លាប់ខ្លួនដោយសារតែរឿងស្នេហាក៏អាចកើតមាននៅក្នុងសង្គមផងដែរ។ ទោះបីជាយ៉ាងណាក៏ដោយ ការស្ថិតនៅក្នុងភាពមានវិបត្តិផ្លូវចិត្ត ឬ ការកើតរោគចិត្ត និងធ្វើឱ្យមនុស្សខ្វះការយល់ដឹង ខ្វះការពិចារណា ហើយអាចនិងត្រូវជនខិលខូចល្បួងយកទៅធ្វើជាស្រីពេស្យា ប្រសិនបើគាត់ជានារីភេទដែលកើតមានវិបត្តិផ្លូវចិត្ត។

**កថាខណ្ឌទី ២៖ អនាថា**

ភាពអនាថា ក៏អាចធ្វើឱ្យមនុស្សធ្លាក់ខ្លួនធ្វើជាជនពេស្យាបានដែរ ដោយសារតែខ្លួនគ្មានទិសដៅដែលត្រូវទៅ ហើយការរស់នៅរសាត់អណ្តែតគ្មានទីកន្លែងច្បាស់លាស់ ដូច្នេះជនអនាថាមួយចំនួនបានរស់នៅចិញ្ចឹមជីវិតដោយការធ្វើជាស្រីពេស្យា លក់ខ្លួននៅតាមទីសាធារណៈ ឬ នៅតាមផ្ទះបនជាដើម ព្រោះថាការធ្វើបែបនេះ ប្រសើរជាងជីវិតដែលដើរសុំទានគេ ឬ ការរើសកាកសំណល់មកបរិភោគនៅតាមដងផ្លូវផងដែរ។ នៅក្នុងសង្គមជាក់ស្តែង មានជនអនាថាជាច្រើនដែលរស់នៅតាមដងផ្លូវ ដែលបានធ្វើឱ្យមានភាពអនាធិបតេយ្យយ៉ាងខ្លាំង ហើយថែមទាំងធ្វើឱ្យសង្គមបាត់បង់សណ្តាប់ធ្នាប់ទៀតផង។

ទោះបីជាយ៉ាងណាក៏ដោយ បញ្ហាជនអនាថាតែងតែកើតមាននៅក្នុងសង្គម ជាពិសេសនៅក្នុងប្រទេសក្រីក្រ ហើយមានសេដ្ឋកិច្ចទន់ខ្សោយ ព្រោះថាប្រជាជនភាគច្រើន មានជីវភាពលំបាកក្រីក្រ និងខ្វះខាត ហេតុនេះហើយ អត្រានៃជនអនាថាតែងកើតមានច្រើននៅក្នុងប្រទេសដែលមានសេដ្ឋកិច្ចទន់ខ្សោយ។

**កថាខណ្ឌទី ៣៖ ភ្លើតភ្លើន**

ការសប្បាយភ្លើតភ្លើនច្រើន ងាយនឹងធ្វើឱ្យយុវជនត្រូវមិត្តភក្តិអូសទាញ ក្នុងការដើរហើរច្រើន ឬ ត្រូវគេល្បួងឱ្យប្រើប្រាស់គ្រឿងញៀនផងដែរ។ ដោយសារតែការភ្លើតភ្លើនច្រើន យុវជនមួយចំនួនតូច បានជ្រុលខ្លួនធ្វើជាស្រីពេស្យា (ចំពោះនារី) ដែលត្រូវបានមិត្តភក្តិរបស់ខ្លួន បោកប្រាស់ដោយនាំយកទៅលក់ឱ្យជនខិលខូច ដែលប្រកបអាជីវកម្មពេស្យាចារ។

**កថាខណ្ឌទី ៤៖ ភាពគ្មានការងារធ្វើ**

ភាពគ្មានការធ្វើជាមូលហេតុដែលនាំឱ្យមនុស្សប្រព្រឹត្តអំពើពេស្យាចារ ដោយសារតែភាពក្រីក្រ ភាពគ្មានចំណេះដឹងនាំឱ្យពួកគេមិនអាចរកការងារល្អបានធ្វើ ទើបត្រូវបង្ខំចិត្តលក់ខ្លួន តាមរយៈការធ្វើជាជនពេស្យា ដើម្បីរកប្រាក់ចិញ្ចឹមជីវិត។ ដូច្នេះរាជរដ្ឋាភិបាលគួរតែគិតគូរពីបញ្ហានេះឡើងវិញ និងត្រូវដោះស្រាយជូនប្រជាពលរដ្ឋ ដោយបង្កើតនូវលក្ខខណ្ឌដែលជម្រុញឱ្យសេដ្ឋកិច្ចមានការរីកចម្រើន និងផ្តល់ឱកាសការងារជូនប្រជាជន ដើម្បីកាត់បន្ថយភាពក្រីក្រ។

**កថាខណ្ឌទី ៥៖ ខូចចិត្តរឿងស្នេហា**

បញ្ហារឿងរ៉ាវស្នេហាតែងតែកើតមានទៅលើមនុស្សគ្រប់គ្នា ជាពិសេសយុវវ័យ។ បច្ចុប្បន្ននេះសូម្បីតែក្មេងមិនទាន់គ្រប់អាយុជានីតិជនផងក៏ធ្លាប់ឆ្លងកាត់នូវស្នេហា ទោះបីជាពួកគេស្ថិតនៅក្នុងវ័យសិក្សារៀនសូត្រ កម្រិតថ្នាក់បឋមក្តី ឬអនុវិទ្យាល័យក្តី។ ចំណែកឯការសិក្សានៅថ្នាក់វិទ្យាល័យវិញ យើងសង្កេតឃើញថា សិស្សសាលាភាគច្រើនមានទំនាក់ទំនងស្នេហា ជាមួយសង្សារ

ដែលរៀនថ្នាក់ជាមួយគ្នា ឬរៀននៅក្នុងសាលាជាមួយគ្នាក៏មានផងដែរ ហើយពេលខ្លះ ទំនាក់ទំនងទាំងនោះ មិនសូវជាបានយូរអង្វែងនោះទេ ក៏ត្រូវបែកបាក់គ្នាទៅវិញ ដោយសារភាពជាយុវវ័យមិនបានគិតគូរវែងឆ្ងាយ ហើយពួគេមិនសូវយល់ពីស្នេហាអីនោះទេ ព្រោះថាខ្លួនស្ថិតនៅក្នុងភាពជាយុវវ័យមានការសប្បាយភ្លើតភ្លើនច្រើន។ ក្នុងករណីនេះយុវវ័យដែលជ្រុលខ្លួនក្នុងរឿងស្នេហា ពេលខ្លះត្រូវខូចខ្លួនជាមួយសង្សារ ហើយត្រូវសង្សារបោះបង់ចោល បណ្តាលឱ្យខូចចិត្តជាខ្លាំង ហើយអាចនាំឱ្យគេខ្វះការពិចារណា រហូតជ្រុលខ្លួនធ្វើជាស្រីពេស្យាថែមទៀតផង។

**កថាខណ្ឌទី ៦៖ ចាញ់បោកការអូសទាញ**

ជនរងគ្រោះជាស្ត្រីភាគច្រើន ត្រូវចាញ់បោកការអូសទាញរបស់ជនខិលខូច ហើយត្រូវគេនាំយកទៅលក់នៅផ្ទះបន។ ជាទូទៅការធ្វើសកម្មភាពបោកប្រាស់របស់ជនខិលខូចភាគច្រើនទៅលើគ្រួសារដែលមានជីវភាពក្រីក្រ នៅតាមទីជនបទ ដោយប្រព្រឹត្តតាមរយៈការណែនាំឱ្យធ្វើការនៅទីក្រុង។ ដោយសារតែស្ថានភាពគ្រួសារលំបាកទើបធ្វើឱ្យឪពុកម្តាយខ្លះជម្រុញកូនរបស់ខ្លួនទៅធ្វើការតាមការ បញ្ចុះបញ្ចូលរបស់គេ ដោយសង្ឃឹមថាកូនរបស់ខ្លួន នឹងទទួលបានការងារសមរម្យ ហើយអាចផ្គត់ផ្គង់ជាលុយកាក់ដល់គ្រួសារបានខ្លះ ប៉ុន្តែផ្ទុយទៅវិញបែរជាត្រូវជនខិលខូច បោកប្រាស់នាំយកទៅលក់ធ្វើជាស្រីពេស្យានៅផ្ទះបនទៅវិញ។ ក្រៅពីនេះយើងឃើញថា ការឆបោកអាចធ្វើឡើងក្រោមទម្រង់ជាការរៀបអាពាហ៍ពិពាហ៍ក្លែងក្លាយ ឬ កើតចេញពីការសុំកូនយកទៅចិញ្ចឹមថែមទៀតផង។ បញ្ហាទាំអស់នេះហើយដែលអាជ្ញាធរត្រូវតែទប់ស្កាត់ និងបង្ក្រាបរាល់សកម្មភាពរបស់ជនខិលខូច និងត្រូវធ្វើការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឱ្យយល់ដឹង កុំឱ្យចាញ់បោកការអូសទាញរបស់ជនខិលខូចតទៅទៀត។

**កថាខណ្ឌទី ៧៖ ត្រូវគេចាប់ពង្រាត់**

ជនរងគ្រោះខ្លះត្រូវបានជនខិលខូច ចាប់ពង្រាត់យកទៅ ធ្វើជាស្រីពេស្យាក៏អាចកើតមានឡើងផងដែរ ជាពិសេស នៅតាមទីដាច់ស្រយាល ដែលឃ្លាតឆ្ងាយពីទីប្រជុំជន ដោយអាចផ្តល់ភាពងាយស្រួលដល់ជនខិលខូច ឆ្លៀតឱកាសចាប់ក្មេងស្រីៗយកទៅធ្វើជាស្រីបន។ បញ្ហានេះជាការព្រួយបារម្ភផងដែរ ចំពោះប្រជាជនដែលរស់នៅតំបន់ជនបទ ស្ងាត់ ដាច់ស្រយាល ត្រូវតែបង្កើនការប្រុងប្រយ័ត្នទៅលើគ្រួសារណាដែលមានក្មេងស្រីៗ គួរតែមានការប្រុងប្រយ័ត្ន ជៀសវាងត្រូវជនខិលខូច ឆ្លៀតឱកាសចាប់យកទៅលក់។

ទោះបីជាយ៉ាងណាក៏ដោយ ហេតុការណ៍ទាំងនេះជាសញ្ញាណមួយដែលបង្ហាញអំពីការខ្វះខាតផ្នែកសន្តិសុខ សុវត្ថិភាពដែលធានាដោយអាជ្ញាធរមានសមត្ថកិច្ចទទួលខុសត្រូវលើការងាររក្សាសន្តិសុខ សណ្តាប់ធ្នាប់សង្គម។

## ផ្នែកទី ៤៖ ផលប៉ះពាល់នៃអំពើសញ្ជារកម្ម

### កថាខណ្ឌទី ១៖ ចំពោះមនុស្ស

#### ១. ប៉ះពាល់ដល់ផ្លូវកាយ និង ចិត្ត

ជាទូទៅជនរងគ្រោះ (បុគ្គលពេស្យា) ដែលត្រូវបានគេចាប់បង្ខំឱ្យបម្រើផ្លូវភេទ តែងតែទទួលរងនូវផលវិបាកជាច្រើនពីអំពើទាំងអស់នោះដូចជា: បញ្ហាសុខភាពផ្លូវកាយ និងផ្លូវចិត្ត។

- **បញ្ហាសុខភាពផ្លូវកាយ:** ធ្វើឱ្យបុគ្គលរងគ្រោះមានការឈឺចាប់ដោយសារការបង្ខំឱ្យបម្រើភ្ញៀវច្រើននាក់(បម្រើសេវាកម្មផ្លូវភេទ) ក្នុងមួយថ្ងៃៗ។ លើសពីនេះទៅទៀត ជនរងគ្រោះងាយនឹងឆ្លងជម្ងឺផ្សេងៗតាមរយៈការរួមរ័ក្សជាមួយអតិថិជន ដូចជាជម្ងឺអេដស៍ជាដើម។
- **បញ្ហាផ្លូវចិត្ត:** ជនរងគ្រោះដោយសញ្ជារកម្មដែលត្រូវជនខិលខូច (សញ្ជារិក ឬសញ្ជារិកា) បង្ខំឱ្យប្រព្រឹត្តអំពើពេស្យាចារ បានទទួលរងនូវការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ ជាពិសេសបញ្ហាផ្លូវចិត្តដែលរួមមានដូចជា ការភ័យខ្លាច ការបាក់ទឹកចិត្ត កើតទុក្ខក្រៀមក្រំ ហើយធ្វើឱ្យពួកគេអស់សង្ឃឹមក្នុងការរស់នៅក្នុងសង្គម និងមានគំនិតចង់សម្លាប់ខ្លួនទៀតផង។

#### ២. ប៉ះពាល់ដល់កិត្តិយសគ្រួសារ

ជាការពិតណាស់ បុគ្គលដែលរងគ្រោះដោយ អំពើសញ្ជារកម្ម ត្រូវជាប់ឈ្មោះថាជាជនពេស្យា ប៉ុន្តែឈ្មោះនេះត្រូវបានមនុស្សទូទៅហៅថា **ស្រីបន** ឬ **ស្រីខូច** ដែលបម្រើការងារនៅក្នុងផ្ទះបន។ ដូច្នេះហើយបុគ្គលពេស្យា ត្រូវបានគេចាត់ទុកថាជាស្រីមិនល្អ (ចំពោះនារីភេទ) ដែលធ្វើឱ្យមនុស្សនៅក្នុងសង្គម គេសដៀល មើលងាយ និងស្អប់ខ្ពើមចំពោះបុគ្គលពេស្យា។ ផ្ទុយទៅវិញ ការគិតបែបនេះ មិនត្រឹមត្រូវឡើយ ព្រោះថា បុគ្គលពេស្យា ជាបុគ្គលដែលរងគ្រោះពីការកេងប្រវ័ញ្ច និងរងនូវការរំលោភបំពាន ដោយជនខិលខូច។ ជាទូទៅ នៅក្នុងគ្រួសារណា ដែលមានសមាជិកណាមួយប្រព្រឹត្តអំពើពេស្យាចារ ឬ ធ្លាប់រងគ្រោះដោយអំពើសញ្ជារកម្ម ហើយនាំឱ្យមានការលេច ឮ ជាសាធារណៈ និងធ្វើឱ្យមានការរិះគន់ពីសំណាក់មនុស្សទូទៅថាជាបុគ្គលមិនល្អ ឬ ត្រូវគេដៀលថាជាគ្រួសារដែលមានប្រវត្តិមិនល្អជាដើម។

#### ៣. ឃ្លាតឆ្ងាយពីគ្រួសារ

ជនរងគ្រោះជាបុគ្គលពេស្យា ដែលត្រូវបានមេបនបង្ខំឱ្យបម្រើអតិថិជន ពិតជាកម្រនឹងមានឱកាសបានវិលត្រលប់ទៅផ្ទះជួបជុំក្រុមគ្រួសាររបស់ខ្លួនណាស់ ជាពិសេសបុគ្គលពេស្យាដែលត្រូវបានគេបោកប្រាស់ ឬ ចាប់ពង្រាត់ យកមកលក់ធ្វើជាស្រីបនជាដើម។ ប៉ុន្តែក្នុងករណីខ្លះ បុគ្គលពេស្យាមានសេរីភាពគ្រប់គ្រាន់ក្នុងការជួបជុំជាមួយក្រុមគ្រួសាររបស់ខ្លួន ដោយសារតែគាត់មិនស្ថិតនៅក្រោម ការគាបសង្កត់ ឬ គ្រប់គ្រងដោយមេបនឡើយ។ ឧទាហរណ៍: ការប្រព្រឹត្តពេស្យាចារដោយស្ម័គ្រចិត្ត។

លើសពីនេះទៅទៀត បុគ្គលពេស្យា ដែលត្រូវបានមេបន ឃុំឃាំងខ្លួន នៅក្នុងបន្ទប់ផ្ទះបន គ្មានឱកាសនឹងរត់គេចចេញបានឡើយ ហើយក៏គ្មានសង្ឃឹមថានឹងបានជួបជុំក្រុមគ្រួសារវិញដែរ ដោយហេតុថា ខ្លួនត្រូវគេចាប់ឃុំឃាំងនៅក្នុងបន្ទប់ជាប់ សម្រាប់តែបម្រើឱ្យអតិថិជនប៉ុណ្ណោះ។ ទោះបីជាយ៉ាងណាក៏ដោយ ជនរងគ្រោះអាចនឹងរួចផុតពីការធ្វើបាបរបស់មេបន ប្រសិនបើសមត្ថកិច្ចបានចុះទៅធ្វើការបង្រ្កាបទាន់ពេលវេលា ដែលនៅពេលនោះហើយទើបជនរងគ្រោះ ដែលជាបុគ្គលពេស្យា មានសង្ឃឹមអាចវិលត្រឡប់ទៅជួបជុំក្រុមគ្រួសាររបស់ខ្លួនវិញ។

**កថាខណ្ឌទី ២៖ ចំពោះសង្គម**

**១. បាត់បង់ប្រពៃណី**

ការធ្វើអាជីវកម្មពេស្យាចារ បានជះឥទ្ធិពលមិនត្រឹមតែទៅលើមនុស្សប៉ុណ្ណោះទេ ប៉ុន្តែក៏ធ្វើឱ្យសីលធម៌សង្គម ត្រូវធ្លាក់ចុះផងដែរ ជាពិសេសធ្វើឱ្យប្រពៃណីល្អរបស់ខ្មែរយើង ត្រូវបាត់បង់ថែមទៀត ដោយសារតែសកម្មភាពរួមភេទបែបពាលាអាវាសែនេះហើយ។ ម្យ៉ាងវិញទៀតការប្រព្រឹត្តអំពើទាំងនេះសង្គមខ្មែរយើងមិនឱ្យតម្លៃឡើយ ពីព្រោះថាវានាំឱ្យបាត់បង់សេចក្តីថ្លៃថ្នូររបស់មនុស្សជាពិសេសនារីភេទ។ ការធ្វើអាជីវកម្មលើអំពើពេស្យាចារ ឬអាចហៅម្យ៉ាងទៀតថា អំពើសញ្ចារកម្ម ដែលបានកើតមានឡើង ហើយចាក់ ឫគល់ នៅក្នុងសង្គមខ្មែរជាយូរលង់ណាស់មកហើយ មិនមែនទើបតែកើតមាននាពេលបច្ចុប្បន្នឡើយ សូម្បីតែនៅតាមបណ្តាប្រទេសជាច្រើននៅលើពិភពលោកក៏នៅតែមានការធ្វើអាជីវកម្មផ្លូវភេទនេះផងដែរ ជាឧទាហរណ៍ជាក់ស្តែង ដូចដែលយើងធ្លាប់បានទស្សនាខ្សែភាពយន្តភាគចិន ដែលនៅក្នុងវគ្គខ្លះមានការបង្ហាញពីសកម្មភាពប្រកបអាជីវកម្ម ដោយបើកផ្ទះបន (បនហាងឡូវ) សម្រាប់បម្រើឱ្យអតិថិជន មកកម្សាន្តលេងជាដើម។ សរុបសេចក្តីមកសញ្ចារកម្មជាអំពើដែលមិនគួរឱ្យកើតមានឡើងនៅក្នុងសង្គមខ្មែរឡើយ ដោយសារតែ ឥទ្ធិពលរបស់វាបានធ្វើឱ្យសីលធម៌សង្គមត្រូវធ្លាក់ចុះ ធ្វើឱ្យបាត់បង់ប្រពៃណីទំនៀមទម្លាប់ល្អ ព្រមទាំងធ្វើឱ្យសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិត្រូវបាត់បង់ថែមទៀតផង។

**២. រារាំងដល់ការអភិវឌ្ឍន៍**

ហេតុអ្វីបានជាអំពើសញ្ចារកម្មនាំឱ្យមានការរារាំងដល់ការអភិវឌ្ឍន៍? ដើម្បីធ្វើការឆ្លើយតបទៅនឹងសំណួរនេះ យើងត្រូវយល់ថា សញ្ចារកម្ម គឺជាបទល្មើសមួយ មិនត្រឹមតែធ្វើឱ្យប៉ះពាល់ដល់មនុស្សប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្កនូវផលវិបាកដល់សង្គមទៀតផង ដែលផលប៉ះពាល់ទាំងអស់នោះរួមមាន៖

- បង្កភាពចលាចលដល់សង្គម
- បាត់បង់របៀបរៀបរយសាធារណៈ

- ធ្វើឱ្យបាត់បង់សេចក្ដីថ្លៃថ្នូររបស់មនុស្ស
- ធ្វើឱ្យកើតមាននូវបទល្មើសជាច្រើន ដូចជាៈ ការជួញដូរមនុស្ស អំពើហិង្សា ការលួច ឆក់ប្លន់
- កើតមានអំពើពុករលួយ
- ងាយនឹងធ្វើឱ្យមានការឆ្លងជម្ងឺផ្សេងៗ ( HIV )។

បញ្ហាដូចបានរៀបរាប់ខាងលើនេះ ជាមូលហេតុមួយ ដែលនាំឱ្យមាន ការរាំងស្ទះដល់ការអភិវឌ្ឍន៍ប្រទេសជាតិ ដោយសារតែសង្គមមានភាពវឹកវរ ពោរពេញទៅដោយបទល្មើសកើតឡើងព្រមគ្នាៗជាច្រើន ប្រសិនបើគ្មានការយកចិត្តទុកដាក់ ឬចាត់វិធានការបង្ក្រាបទេ បញ្ហា នឹងរីករាលដាលកាន់តែធំឡើង ហើយពិបាកនិងធ្វើការទប់ស្កាត់ខ្លាំងណាស់។

**៣. ភាពអនាធិបតេយ្យ**

យើងសង្កេតឃើញថា បញ្ហាអនាធិបតេយ្យនេះហើយ ដែលធ្វើឱ្យសង្គមបាត់បង់សណ្ដាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈ។ ដោយឡែកការប្រកបអាជីវកម្មពេស្យាចារវិញ ក៏ជាបញ្ហាមួយដែលនាំឱ្យមានភាពអនាធិបតេយ្យកើតឡើងផងដែរ។ ដោយសារតែ សកម្មភាពទាក់ម៉ូយរបស់បុគ្គលពេស្យានៅក្នុងផ្ទះបន ឬ នៅក្នុងទីកន្លែងណាមួយដែលអាចឱ្យសាធារណជន មើលឃើញ ឬស្ដាប់ឮ ពីសកម្មភាពទាំងអស់នោះ។ ទោះជាយ៉ាងណាក៏ដោយ ការបើកអាជីវកម្មរកស៊ីផ្លូវភេទទាំងនេះ ជាពិសេសផ្ទះបន ត្រូវបានលុបបំបាត់ចោលស្ទើរតែអស់ទាំងស្រុងទៅហើយនាពេលបច្ចុប្បន្ននេះ ប៉ុន្តែក្រោយពីផ្ទះបនត្រូវបានលុបបំបាត់ចោល គេឃើញមានការរកស៊ីផ្លូវភេទតាមបែបថ្មីវិញម្ដង គឺការលួចបង្កប់សេវាកម្មបម្រើផ្លូវភេទ នៅតាមទីកន្លែង ម៉ាស្សា កោសជប់ ក្លឹបខារ៉ាអូខេ និងផ្ទះសំណាក់ជាដើម។ បញ្ហាទាំងអស់នេះហើយ ដែលធ្វើឱ្យសង្គម ពោរពេញទៅដោយភាពអនាធិបតេយ្យ និងបង្កផលវិបាកយ៉ាងខ្លាំងចំពោះសមត្ថកិច្ចក្នុងការចុះទៅបង្ក្រាបទៅលើសកម្មភាពទាំងអស់នោះ។

# ជំពូកទី ៤

# យន្តការទប់ស្កាត់រាល់សកម្មភាពនៃអំពើសញ្ជារកម្ម

ដើម្បីធ្វើការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងទៅនឹង អំពើសញ្ជារកម្មដែលកើតមានឡើងនៅក្នុងសង្គម ក៏ដូចជាអំពើទាំងឡាយ ដែលធ្វើឱ្យបាត់បង់ប្រពៃណី ទំនៀមទម្លាប់ល្អ ឬ ប៉ះពាល់ដល់កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់មនុស្ស ហេតុដូច្នេះហើយ ទើបតម្រូវឱ្យមានយន្តការក្នុងការទប់ស្កាត់ និង បង្ក្រាបរាល់សកម្មភាពនៃបទល្មើសទាំងអស់នោះ ដោយធ្វើការពង្រឹងនូវការអនុវត្តន៍លិខិតបទដ្ឋានគតិយុត្តជាតិ និងអន្តរជាតិ ឱ្យមានប្រសិទ្ធភាព (ផ្នែកទី ១) និង បង្កើតឱ្យមានជាស្ថាប័នសម្រាប់គាំពារដល់ជនដែលងាយរងគ្រោះ ជាពិសេស ស្ត្រី និងកុមារ (ផ្នែកទី ២) ហើយព្រមទាំងបង្កើតឱ្យមាន គណៈកម្មាធិការជាតិ ដែលមានទំនាក់ទំនងជាមួយស្ថាប័នទាំងឡាយក្នុងការប្រយុទ្ធប្រឆាំងទៅនឹងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ (ផ្នែកទី ៣) ម្យ៉ាងវិញទៀតដើម្បីឱ្យយន្តការទប់ស្កាត់រាល់សកម្មភាពនៃអំពើសញ្ជារកម្ម ប្រកបដោយប្រសិទ្ធភាពមួយចំណែកទៀតបានលុះត្រាតែ យើងត្រូវធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងអប់រំដល់ប្រជាពលរដ្ឋ (ផ្នែកទី ៤) ឱ្យមានចំណេះដឹងគ្រប់គ្រាន់ ដើម្បីអាចជៀសផុតពីការកេងប្រវ័ញ្ចផ្សេងៗដោយជនទុច្ចរិត។

អាស្រ័យហេតុនេះហើយ យន្តការមួយចំនួន ដើម្បីធ្វើការទប់ស្កាត់ចំពោះអំពើសញ្ជារកម្មដូចបានរៀបរាប់ខាងលើនឹងត្រូវបានបកស្រាយដូចតទៅនេះៈ

## ផ្នែកទី ១ៈ ពង្រឹងការអនុវត្តន៍ច្បាប់ និងអនុវត្តគោលនយោបាយប្រឆាំងនិងអំពើជួញដូរមនុស្ស

### កថាខណ្ឌទី ១ៈ ការអនុវត្តន៍ច្បាប់ឱ្យមានប្រសិទ្ធភាព

ដើម្បីធ្វើការលុបបំបាត់ និង បង្ក្រាបនូវរាល់បទល្មើសផ្សេងៗដែលកើតមាននៅក្នុងសង្គម ជាពិសេស ការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ត្រូវទាមទារឱ្យមានការអនុវត្តន៍ច្បាប់ឱ្យបានតឹងរឹងបំផុត ពីព្រោះថា ប្រសិនបើ ប្រទេសមានច្បាប់គ្រប់គ្រាន់ហើយ ប៉ុន្តែបែរជាមិនយកច្បាប់ទាំងនោះមកអនុវត្ត ឬអនុវត្តមិនបានតឹងរឹង នាំឱ្យជនល្មើស រួចផុតពីការទទួលខុសត្រូវ និងមិនមានការភ័យខ្លាចក្នុងការប្រព្រឹត្តបទល្មើស ហើយថែមទាំងបង្កនូវបទល្មើសកើតឡើង ត្រង់ចំណុចនេះយើងអាចចោទជាសំណួរឡើងថា តើច្បាប់មានន័យអ្វីទៅ ប្រសិនបើគ្មានការអនុវត្តន៍?

ជាការពិតណាស់ចំពោះបទល្មើសជួញដូរមនុស្ស ឬ ការធ្វើអាជីវកម្មផ្លូវភេទជាអាទិ៍ ត្រូវបានដាក់បញ្ចូលទៅក្នុងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៨ និងក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩ ផងដែរ។

លើសពីនេះទៅទៀត ប្រទេសកម្ពុជាបានចូលរួមក្នុងការអនុវត្តន៍នូវលិខិតបទដ្ឋានអន្តរជាតិផ្សេងៗជាច្រើនដូចជា: សន្ធិសញ្ញាប៉ាឡឺម៉ូ អនុសញ្ញាអន្តរជាតិ ឬកិច្ចព្រមព្រៀងដែលទាក់ទងនឹងការជួញដូរមនុស្ស -ល-។ ម្យ៉ាងវិញទៀត ប្រទេសកម្ពុជាក៏ជាភាគី នៃអនុស្សារណៈនៃការយោគយល់គ្នា ស្ដីពីកិច្ចសហប្រតិបត្តិការប្រឆាំង អំពើជួញដូរមនុស្ស នៅមហាអនុតំបន់ទន្លេមេគង្គ ប្រឆាំងអំពើជួញដូរមនុស្ស ដែលរួមមានប្រទេសជាភាគីដូចជា សាធារណៈរដ្ឋប្រជាមានិតចិន សាធារណៈរដ្ឋប្រជាធិបតេយ្យឡាវ សហភាពភូមា ព្រះរាជាណាចក្រថៃឡង់ និងសាធារណៈរដ្ឋសង្គមនិយមវៀតណាម។

យើងសង្កេតឃើញថា បញ្ហាជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ឬការកេងប្រវ័ញ្ចផ្សេងៗជាប្រធានបទមួយដែលពេញនិយមណាស់នាពេលបច្ចុប្បន្ននេះ ហើយធ្វើឱ្យមជ្ឈដ្ឋានជាតិ និង អន្តរជាតិមានការចាប់អារម្មណ៍យ៉ាងខ្លាំង ជាពិសេស ការបង្កើតឡើងនូវបទដ្ឋានគតិយុត្តផ្សេងៗ ដើម្បីទប់ស្កាត់ និងធ្វើការប្រយុទ្ធប្រឆាំងទៅលើបញ្ហាទាំងអស់នោះ។ យ៉ាងណាមិញ ទោះបីជាយើងមានទាំងច្បាប់ជាតិ និងអន្តរជាតិ ដើម្បីធានានូវសិទ្ធិការពារខាងផ្លូវច្បាប់ក៏ដោយ ប៉ុន្តែមិនទាន់បានឆ្លើយតបទៅនឹងស្ថានភាពជាក់ស្ដែងនៅឡើយទេ។

**កថាខណ្ឌទី ២៖ គោលនយោបាយរបស់រាជរដ្ឋាភិបាល**

ដើម្បីធ្វើការឆ្លើយតបទៅនឹងបញ្ហា សន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ និងបញ្ហាដែលតែងតែកើតមានជារឿយៗនៅក្នុងសង្គម រួមមាន អំពើលួច ឆក់ ប្លន់ អំពើហិង្សា គ្រឿងញៀន ការជួញដូរមនុស្ស ឬការធ្វើអាជីវកម្មផ្លូវភេទជាដើម រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយ **ភូមិ ឃុំ មានសុវត្ថិភាព** ដើម្បីជម្រុញឱ្យមានការការពារ សន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ នៅគ្រប់ច្រកល្ហក់ ទូទាំងប្រទេស។

យោងតាមផែនការណែនាំស្ដីពីការចាត់តាំងអនុវត្តគោលនយោបាយ **ភូមិ ឃុំ មានសុវត្ថិភាព** របស់ក្រសួងមហាផ្ទៃ បានលើកឡើងពីគោលបំណងសំខាន់ៗ ដើម្បីអនុវត្តគោលនយោបាយ **ភូមិ ឃុំមានសុវត្ថិភាព** ឱ្យបានជោគជ័យ តាមរយៈ ការបន្តកសាង និង ពង្រឹងសុខសុវត្ថិភាពជូនប្រជាពលរដ្ឋ នៅគ្រប់ទីកន្លែង និងគ្រប់ពេលវេលា ដោយការលុបបំបាត់បទល្មើសគ្រប់ប្រភេទក្នុងមូលដ្ឋាន ភូមិ ឃុំ សង្កាត់ ទូទាំងព្រះរាជាណាចក្រកម្ពុជា និងបំផុសឱ្យមានកិច្ចសហការចូលរួមជាមួយសមត្ថកិច្ច ពីគ្រប់សមាសភាពផ្សេងៗ ទាំងក្នុងជួររដ្ឋាភិបាល គណបក្សនយោបាយ អង្គការក្រៅរដ្ឋាភិបាល ឯកជន និងប្រជាពលរដ្ឋគ្រប់រូបដើម្បីកសាងបានជាកម្លាំងសរុប វិធានការសរុប និងមធ្យោបាយសរុប ក្នុងការអនុវត្តន៍គោលនយោបាយ **ភូមិ ឃុំមានសុវត្ថិភាព**។

ទោះបីជាយ៉ាងណាក៏ដោយ រាល់បទល្មើសទាំងឡាយ ដែលកើតមាននៅក្នុងសង្គម ជាពិសេស អំពើសញ្ចារកម្ម អំពើអនាចារ ការជួញដូរស្ត្រី និងកុមារ ឬការធ្វើអាជីវកម្មផ្លូវភេទជាអាទិ៍

រាជរដ្ឋាភិបាលត្រូវតែចាត់វិធានការ លុបបំបាត់ចោល ដើម្បីការពារសន្តិសុខ សុវត្ថិភាពជូនប្រជាជន ជាពិសេសស្ត្រីនិងកុមារ ឱ្យរួចផុតពីការជួញដូរ អំពើរត់ពន្ធ ការធ្វើអាជីវកម្មផ្លូវភេទ ដោយការអនុវត្តន៍ច្បាប់ឱ្យបានម៉ឺងម៉ាត់ និងមានប្រសិទ្ធភាព។

កាលពីឆ្នាំ ២០០៨ ក្រសួងមហាផ្ទៃ បានចេញនូវគោលការណ៍ណែនាំស្តីពី ការអនុវត្តន៍ដោយបញ្ជាក់យ៉ាងច្បាស់ពីសកម្មភាពរបស់សមត្ថកិច្ច ក្នុងការចុះទៅបង្ក្រាប ករណីដែលមានអំពើសញ្ចារកម្ម ឬអំពើពេស្យាចារ ដោយត្រូវធ្វើឡើងតែ ក្នុងករណី ៤ ដូចខាងក្រោម៖

- ប្រសិនបើ មានបណ្តឹងពីអ្នកជិតខាង ទៅលើសកម្មភាពអំពើ ពេស្យាចារ ដែលធ្វើឱ្យប៉ះពាល់ដល់ការរស់នៅប្រចាំថ្ងៃ។
- ប្រសិនបើ មានបណ្តឹងពីជនរងគ្រោះ ដែលត្រូវបានបង្ខំឱ្យប្រព្រឹត្ត អំពើពេស្យាចារនៅតំបន់នោះ
- ប្រសិនបើមានអំពើពេស្យាចារកុមារ
- ប្រសិនបើ អំពើពេស្យាចារនាំឱ្យមានភាពឥតសណ្តាប់ធ្នាប់ អសន្តិសុខសាធារណៈ។

ក្រៅពីនេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវ **យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣** និងកម្មវិធីនយោបាយ ដើម្បីធ្វើការលើកម្ពស់ឱ្យមានការចូលរួម ក្នុងការការពារសន្តិសុខជាតិ និងបន្ត អនុវត្តគោលនយោបាយ **ភូមិ ឃុំ មានសុវត្ថិភាព** ដោយពង្រឹងវិធានការ ទប់ស្កាត់ និងបង្ក្រាបរាល់បទល្មើសទាំងឡាយដែលកើតមាននៅក្នុងសង្គម ហើយព្រមទាំងជម្រុញឱ្យមានការអនុវត្តន៍គោលនយោបាយជាតិប្រជាជន និងសមភាពយេនឌ័រ ដើម្បីលើកស្ទួយស្ត្រី។ ក្នុងការលើកស្ទួយស្ថានភាពស្ត្រី ឆ្នាំ ២០១៤ ដល់២០១៨ នេះ រាជរដ្ឋាភិបាលបានអនុវត្ត **នារីរតនៈទី ៤** ដែលជាផែនការយុទ្ធសាស្ត្ររយៈពេល ៥ ឆ្នាំ ដើម្បីសមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រីនៅកម្ពុជា។

**កថាខណ្ឌទី ៣៖ បញ្ហាប្រឈមផ្សេងៗ**

ការលុបបំបាត់សកម្មភាពបទល្មើសនៅក្នុងសង្គម ជាគោលដៅសំខាន់ដែលរាជរដ្ឋាភិបាលត្រូវតែ ធានា និងធ្វើការចាត់វិធានការដើម្បីបង្ក្រាប នូវសកម្មភាពនៃបទល្មើសដែលតែងតែកើតមានឡើង ជាពិសេសបញ្ហាការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទជាដើម។ ទន្ទឹមនឹងនេះរាជរដ្ឋា-ភិបាលកម្ពុជាបានដាក់ចេញនូវគោលនយោបាយប្រយុទ្ធប្រឆាំង និង បង្ក្រាប នូវរាល់បទល្មើសទាំងឡាយដែលរួមមាន គោលនយោបាយ **ភូមិ ឃុំមានសុវត្ថិភាព** ដែលមានលក្ខណៈសម្បត្តិ ៥ យ៉ាងគឺ: **ទី១** គ្មានសកម្មភាព លួច ឆក់ ប្លន់គ្រប់ប្រភេទ **ទី២** គ្មានការផលិត ការចែកចាយ និងប្រើប្រាស់គ្រឿងញៀនខុសច្បាប់ **ទី៣** គ្មានអំពើអនាចារ ការជួញដូរ ស្ត្រី និងកុមារ និងអំពើហិង្សាក្នុង

គ្រួសារ **ទី៤** គ្មានក្មេងទំនើង **ទី៥** គ្មានការលេងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ គ្មានការប្រើប្រាស់អាវុធខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ។ ក្រៅពីនេះយើងឃើញថាមានការរៀបចំនូវផែនការដើម្បីអនុវត្តសកម្មភាពក្នុងការលុបបំបាត់បទល្មើសទាំងឡាយ ដូចបានកំណត់ក្នុងផែនការណែនាំស្តីពីការចាត់តាំងអនុវត្តគោលនយោបាយ ភូមិ ឃុំមានសុវត្ថិភាព។

ផ្ទុយទៅវិញ ទោះបីជារាជរដ្ឋាភិបាលបានខិតខំ ព្យាយាម ចាត់វិធានការ បង្ក្រាបបទល្មើសតាមមធ្យោបាយបែបណាក៏ដោយ ទោះជាដាក់ចេញនូវគោលនយោបាយ ភូមិ ឃុំមានសុវត្ថិភាពដើម្បីលុបបំបាត់បទល្មើសដែលកើតមាននៅក្នុងសង្គមក្តី ឬ ការចាត់វិធានការផ្សេងៗ ក៏នៅតែមានបទល្មើសជាច្រើនកើតឡើងដដែល។ ជាឧទាហរណ៍ អំពើឃាតកម្ម ឆក់ប្លន់ គ្រឿងញៀន បញ្ហាពេស្យាចារ ឬសញ្ជារកម្ម ល។ បញ្ហាដូចបានរៀបរាប់ទាំងអស់នេះបានកើតចេញពីកត្តាច្រើនយ៉ាងដែលធ្វើឱ្យមានការលំបាក ក្នុងការលុបបំបាត់បទល្មើស ដោយហេតុមកពី ភាពខ្វះចន្លោះនៃច្បាប់ការអនុវត្តន៍ច្បាប់នូវមានកម្រិត បញ្ហាអំពើពុករលួយ ឬកង្វះខាតផ្នែកវិស័យអប់រំ និងការផ្សព្វផ្សាយជាដើម។

## ផ្នែកទី ២៖ ស្ថាប័នជាតិគាំពារស្ត្រី និង ជនខាយរងគ្រោះ

### កថាខណ្ឌទី ១៖ ក្រសួងកិច្ចការនារី

ក្រសួងកិច្ចការនារីជាស្ថាប័នជាតិ ដែលត្រូវបានបង្កើតឡើងដោយព្រះរាជក្រមលេខ នស/រកម/០១០៥/០០២ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥។ ក្រសួងកិច្ចការនារីបង្កើតឡើងក្នុងគោលបំណងដើម្បីលើកកម្ពស់ស្ថានភាពស្ត្រី នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ក្រសួងកិច្ចការនារីត្រូវបានដឹកនាំដោយរដ្ឋមន្ត្រីមួយរូបដែលអមដោយរដ្ឋលេខាធិការ និង/ឬអនុរដ្ឋលេខាធិការតាមការចាំបាច់[40]។

**ក្រសួងកិច្ចការនារី មានមុខងារ និងភារកិច្ចៈ**

- ធ្វើជាសេនាធិការជូនរាជរដ្ឋាភិបាល ក្នុងការអនុវត្តន៍គោលនយោបាយជាតិ ដើម្បីធានាឱ្យស្ត្រីទទួលបាននូវផលប្រយោជន៍ដូចបុរស និងលើកកម្ពស់ស្ថានភាពរបស់ស្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។
- ជម្រុញ សម្របសម្រួល តស៊ូមតិដើម្បីស្វែងរកការគាំទ្រ តាមដាន និងត្រួតពិនិត្យការវាយតម្លៃការអនុវត្តន៍គោលនយោបាយជាតិ និងកម្មវិធីផ្សេងៗ ក្នុងគោលដៅលើកកម្ពស់ស្ថានភាពស្ត្រី។

[40] មាត្រា ៣ នៃច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥

- សម្របសម្រួល និងសហការជាមួយក្រសួង ស្ថាប័ន អង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ មន្ទីរខេត្ត ក្រុង ក្រុមប្រឹក្សា ឃុំ សង្កាត់ គណៈកម្មការអភិវឌ្ឍដែលពាក់ព័ន្ធនានា ដើម្បីបញ្ជ្រាបយេនឌ័រ ទៅក្នុងគោលនយោបាយជាតិ គោលនយោបាយមូលដ្ឋាន និងកម្មវិធីផ្សេងៗព្រមទាំងដើម្បីបង្កើនសមាមាត្រ នៃការចូលរួមរបស់ស្ត្រីឱ្យបានជាអតិបរមាក្នុងក្រសួង ស្ថាប័នជាតិគ្រប់ថ្នាក់ តាំងពីថ្នាក់កណ្តាល រហូតដល់មូលដ្ឋាន។
- សិក្សាស្រាវជ្រាវ រៀបចំគោលនយោបាយ និងកម្មវិធីផ្សេងៗ ដើម្បីកាត់បន្ថយគម្លាតយេនឌ័រ និងបង្កើនឋានៈតួនាទីរបស់ស្ត្រី។
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការក្រៅរដ្ឋាភិបាល និងសង្គមស៊ីវិល ជម្រុញដំណើរការកម្មវិធី ជួយដល់ស្ត្រី ជាពិសេសចាស់ជរា ឬគ្មានទីពឹង ឬពិការ ឬមេម៉ាយ ស្ត្រី និងកុមាររងគ្រោះដោយជម្ងឺអេដស៍ ដោយការជួញដូរ រងគ្រោះពីរាល់ទម្រង់នៃអំពើហិង្សាប្រឆាំងនឹងស្ត្រី រួមមានការចាប់រំលោភសេពសន្ថវៈ និងអំពើហិង្សាក្នុងគ្រួសារជាដើម។
- ចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ តាមរយៈការលើកម្ពស់ការអភិវឌ្ឍន៍សហគ្រាសខ្នាតតូច និងមធ្យោបាយផ្តល់ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ផ្តល់លទ្ធភាពក្នុងការទទួលសេវាឥណទាន និងបង្កើតមុខរបរសម្រាប់ស្ត្រី។
- រៀបចំកម្មវិធីអប់រំ និងផ្សព្វផ្សាយពត៌មាន ប្រឆាំង ទប់ស្កាត់នឹងអំពើហិង្សាក្នុងគ្រួសារ និងការពារជនរងគ្រោះ។
- ជម្រុញឱ្យស្ត្រី និងកុមារ ទទួលនូវសិទ្ធិការពារតាមផ្លូវច្បាប់ និងដោយយុត្តិធម៌ តាមរយៈធ្វើជាអ្នកដើមបណ្តឹងជូសមុខឱ្យជនរងគ្រោះទៅតុលាការ និងការដាក់បញ្ចូលទៅក្នុងច្បាប់ ការអនុវត្តន៍ច្បាប់ ការបណ្តុះបណ្តាល ការផ្សព្វផ្សាយ និងការអប់រំជាអតិបរមា។
- ជម្រុញឱ្យស្ត្រី និងកុមារ ទទួលការថែទាំសុខភាពបឋម ការប្រើប្រាស់សេវាថែទាំក្នុងការធ្វើឱ្យប្រសើរឡើងនូវសុខុមាលភាព ជាពិសេសសុខភាពបន្តពូជ និងការទប់ស្កាត់ការឆ្លងមេរោគអេដស៍ និងការលើស្ទួយស្ថានភាពអាហាររូបត្ថម្ភរបស់ស្ត្រី និងកុមារ។
- ជម្រុញការចូលរៀន និងកាត់បន្ថយការបោះបង់ចោលការសិក្សារបស់សិស្សស្រីនៅគ្រប់កម្រិតចាប់ពីបឋមសិក្សារហូតដល់ឧត្តមសិក្សា ព្រមទាំងបង្កើនអក្ខរភាព និងជំនាញរបស់ស្ត្រី។

- លើកម្ពស់សីលធម៌សង្គម និងតម្លៃគ្រួសារខ្មែរ តាមរយៈការផ្សព្វផ្សាយពត៌មានគ្រប់រូបភាព ដូចជា ឯកសារបោះពុម្ព វិទ្យុ ទូរទស្សន៍ និងប្រព័ន្ធផ្សព្វផ្សាយពត៌មានទំនើប។ល។ និងលើកទឹកចិត្តស្ត្រីឱ្យចូលរួមក្នុងការរៀបចំកម្មវិធីនេះ។
- ជម្រុញការអនុវត្តន៍អនុសញ្ញាអន្តរជាតិ ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីដែលព្រះរាជាណាចក្រកម្ពុជា ជាភាគីហត្ថលេខី នាថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩២ និងពិធីសារអង្គការសហប្រជាជាតិ ស្តីពីការទប់ស្កាត់ ការបង្ក្រាប និងការដាក់ទណ្ឌកម្ម ការជួញដូរមនុស្ស ពិសេសស្ត្រីនិងកុមារ បំពេញបន្ថែមឱ្យអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីការប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន ដែលមានការចាត់តាំង ព្រមទាំងច្បាប់ និងអនុសញ្ញាអន្តរជាតិដទៃទៀត ដែលការពារសិទ្ធិ និងផលប្រយោជន៍របស់ស្ត្រី និងកុមារ[41]។

**កថាខណ្ឌទី ២៖ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានបង្កើតឡើងតាមព្រះរាជក្រមលេខ នស/រកត/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ និងអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នា ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវបានរាជរដ្ឋាភិបាលកម្ពុជា ប្រគល់បេសកកម្មឱ្យដឹកនាំគ្រប់គ្រងវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៃព្រះរាជាណាចក្រកម្ពុជា[42]។

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាមានមុខងារ និងភារកិច្ចដូចតទៅ៖**

**ក. វិស័យសង្គមកិច្ច**

- រៀបចំគោលនយោបាយ និងដឹកនាំ គ្រប់គ្រងរាល់សេវាសង្គមកិច្ចរបស់រដ្ឋ ដើម្បីជួយដល់ប្រភេទជនងាយរងគ្រោះនិងជនក្រីក្រ ជាអាទិ៍ ជនចាស់ជរាគ្មានទីពឹង ជនពិការ ជនរស់នៅតាមចិញ្ចើមថ្នល់ កុមារកំព្រា កុមារតាមចិញ្ចើមថ្នល់ ស្រីពេស្យា ជនដែលផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ និងមានមេរោគឆ្លងកាចសាហាវ ជនក្រីក្រជួបការលំបាកជាងគេក្នុងសង្គម ។

[41] មាត្រា ៣ នៃអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកិច្ចការនារី ចុះថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ២០០៥

[42] មាត្រា ២ នៃអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១១

- រៀបចំអនុវត្តគោលនយោបាយស្តីពីគ្រួសារ ជនចាស់ជរា ។
- រៀបចំលិខិតបទដ្ឋាននិងគ្រប់គ្រងការងារសុំកូនទៅចិញ្ចឹមនៅក្នុងនិងក្រៅប្រទេស ។
- រៀបចំសេវាសង្គមកិច្ច ដើម្បីថែរក្សា ការពារ និងអប់រំ កុមារកំព្រា កុមាររងគ្រោះដោយអំពើជួញដូរ ដោយជំងឺអេដស៍ កុមារពិការ និងចិញ្ចឹមបីបាច់ថែរក្សាទារកដែលត្រូវគេបោះបង់ចោល ។
- រៀបចំគោលការណ៍គាំពារជនពិការ អនុវត្តការងារស្តារលទ្ធភាព ពលកម្ម បង្កលក្ខណៈខាងជីវភាពរស់នៅដល់ជនពិការគ្រប់ប្រភេទ ។
- សហការជាមួយស្ថាប័នពាក់ព័ន្ធចាត់វិធានការផ្លូវច្បាប់ក្នុងការ ទប់ស្កាត់អំពើពេស្យាចារ ការជួញដូរមនុស្ស ការរំលោភផ្លូវភេទលើកុមារ ការប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍ ។
- សហការជាមួយស្ថាប័នពាក់ព័ន្ធ ជួយដល់ជនរងគ្រោះដោយភយន្តរាយផ្សេងៗ មានគ្រោះថ្នាក់ធម្មជាតិ និងគ្រោះថ្នាក់ផ្សេងៗទៀត ។
- សហការជាមួយស្ថាប័ននិងអង្គការពាក់ព័ន្ធនឹងការអនុវត្តន៍សិទ្ធិកុមារ ។
- គ្រប់គ្រងរបបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ សម្រាប់មន្ត្រីរាជការ តាមការកំណត់របស់ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា ។
- គ្រប់គ្រងរបបធានារ៉ាប់រងសង្គម ដល់កូនកំព្រាពីសពមន្ត្រីរាជការ ។
- ដឹកនាំគ្រប់គ្រង និងសហការជាដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាល អង្គការជាតិ អន្តរជាតិ ដែលធ្វើសកម្មភាពលើវិស័យសង្គមកិច្ច ជាអាទិ៍ ការផ្តល់ព័ត៌មាន ការប្រាប់បង្ហាញ ការណែនាំ និងការផ្តល់សេវា សង្គមកិច្ចនានា ។
- បំផុសការចូលរួមសកម្មភាពសាមគ្គីធម៌សង្គម លើកទឹកចិត្ត និងធ្វើជាដៃគូជាមួយអង្គការមនុស្សធម៌ សហគមន៍មូលដ្ឋាន ក្នុងការបង្កើតមូលនិធិទ្រទ្រង់ដល់សេវាសង្គមកិច្ចនានា ដើម្បីជួយដល់ជនងាយរងគ្រោះគ្រប់ប្រភេទ ។

**ខ. វិស័យអតីតយុទ្ធជន**

- រៀបចំដាក់ឱ្យដំណើរការ សម្របសម្រួលគោលនយោបាយជាតិស្តីពីអតីតយុទ្ធជន។
- រៀបចំបញ្ចូលអតីតយុទ្ធជន និងគ្រួសារទៅក្នុងសហគមន៍ ដោយលើកកម្ពស់ស្ថានភាពរស់នៅឱ្យបានល្អប្រសើរនិងគ្មានការរើសអើង តាមរយៈការបណ្តុះបណ្តាលវិជ្ជាជីវៈ ការដោះស្រាយការងារធ្វើ និងបង្កើតមុខរបរ ។

- លើកគោលការណ៍អប់រំណែនាំអតីតយុទ្ធជន ឱ្យយល់ពីតម្លៃកាតព្វកិច្ច តួនាទីក្នុងគ្រួសារ សហគមន៍ និងសង្គមដើម្បីទទួលបានការអភិវឌ្ឍន៍។
- គ្រប់គ្រងរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារសម្រាប់យោធិននៃកងយោធពលខេមរភូមិន្ទ តាមការកំណត់របស់ច្បាប់ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ។
- គ្រប់គ្រងនិងដោះស្រាយគោលនយោបាយជូនជនពលី មរណៈ បង្កស្លាប់ បាត់ខ្លួន ពិការនិងគ្រួសារនៃកងយោធពលខេមរភូមិន្ទ កងកម្លាំងនគរបាលជាតិ មន្ត្រីរាជការស៊ីវិល កងសេនាជន កងជីវពលដែលបានបូជាជីវិតដើម្បីប្រទេសជាតិ ។

**គ. វិស័យយុវនីតិសម្បទា**

- គ្រប់គ្រងក្មេងពីអាយុ ៧ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ ដែលបានប្រព្រឹត្តបទល្មើស ពាលអនាថា អបាយមុខ ក្នុងទូទាំងប្រទេស និងមានតួនាទីកែប្រែ អប់រំ ដើម្បីឱ្យក្លាយទៅជាពលរដ្ឋល្អ ។
- បង្កើតមណ្ឌលទទួលអប់រំកុមារតាមការចាំបាច់ ដើម្បីទទួលយកកុមារដែលបានប្រព្រឹត្តអំពើខុសឆ្គងមកគ្រប់គ្រង អប់រំ និងបណ្តុះបណ្តាល ។
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការជាតិ អន្តរជាតិ បង្កើតកម្មវិធីអប់រំបណ្តុះបណ្តាលអនីតិជន ។
- សហការជាមួយស្ថាប័នពាក់ព័ន្ធ រៀបចំបណ្តុះបណ្តាលវិជ្ជាជីវៈ ដល់ទណ្ឌិតតាមពន្ធនាគារ ។
- កសាងច្បាប់ លិខិតបទដ្ឋានពាក់ព័ន្ធទៅនឹងការគ្រប់គ្រងវិស័យយុវនីតិសម្បទា ។
- បង្កើត និងគ្រប់គ្រងមណ្ឌលស្តារនីតិសម្បទា អ្នកញៀនគ្រឿងញៀន និង សមាហរណកម្មជនរងគ្រោះទាំងនោះទៅក្នុងសហគមន៍ [43]។

**កថាខណ្ឌទី ៣៖ ក្រសួងមហាផ្ទៃ**

ក្រសួងមហាផ្ទៃ ត្រូវបានបង្កើតឡើងដោយព្រះរាជក្រម នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ នាសម័យប្រជុំលើកទី ៥ ក្នុងនីតិកាលទី ១ ដែលមានបេសកម្មដឹកនាំ គ្រប់គ្រងរដ្ឋបាលដែនដីគ្រប់ថ្នាក់ លើវិស័យនយោបាយរដ្ឋបាល គ្រប់គ្រងកងកម្លាំងនគរបាលជាតិលើវិស័យសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈនិងសុវត្ថិភាពសង្គមក្នុងព្រះរាជាណាចក្រកម្ពុជា[44]។

[43] មាត្រា ៣ នៃអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១១

[44] មាត្រា ៤ នៃអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងមហាផ្ទៃ ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥

**ក្រសួងមហាផ្ទៃមានតួនាទីភារកិច្ចៈ**

- ដឹកនាំ សម្របសម្រួល គាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យអនុវត្តមុខងារត្រឹមត្រូវតាមច្បាប់ ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា។
- បញ្ជា ដឹកនាំ កងកម្លាំងនគរបាលជាតិ គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានីខេត្តព្រមទាំងសហការសម្របសម្រួលជាមួយសមត្ថកិច្ចពាក់ព័ន្ធដទៃទៀត ក្នុងការថែ រក្សាការពារសន្តិសុខជាតិ ពង្រឹងសណ្តាប់ធ្នាប់សាធារណៈ និងធានាសុវត្ថិភាពសង្គមក្នុងព្រះរាជាណាចក្រកម្ពុជា។
- បញ្ជា ដឹកនាំ កម្លាំងមានសមត្ថកិច្ចក្នុងការគ្រប់គ្រងការងារអត្តសញ្ញាណកម្ម និងការងារសញ្ជាតិ។
- បញ្ជា ដឹកនាំ កម្លាំងមានសមត្ថកិច្ចក្នុងការគ្រប់គ្រង ដឹកនាំការងារអន្តោប្រវេសន៍ និងការងារជនភាសខ្លួន។
- បញ្ជា ដឹកនាំ ដល់អង្គភាពពាក់ព័ន្ធចំណុះក្រសួងមហាផ្ទៃ និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវារដ្ឋបាលប្រកបដោយគុណភាព តម្លាភាព ប្រសិទ្ធភាព និងឆ្លើយតបទាន់ពេលវេលាទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។
- ចុះបញ្ជីគណបក្សនយោបាយ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងតាមដានត្រួតពិនិត្យការអនុវត្តន៍ឱ្យបានត្រឹមត្រូវតាមច្បាប់ជាធរមាន និង លក្ខន្តិកៈរបស់ខ្លួន។
- ពិនិត្យ និងចូលរួមលើកយោបល់ពាក់ព័ន្ធនីតិវិធី និងដំណើរការនៃការបោះឆ្នោត
- ធ្វើអធិការកិច្ច ទទួលនិងដោះស្រាយពាក្យបណ្តឹងតវ៉ា បណ្តឹងបរិហាររបស់ពលរដ្ឋដែលពាក់ព័ន្ធនឹងមន្ត្រីក្នុងក្របខណ្ឌក្រសួងមហាផ្ទៃ។
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការរៀបចំទីតាំងភូមិឋានរបស់ប្រជាពលរដ្ឋ ឱ្យស្របទៅតាមលក្ខណៈភូមិសាស្ត្រ ទំនៀមទម្លាប់ ប្រពៃណី វប្បធម៌សាសនារបស់ប្រជាពលរដ្ឋ។
- បញ្ជា ដឹកនាំ គ្រប់គ្រងការងារពន្ធនាគារ នៅក្នុងព្រះរាជាណាចក្រកម្ពុជាធ្វើការបណ្តុះបណ្តាលធនធានមនុស្សទាំងមន្ត្រីរដ្ឋបាលស៊ីវិល មន្ត្រីបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិមន្ត្រីនគរបាលជាតិ និងមន្ត្រីពន្ធនាគារនៃក្របខណ្ឌក្រសួងមហាផ្ទៃ។

- រៀបចំស្នើ ឬតែងតាំងមុខតំណែង ដំឡើង ឋានន្តរស័ក្តិ ផ្ទេរ ផ្លាស់ប្តូរភារកិច្ច លើកសរសើរ ជូន រង្វាន់ ដាក់វិន័យ បន្ថយឋានៈ ឋានន្តរស័ក្តិ ដកហូតមុខតំណែង បណ្តេញចេញពីក្របខណ្ឌ ព្រមទាំងការប្រឡងជ្រើសរើសក្របខណ្ឌមន្ត្រីរដ្ឋបាលស៊ីវិល មន្ត្រីនគរបាលជាតិ និងមន្ត្រីពន្ធនាគារ តាមច្បាប់ជាធរមាន។
- ធ្វើការងារភស្តុភារ ហិរញ្ញវត្ថុ ការផ្សព្វផ្សាយអប់រំ ការងារសុខាភិបាល ការងារសំណង់និងវិស្វកម្មព្រមទាំងគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។
- ធ្វើការងារសវនកម្មផ្ទៃក្នុង លើការងារគ្រប់គ្រងហិរញ្ញវត្ថុ ការងារគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ព្រមទាំងការងារគ្រប់គ្រងបញ្ជីបុគ្គលិក នៅគ្រប់អង្គភាពដែលស្ថិតក្នុងដែនសមត្ថកិច្ចក្រសួងមហាផ្ទៃ។
- លើកគោការណ៍ វិធានការ និងការអនុវត្តន៍ការងារសម្ងាត់ជាតិ ស្របតាមច្បាប់។
- រក្សាការពារសុវត្ថិភាពថ្វាយព្រះមហាក្សត្រ ជូនថ្នាក់ដឹកនាំជាន់ខ្ពស់ជាតិ អន្តរជាតិ និងការពារស្ថាប័នជាតិគោលដៅនយោបាយ ការទូត សេដ្ឋកិច្ច វប្បធម៌ ពាណិជ្ជកម្ម ទេសចរណ៍ ការពារកម្មវិធីសំខាន់ៗរបស់ជាតិ អន្តរជាតិ និងជនបរទេសដែលស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- ដឹកនាំការងារគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ គ្រាប់រំសេវរបស់កងកម្លាំងនគរបាលជាតិ ស្ថាប័នសាធារណៈ មន្ត្រី និងជនស៊ីវិល ការងារបង្ការ ពន្លត់អគ្គីភ័យ ការងារសង្គ្រោះ ការងារស្វែងរកមនុស្សបាត់ខ្លួន ការងារសណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈ និងសុវត្ថិភាពចរាចរណ៍ផ្លូវគោក ផ្លូវទឹក ផ្លូវដែក តាមបទដ្ឋានគតិយុត្ត។
- កំណត់វិធានការដឹកនាំ និងគ្រប់គ្រងការងារនគរបាលព្រំដែន រួមចំណែកការពារបូរណភាពទឹកដីអធិបតេយ្យជាតិនៃព្រះរាជាណាចក្រកម្ពុជា ស្របតាមច្បាប់ជាតិ អន្តរជាតិ និងថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់តាមបណ្តោយព្រំដែន។
- សិក្សា ស្រាវជ្រាវ កែសម្រួល ឬធ្វើវិសោធនកម្ម ឬកសាងច្បាប់ លិខិតបទដ្ឋាន តាមដានការអនុវត្តន៍ ច្បាប់ លិខិតបទដ្ឋាន និងផ្សព្វផ្សាយច្បាប់ លិខិតបទដ្ឋាននានាក្នុងដែនសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ។
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារ និងលើកទិសដៅបន្តលើគ្រប់វិស័យរបស់ក្រសួងមហាផ្ទៃ។
- ទទួលអនុវត្តភារកិច្ច និងសិទ្ធិផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់ឱ្យ[45]។

[45] មាត្រា ៥ នៃអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងមហាផ្ទៃ ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥

## ផ្នែកទី ៣៖ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ត្រូវបានបង្កើតឡើង ដោយព្រះរាជក្រឹត្យលេខ នស/រកត/០៦១៤/៨០៨ ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៤។

### កថាខណ្ឌទី ១៖ សមាសភាព

**គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សមានសមាសភាពដូចខាងក្រោម៖**

| | | |
|---|---|---|
| ១. រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | | ប្រធាន |
| ២. រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | | អនុប្រធាន |
| ៣. រដ្ឋមន្ត្រីក្រសួងកិច្ចការនារី | | អនុប្រធាន |
| ៤. រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | | អនុប្រធាន |
| ៥. រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | | អនុប្រធាន |
| ៦. រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា | | អនុប្រធាន |
| ៧. រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ១រូប | អនុប្រធានអចិន្ត្រៃ |
| ៨. អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ | | អនុប្រធាន |
| ៩. រដ្ឋលេខាធិការក្រសួងសុខាភិបាល | ១រូប | សមាជិក |
| ១០. រដ្ឋលេខាធិការក្រសួងទេសចរណ៍ | ១រូប | សមាជិក |
| ១១. រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ១រូប | សមាជិក |
| ១២. រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | ១រូប | សមាជិក |
| ១៣. រដ្ឋលេខាធិការក្រសួងការពារជាតិ | ១រូប | សមាជិក |
| ១៤. រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១រូប | សមាជិក |
| ១៥. រដ្ឋលេខាធិការក្រសួងផែនការ | ១រូប | សមាជិក |
| ១៦. រដ្ឋលេខាធិការក្រសួងពត៌មាន | ១រូប | សមាជិក |
| ១៧. រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ១រូប | សមាជិក |
| ១៨. រដ្ឋលេខាធិការក្រសួងអភិវឌ្ឍជនបទ | ១រូប | សមាជិក |
| ១៩. រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | ១រូប | សមាជិក |
| ២០. រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម និងសិប្បកម្ម | ១រូប | សមាជិក |
| ២១. រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា | ១រូប | សមាជិក |
| ២២. រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ | ១រូប | សមាជិក |
| ២៣. រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១រូប | សមាជិក |

២៤. មេបញ្ជាការកងរាជអាវុធហត្ថ លើផ្ទៃប្រទេស សមាជិក

២៥. អគ្គនាយក នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍នៃក្រសួងមហាផ្ទៃ សមាជិក

២៦. អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មនៃក្រសួងមហាផ្ទៃ សមាជិក

២៧. នាយកកិច្ចការព្រំដែននៃអគ្គបញ្ជាការដ្ឋានកងយោធពលខេមរៈភូមិន្ទ សមាជិក

សមាសភាព ជាក់ស្តែង នៃ គ.ជ.ប.ជ ត្រូវតែងតាំង ដោយ សេចក្តីសម្រេច របស់រាជរដ្ឋាភិបាល[46]។

**កថាខណ្ឌទី ២៖ តួនាទី និងភារកិច្ច**

គ.ជ.ប.ជ គឺជាយន្តការអន្តរស្ថាប័នថ្នាក់ជាតិ ដែលមានតួនាទីធ្វើជាសេនាធិការជូនរាជរដ្ឋាភិបាល ក្នុងការដឹកនាំ សម្របសម្រួលផ្តុំការចូលរួមនិងកិច្ចសហការ និងគាំទ្រពីក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការសហប្រជាជាតិ អង្គការដៃគូរជាតិ អន្តរជាតិ ផ្នែកឯកជនរួមទាំងយន្តការក្នុងតំបន់ និងបណ្តាប្រទេសពាក់ព័ន្ធទាំងឡាយ សម្រាប់ការងារប្រយុទ្ធប្រឆាំងនឹងរាល់ទម្រង់នៃអំពើជួញដូរ និងអំពើធ្វើអាជីវកម្មកេងប្រវ័ញ្ចលើមនុស្សគ្រប់រូបភាព ជាពិសេសលើស្ត្រីនិងកុមារ ដែលកើតមាននៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា[47]។

**គ.ជ.ប.ជ មានភារកិច្ចដូចខាងក្រោម៖**

១. ជម្រុញ និង លើកម្ពស់ ការអនុវត្តន៍ច្បាប់ស្តីពីការង្រ្កាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ ពិធីសារស្តីពីការទប់ស្កាត់ការបង្រ្កាប និងដាក់ទណ្ឌកម្ម ការជួញដូរមនុស្ស ជាពិសេសស្រ្តីនិងកុមារ ដែលបំពេញបន្ថែមលើអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីការប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង ឬលិខិតតូបករណ៍និងកិច្ចព្រមព្រៀងអន្តរជាតិផ្សេងៗទៀតទាក់ទងនឹងអំពើជួញដូរមនុស្ស ដែលព្រះរាជាណាចក្រកម្ពុជាជាសមាជិកហត្ថលេខី។

២. ជម្រុញ និង ពង្រឹងការអនុវត្តន៍គោលនយោបាយ និង បទដ្ឋានអប្បបរមាស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស។

៣. ជម្រុញ និង ពង្រឹងកិច្ចការជួយជនរងគ្រោះដោយ អំពើជួញដូរមនុស្ស នៅតាមគ្រប់ដំណាក់កាលនៃនីតិវិធីតុលាការ។

---

[46] មាត្រា ២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦១៤/៨០៨ ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

[47] មាត្រា ៣ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦១៤/៨០៨ ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

៤. ជម្រុញ និង តាមដានការអនុវត្តន៍ច្បាប់ គោលនយោបាយជាតិ អន្តរជាតិពាក់ព័ន្ធ និង គោលការណ៍ណែនាំផ្សេងៗរបស់រាជរដ្ឋាភិបាល ព្រមទាំងគាំទ្រឱ្យមានការចុះហត្ថលេខា ឬការផ្តល់សច្ចាប័នលើលិខិតតូបករណ៍អន្តរជាតិទាំងឡាយណាដែលមានអត្ថប្រយោជន៍ដល់ការងារប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស។

៥. តាមដាន ត្រួតពិនិត្យ និង វាយតម្លៃសភាពការណ៍ប្រែប្រួល នៃបទល្មើសជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ និងបទល្មើសពាក់ព័ន្ធដទៃទៀត ដោយយកចិត្តទុកដាក់លើភាពរងគ្រោះរបស់ប្រជាពលរដ្ឋ ទាំងស្ត្រី បុរស ជាពិសេសកុមារ និងយុវវ័យ។

៦. ពិនិត្យ កែលំអ និងស្នើឱ្យក្រសួង ស្ថាប័នពាក់ព័ន្ធ រៀបចំតាក់តែងបំពេញបន្ថែម នូវអត្ថបទច្បាប់ បទដ្ឋានគតិយុត្តដែលនៅខ្វះខាត ដាក់ចេញគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពដើម្បីទប់ស្កាត់បទល្មើស ជួយសង្គ្រោះ និងការពារជនរងគ្រោះដោយអំពើជួញដូរមនុស្សគ្រប់រូបភាពនិងជម្រុញការផ្សព្វផ្សាយអប់រំឱ្យបានទូលំទូលាយដល់សាធារណជន បានយល់ដឹងនិងចូលរួមអនុវត្ត។

៧. ជម្រុញឱ្យមានមជ្ឈមណ្ឌលគំរូ ដែលអនុវត្តតាមបទដ្ឋានបានត្រឹមត្រូវ សម្រាប់ការស្តារនីតិសម្បទាជនរងគ្រោះមាតុភូមិនិវត្តន៍ មុន នឹងធ្វើសមាហរណកម្មទៅគ្រួសារ ឬសហគមន៍វិញ។

៨. ជម្រុញនិងលើកកម្ពស់ការទទួលខុសត្រូវរបស់ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌឱ្យឆ្លើយតបទៅនឹងអំពើជួញដូរមនុស្សមានជាអាទិ៍៖ ពង្រឹងការអនុវត្តន៍ច្បាប់ ការលុបបំបាត់និទណ្ឌភាព ការស៊ើបអង្កេត និងការផ្តន្ទាទោសជនល្មើសពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស លើកកម្ពស់ការជឿទុកចិត្តពីប្រជាពលរដ្ឋ ជា១ៗទៀតតាមការប្រគល់ជូនរបស់រាជរដ្ឋាភិបាល[48]។

**កថាខណ្ឌទី ៣៖ អំពីអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**

គ.ជ.ប.ជ មានអគ្គលេខាធិការដ្ឋានមួយជាអង្គភាពប្រតិបត្តិ ដែលមានទីតាំងនៅក្នុងមូលដ្ឋានណាមួយនៃទីស្តីការក្រសួងមហាផ្ទៃ និងមានមន្ត្រីបម្រើការងារជាក្របខណ្ឌក្រសួងមហាផ្ទៃ។

អនុប្រធានអចិន្ត្រៃនៃ គ.ជ.ប.ជ ត្រូវបានប្រគល់ភារកិច្ចឱ្យទទួលបន្ទុក អគ្គលេខាធិការដ្ឋាន ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ត្រូវកំណត់ដោយអនុ-ក្រឹត្យ[49]។

[48] មាត្រា ៩ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦១៤/៨០៨ ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

[49] មាត្រា ៨ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦១៤/៨០៨ ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

**តួនាទី ភារកិច្ចរបស់អគ្គលេខាធិការដ្ឋាននៃ គ.ជ.ប.ជ**

អគ្គលេខាធិការដ្ឋាននៃ គ.ជ.ប.ជ មានតួនាទីជាអង្គភាពប្រតិបត្តិធ្វើជាសេនាធិការជូនគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស គ.ជ.ប.ជ ដោយមានភារកិច្ចដូចខាងក្រោម៖

- សម្របសម្រួលការងារជាមួយក្រុមការងារជំនាញអន្តរក្រសួង ស្ថាប័ន នៃ គ.ជ.ប.ជ ដូចមានចែងក្នុងមាត្រា ១០ នៃព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈកម្មធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- សហការជាមួយគណៈកម្មធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរាជធានី (គ.រ.ប.ជ) និងគណៈកម្មធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត (គ.ខ.ប.ជ)។
- សហការជាមួយអង្គការជាតិ អន្តរជាតិពាក់ព័ន្ធ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- តាមការប្រគល់សិទ្ធិពីប្រធានគណៈកម្មាធិការជាតិ គ.ជ.ប.ជ ធ្វើទំនាក់ទំនងជាមួយស្ថានទូត ស្ថានតំណាង និងរាជរដ្ឋាភិបាលនៃប្រទេសពាក់ព័ន្ធនានា ដើម្បីស្នើសុំឱ្យមានការស្រាវជ្រាវអំពីករណី ឬភាពមិនប្រក្រតី និងផលប៉ះពាល់នៃបទល្មើសជួញដូរមនុស្ស។
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃសភាពការណ៍ប្រែប្រួលនៃបទល្មើសជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ បទល្មើសពាក់ព័ន្ធដទៃទៀត ដោយយកចិត្តទុកដាក់លើភាពងាយរងគ្រោះរបស់ប្រជាពលរដ្ឋទាំងស្ត្រី ទាំងបុរស ជាពិសេសកុមារ និងយុវវ័យ។
- សហការ ជាមួយសមត្ថកិច្ចជំនាញ ដើម្បីលើកសំណើ បណ្តុះបណ្តាលធនធានមនុស្ស និងអភិវឌ្ឍនសមត្ថភាព ដែលពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស។
- រៀបចំផ្សព្វផ្សាយផែនការសកម្មភាពរយៈពេលវែងមធ្យម និងរយៈពេលខ្លីរបស់ គ.ជ.ប.ជ ដើម្បីឱ្យស្ថាប័នពាក់ព័ន្ធ និងប្រជាពលរដ្ឋយល់ជ្រួតជ្រាបអំពីការប្រឆាំង និងការធ្វើអាជីវកម្មផ្លូវភេទ។
- តាមការប្រគល់សិទ្ធិពីប្រធាន គ.ជ.ប.ជ ដើម្បីរៀបចំ និងចូលរួមកិច្ចប្រជុំ សិក្ខាសាលា ទស្សនកិច្ចសិក្សា និងសន្និសិទផ្សេងៗនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងជាមួយអន្តរជាតិពាក់ព័ន្ធការងារប្រឆាំងអំពើជួញដូរមនុស្ស។

- លើកគំរោងផែនការថវិកា ភស្តុភារ សម្ភារៈបច្ចេកទេស និង មធ្យោបាយស្របតាមច្បាប់ស្តីពីហិរញ្ញវត្ថុ។
- កៀរគរធនធានថវិកា សម្ភារៈ មធ្យោបាយ និងការចូលរួមគាំទ្រពីបណ្តាដៃគូពាក់ព័ន្ធនានា។
- ទទួលបានការប្រគល់សិទ្ធិពីប្រធាន គ.ជ.ប.ជ គ្រប់គ្រងនិងចាត់ចែងថវិការ សម្ភារបរិក្ខា មធ្យោបាយ និងការងារពាក់ព័ន្ធរបស់ គ.ជ.ប.ជ ដូចមានចែងក្នុងមាត្រា ១២ នៃព្រះរាជក្រឹត្យ ស្តីពីការបង្កើត គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស។
- ដឹកនាំគ្រប់គ្រងមន្ត្រីអគ្គលេខាធិការដ្ឋាននៃ គ.ជ.ប.ជ លើកសំណើតែងតាំង ដំឡើងឋានៈ ឬផ្លាស់ប្តូរភារកិច្ច លើកសរសើរ អនុវត្តវិន័យដល់មន្ត្រីបម្រើការងារនៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ដាក់ជូនអនុប្រធានអចិន្ត្រៃ នៃ គ.ជ.ប.ជ ពិនិត្យសម្រេចមុននឹងសុំសេចក្តីសម្រេចពីប្រធាន គ.ជ.ប.ជ។
- គ្រប់ គ្រងទុកដាក់ បែងចែក ឯកសារ និងលិខិតចេញចូលរបស់អគ្គលេខាធិការដ្ឋាននៃ គ.ជ.ប.ជ។
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារប្រចាំខែជូនប្រធានគណៈកម្មាធិការជាតិ គ.ជ.ប.ជ។
- រៀបចំសេចក្តីព្រាងរបាយការណ៍លទ្ធផលការងារប្រចាំត្រីមាស ឆមាស និងឆ្នាំ និងទិសដៅបន្តដាក់ជូនប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សពិនិត្យសម្រេច។
- ប្រមូល ចងក្រងបោះពុម្ព និងផ្សព្វផ្សាយរបាយការណ៍ខែ ត្រីមាស ឆមាស និងឆ្នាំរបស់ គ.ជ.ប.ជ។
- បំពេញភារៈកិច្ចផ្សេងៗទៀត ដែលប្រធាន គ.ជ.ប.ជ និងក្រសួងមហាផ្ទៃប្រគល់ឱ្យ[50]។

**អគ្គលេខាធិការដ្ឋាននៃ គ.ជ.ប.ជ មានរចនាសម្ព័ន្ធដូចខាងក្រោមៈ**

- លេខាធិការដ្ឋានរដ្ឋបាល សរុប
- ក្រុមមន្ត្រីជំនួយការ អគ្គលេខាធិការដ្ឋាន

[50] មាត្រា ៣ នៃអនុក្រឹត្យលេខ ២៧៣ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

លេខាធិការដ្ឋានរដ្ឋបាល សរុប ដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើ និងបុព្វសិទ្ធិស្មើប្រធាននាយកដ្ឋាននិងមានអនុប្រធានលេខាធិការដ្ឋាន ជាជំនួយការ មានឋានៈ និងបុព្វសិទ្ធិស្មើអនុប្រធាននាយកដ្ឋាន ចំណុះក្រសួងមហាផ្ទៃ

ក្រុមមន្ត្រីជំនួយការរបស់អគ្គលេខាធិការដ្ឋាន មានចំនួនសមស្រប តាមទំហំក្រុមការងារជំនាញនីមួយៗ សម្រាប់ទំនាក់ទំនងការងារជាមួយក្រុមជំនាញអន្តរក្រសួង ស្ថាប័ន ដែលមានឋានៈ និងបុព្វសិទ្ធិស្មើប្រធាននាយកដ្ឋាន ឬអនុប្រធាននាយកដ្ឋាន។

មន្ត្រីដែលបម្រើការងារក្នុងអគ្គលេខាធិការដ្ឋាន លេខាធិការដ្ឋាន និងក្រុមមន្ត្រីជំនួយការត្រូវមានក្របខណ្ឌមកពីក្រសួងមហាផ្ទៃ។ ក្នុងករណីចាំបាច់អគ្គលេខាធិការដ្ឋាននៃ គ.ជ.ប.ជ អាចស្នើសុំមន្ត្រីជំនាញពីក្រសួងដទៃ។

តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់លេខាធិការដ្ឋានរដ្ឋបាល សរុប និងក្រុមមន្ត្រីជំនួយការត្រូវកំណត់ដោយប្រកាសរបស់ប្រធាន គ.ជ.ប.ជ[51]។

## ផ្នែកទី ៤៖ ការផ្សព្វផ្សាយឱ្យបានទូលំទូលាយ និង អប់រំដល់ប្រជាពលរដ្ឋឱ្យយល់ដឹងពីអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ

### កថាខណ្ឌទី ១៖ ការផ្សព្វផ្សាយជាសាធារណៈ

ដើម្បីឱ្យប្រជាពលរដ្ឋទូទៅ បានយល់ដឹងអំពីបញ្ហា ការជួញដូរមនុស្សយកទៅធ្វើអាជីវកម្មពេស្យាចារ ជាពិសេស ត្រូវមានការផ្សព្វផ្សាយឱ្យបានទូលំទូលាយ អំពីច្បាប់ និងវិធីផ្សេងៗដែលជនខិលខូចប្រើប្រាស់ជាមធ្យោបាយក្នុងការលួងលោម បោកប្រាស់ ឬចាប់ពង្រាត់ ជូនប្រជានជនដែលងាយរងគ្រោះ ដើម្បីឱ្យពួកគាត់បានយល់ ហើយថែមទាំងដើម្បីរួមចំណែកក្នុងការកាត់បន្ថយនូវបញ្ហាជួញដូរមនុស្សនេះផងដែរ។ បច្ចុប្បន្ននេះមធ្យោបាយដែលប្រើប្រាស់សម្រាប់ធ្វើការផ្សព្វផ្សាយមានច្រើនសម្បូរបែបណាស់ ដែលរួមមាន ទូរទស្សន៍ វិទ្យុ កាសែត ទស្សនាវដ្តី និងតាមប្រព័ន្ធអ៊ីនធឺណេត ល.។

ការផ្សព្វផ្សាយអប់រំ អំពីបញ្ហាជួញដូរមនុស្ស ជាកត្តាសំខាន់មួយដែលរាជរដ្ឋាភិបាលត្រូវតែយកចិត្តទុកដាក់បំផុត ដើម្បីធ្វើការបញ្ជ្រាបឱ្យប្រជាពលរដ្ឋទូទៅបានយល់ដឹង និង ធ្វើការប្រុងប្រយ័ត្ន ជាពិសេសប្រជាពលរដ្ឋ ដែលរស់នៅតាមបណ្តាខេត្តក្រុងមួយចំនួន ដែលជាមុខសញ្ញាសំខាន់របស់ឈ្មួញទុច្ចរិតក្នុងការប្រព្រឹត្តសកម្មភាពជួញដូរមនុស្ស និងការធ្វើអាជីវកម្មកេងប្រវ័ញ្ចផ្លូវភេទ។ តាមរយៈការប្រមែប្រមូលទិន្នន័យដែលពាក់ព័ន្ធនឹងបទល្មើសការពង្រាត់ ការជួញដូរ ការធ្វើ

[51] មាត្រា ៧ នៃអនុក្រឹត្យលេខ ២៧៣ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

អាជីវកម្មកេងប្រវ័ញ្ចផ្លូវភេទនៅតាមខេត្តក្រុងសំខាន់ៗមួយចំនួនដូចជា រាជធានីភ្នំពេញ សៀមរាប ក្រុងព្រះសីហនុ បន្ទាយមានជ័យ បាត់ដំបង កំពង់ចាម ព្រៃវែង ស្វាយរៀង កោះកុង កណ្តាល ស្ទឹងត្រែង និងបណ្តាខេត្តក្រុងមួយចំនួនទៀតដែលប្រជាពលរដ្ឋតែងតែធ្វើចំណាក់ស្រុកដើម្បីស្វែងរកការងារធ្វើនៅតាមទីក្រុង។ ដូច្នេះហើយចាំបាច់ត្រូវតែមានការផ្សព្វផ្សាយ និង អប់រំដល់ប្រជាពលរដ្ឋនៅតាមបណ្តាខេត្តក្រុងដូចបានរៀបរាប់ខាងលើនេះ ឱ្យបានជ្រាប ពីបញ្ហាជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ។

**កថាខណ្ឌទី ២៖ ការបណ្តុះបណ្តាលប្រជាពលរដ្ឋ**

ជាទូទៅការអប់រំអំពីការជួញដូរមនុស្ស និង ការធ្វើអាជីវកម្មផ្លូវភេទ ពិតជាមានសារៈសំខាន់ណាស់សម្រាប់ប្រជាពលរដ្ឋទូទៅ ដើម្បីបានយល់ច្បាស់ពីការជួញដូរ និង សកម្មភាពបោកប្រាស់របស់ជនខិលខូចដែលតែងតែព្យាយាមគ្រប់ល្បិចកល ដើម្បីប្រព្រឹត្តអំពើកេងប្រវ័ញ្ចលើមនុស្ស ជាពិសេស ការប្រកបមុខរបររកស៊ីផ្លូវភេទជាដើម។ នៅក្នុងការអប់រំបណ្តុះបណ្តាលដល់ប្រជាពលរដ្ឋជាពិសេសត្រូវមានការសហការជាមួយបណ្តាស្ថាប័នជាតិ រួមមានក្រសួងអប់រំ យុវជន និង កីឡា ដើម្បីធ្វើការផ្សព្វផ្សាយអំពីបញ្ហាជួញដូរមនុស្ស និង ការធ្វើអាជីវកម្មផ្លូវភេទ ដោយដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សានៅតាមគ្រឹះស្ថានអប់រំនានា ដើម្បីឱ្យសិស្សានុសិស្សទទួលបានការអប់រំ និងយល់ដឹងអំពីការជួញដូរមនុស្សនៅក្នុងសង្គម។

លើសពីនេះទៅទៀត ត្រូវធ្វើការអប់រំណែនាំដល់ប្រជាពលរដ្ឋដែលបើកអាជីវកម្មរកស៊ីគ្រប់ប្រភេទ ដូចជា ម្ចាស់សណ្ឋាគារ ផ្ទះសំណាក់ ក្លឹបកំសាន្ត ខារ៉ាអូខេ ហាងម៉ាស្សាកោសជប់ និង មជ្ឈមណ្ឌលកំសាន្តនានា ដោយហាមមិនឱ្យមានការលួចបង្កប់នូវសេវាកម្មបម្រើផ្លូវភេទឡើយ និង ត្រូវមានការសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច នៅពេលដែលមានករណី ជួញដូរផ្លូវភេទកើតឡើង។ ម្យ៉ាងវិញទៀតចំពោះវិស័យទេសចរណ៍ ត្រូវមានការសហការជាមួយក្រសួងទេសចរណ៍ក្នុងការណែនាំដល់ ក្រុមហ៊ុនទេសចរណ៍ និងភ្ញៀវទេសចរជាតិ និងអន្តរជាតិ ឱ្យមានការយល់ដឹងពីការជួញដូរមនុស្ស ជាពិសេសទេសចរណ៍ផ្លូវភេទ។ ចំពោះវិស័យការងារ ត្រូវមានការសហការជាមួយក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងការត្រួតពិនិត្យទៅលើក្រុមហ៊ុនឯកជនណា ដែលបម្រើសេវាកម្មយកពលករទៅធ្វើការនៅឯក្រៅប្រទេស ដោយស្របច្បាប់ ដោយហេតុថាមានក្រុមហ៊ុនខ្លះប្រើរូបភាពបែបនេះក្នុងការប្រព្រឹត្តសកម្មភាពជួញដូរមនុស្ស។

**កថាខណ្ឌទី ៣៖ ការចុះធ្វើសកម្មភាពអប់រំដោយផ្ទាល់នៅតាមតំបន់ជនបទ**

ប្រជាពលរដ្ឋដែលរស់នៅតាមតំបន់ដាច់ស្រយាល ងាយនឹងត្រូវចាញ់បោក មេខ្យល់ នាំយកទៅលក់ណាស់ ដោយការបញ្ចុះបញ្ចូល តាមរយៈការដឹកនាំឱ្យទៅធ្វើការនៅទីក្រុង។ បញ្ហាទាំង

អស់នេះហើយដែលបាន ធ្វើឱ្យប្រជាពលរដ្ឋមួយចំនួន រងគ្រោះដោយសារតែការចាញ់បោកជនខិលខូចនាំយកទៅលក់។ ហេតុផលទាំងអស់នេះហើយដែល បណ្តាលមកពី កង្វះខាតនៃការផ្សព្វផ្សាយ ការអប់រំ ពីអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ជូនប្រជាពលរដ្ឋ ដោយហេតុថានៅតាមទីដាច់ស្រយាលមួយចំនួន ប្រព័ន្ធផ្សព្វផ្សាយ មិនអាចទៅដល់បានទេ ចំណែកឯការអប់រំវិញ មិនសូវបានគ្រប់គ្រាន់ដែរ ដោយសារតែសាលារៀននៅឆ្ងាយពេក ហើយសិស្សានុសិស្សជួបការលំបាកច្រើនក្នុងការប្រើប្រាស់មធ្យោបាយទៅសាលារៀន ពីព្រោះថាផ្លូវធ្វើដំណើរមានឧបសគ្គច្រើនពិបាកក្នុងការប្រើយានជំនិះ ដូចជា កង់ ឬ ម៉ូតូ ដែលនាំឱ្យពួកគេធ្វើដំណើរដោយថ្មើរជើង ម្យ៉ាងទៀត ប្រជាពលរដ្ឋមានកម្រិតជីវភាពលំបាក និងខ្វះខាតច្រើន មិនអាចមានលទ្ធភាពទិញនូវសម្ភារៈប្រើប្រាស់ទាំងនេះបានគ្រប់គ្រាន់ឡើយ។

ទោះជាយ៉ាងណាក៏ដោយ រាជរដ្ឋាភិបាល បានព្យាយាមខិតខំស្វែងរកគ្រប់មធ្យោបាយក្នុងការផ្សព្វផ្សាយ អប់រំដល់ប្រជាពលរដ្ឋដែលរស់នៅតាមតំបន់ដាច់ស្រយាល ដោយមានការសហការជាមួយអង្គការក្រៅរដ្ឋាភិបាល និងស្ថាប័នផ្សេងៗដែលពាក់ព័ន្ធ ដើម្បីចុះទៅធ្វើសកម្មភាពអប់រំដល់ប្រជាពលរដ្ឋឱ្យយល់ដឹងពីបញ្ហាជួញដូរមនុស្ស និង សកម្មភាពផ្សេងៗដែលជនខិលខូចប្រើល្បិចបោកប្រាស់គ្រប់បែបយ៉ាង ក្នុងការល្បួង យកមនុស្សទៅលក់ដើម្បីធ្វើអាជីវកម្មពេស្យាចារ ជាដើម ជាពិសេសស្ត្រី និង កុមារងាយនឹងរងគ្រោះបំផុត។ ដូច្នេះហើយ ការចុះធ្វើសកម្មភាពអប់រំបណ្តុះបណ្តាល ជាការសំខាន់ណាស់សម្រាប់ប្រជាពលរដ្ឋដែលរស់នៅតាមទីដាច់ស្រយាល ជាពិសេសដើម្បីឱ្យពួកគាត់បានយល់ដឹងពីអំពើជួញដូរមនុស្ស និងធ្វើការប្រុងប្រយ័ត្ន ចំពោះជនខិលខូចដែលតែងតែបោកប្រាស់នាំយកមនុស្សទៅលក់ជាដើម។

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាទៅលើប្រធានបទស្តីអំពី **អំពើសញ្ចារកម្ម** រួចមកយើងឃើញថា នៅពេលសព្វថ្ងៃនេះ ប្រទេសកម្ពុជា កំពុងតែប្រឈមមុខជាមួយនឹងបញ្ហាដែលកើតមាននៅក្នុងសង្គមជាច្រើន ហើយបញ្ហាទាំងអស់នោះបានធ្វើឱ្យសង្គម ទទួលរងនូវផលប៉ះពាល់ យ៉ាងខ្លាំង ជាពិសេសបញ្ហាសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈ។ អំពើសញ្ចារកម្មបានចាក់ឫស គល់នៅក្នុងសង្គមខ្មែរយ៉ាងជ្រៅ និងអស់រយៈកាលជាច្រើនទសវត្សរ៍មកហើយ ជាហេតុ នាំឱ្យសីលធម៌ ប្រពៃណី ទំនៀមទម្លាប់ដ៏ល្អរបស់ជាតិត្រូវធ្លាក់ចុះ ហើយព្រមទាំងធ្វើឱ្យសេចក្តីថ្លៃថ្នូររបស់មនុស្សត្រូវបាត់បង់ផងដែរ។ ដោយយល់ឃើញថាសញ្ចារកម្ម ជាអំពើមួយដែលមានលក្ខណៈប្រឆាំងទៅនឹងមនុស្ស និងសង្គម ទើបធ្វើឱ្យមជ្ឈដ្ឋានជាតិ និងអន្តរជាតិ បានចាត់វិធានការក្នុងការបង្ក្រាប ទប់ស្កាត់ និងលុបបំបាត់ចោលនូវរាល់អំពើទាំងឡាយណា ដែលនាំឱ្យមានការរឹតត្បិតសិទ្ធិសេរីភាព ការកេងប្រវ័ញ្ចយកផលប្រយោជន៍គ្រប់បែបយ៉ាង ការធ្វើអាជីវកម្មលើមនុស្សជាដើម។

នៅក្នុងប្រទេសកម្ពុជាចំពោះការលុបបំបាត់នូវអំពើសញ្ចារកម្ម ដែលតែងតែកើតមាននៅក្នុងសង្គមមិនមែនជារឿងងាយស្រួលប៉ុន្មាននោះទេ ពីព្រោះថាជនខិលខូចដែលប្រព្រឹត្តសញ្ចារកម្មតែងតែព្យាយាមរកគ្រប់កលល្បិចក្នុងការលាក់បាំងពីអាជីវកម្មរបស់ខ្លួន ជាពិសេសការប្រកបអាជីវកម្មផ្លូវភេទ ដូចជា ការបើកផ្ទះបនស្រីពេស្យា សម្រាប់ឱ្យបម្រើសេវាផ្លូវភេទ ដល់អតិថិជន យ៉ាងអនាធិបតេយ្យ នៅតាមទីសាធារណៈ ដែលកន្លងមក សកម្មភាពបែបនេះត្រូវបានសមត្ថកិច្ចចុះធ្វើការបង្ក្រាប និងលុបបំបាត់ចោលអស់ទាំងស្រុងទៅហើយ ប៉ុន្តែជាអកុសល សកម្មភាពទាំងនោះបានកើតឡើងសារជាថ្មីម្តងទៀត ក្រោមទម្រង់ប្លែកៗ ដែលធ្វើឱ្យយើងនឹកស្មានមិនដល់ ដោយសារតែជនខិលខូចទាំងនោះបានប្រើប្រាស់រូបភាពបំភាន់ភ្នែក ដើម្បីអាចគេចផុតពីការបង្ក្រាបរបស់សមត្ថកិច្ច។ ការលួចប្រព្រឹត្តអំពើសញ្ចារកម្មតាមរូបភាពថ្មីបែបនេះ បានបង្កផលវិបាកយ៉ាងខ្លាំងចំពោះសមត្ថកិច្ចក្នុងការចុះទៅធ្វើការបង្ក្រាប ដោយហេតុថា នៅពេលខ្លះជនខិលខូច បានលួចលាក់ បង្កប់អាជីវកម្មផ្លូវភេទ ជាមួយនឹងអាជីវកម្មស្របច្បាប់ ជាក់ស្តែងដូចជា បើកទាមលក់កាហ្វេនៅតាមដងផ្លូវ ការបើក សណ្ឋាគារ ទីកន្លែង ម៉ាស្សា កោសជប់ ផ្ទះសំណាក់ ភោជនីយដ្ឋាន ក្លឹបខារ៉ាអូខេ ដោយមានបង្កប់សេវាផ្លូវភេទ ដើម្បីបន្លំភ្នែកសមត្ថកិច្ច ហេតុនេះហើយទាមទារឱ្យមានការយកចិត្តទុកដាក់ខ្ពស់ ក្នុងការបំពេញបេសកកម្មរបស់សមត្ថកិច្ច ជាពិសេសនៅមុនពេលចុះអនុវត្តសកម្មភាពបង្ក្រាប ត្រូវមានការស៊ើបអង្កេតជាមុនឱ្យបានម៉ត់ចត់។

ទោះបីជាយ៉ាងណាក៏ដោយ រាល់សកម្មភាពនៃអំពើសញ្ជារកម្មដែលបានកើតមានឡើងនៅក្នុងពេលបច្ចុប្បន្ននេះ ទោះបីជា មិនត្រូវបានលុបបំបាត់ចោលអស់ទាំងស្រុងក៏ដោយ ប៉ុន្តែយើងសង្កេតឃើញថាអំពើទាំងនោះមានការថយចុះជាលំដាប់។ ដោយយោងទៅតាមរបាយការណ៍បូកសរុបសកម្មភាព និងលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទប្រចាំឆមាសទី១ និងទិសដៅឆមាសទី ២ ឆ្នាំ ២០១៦ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សបានបង្ហាញថា ករណីអំពើជួញដូរផ្លូវភេទ ត្រូវបានបង្ក្រាប ចំនួន ២៥ ករណី/២៦ ករណី (មានន័យថា ចំនួនបានថយចុះ ១ ករណី)។ នៅក្នុងនោះបទល្មើសពាក់ព័ន្ធនឹងសញ្ជារកម្ម បង្ក្រាបបាន ចំនួន ៧ ករណី សញ្ជារកម្មទាក់ទងនឹងកុមារ ចំនួន ៦ ករណី ការផ្តល់ទីកន្លែងសម្រាប់ធ្វើពេស្យាចារ ចំនួន ១ ករណី រូបភាព និងសម្ភារៈអាសអាភាស ចំនួន ១ ករណី អំពើរួមភេទជាមួយអនីតិជនអាយុក្រោម ១៥ ឆ្នាំ ចំនួន ៥ ករណី និងអំពើអាសប្រឆាំង និងអនីតិជនអាយុក្រោម ១៥ ឆ្នាំ ចំនួន ៥ ករណី។ ដូច្នេះហើយតាមទិន្នន័យ ដូចបានបង្ហាញខាងលើនេះ សបញ្ជាក់ឱ្យឃើញថាបទល្មើសដែលពាក់ព័ន្ធនឹងការជួញដូរផ្លូវភេទ មានការថយចុះគួរឱ្យកត់សម្គាល់ ជាពិសេស បទល្មើសសញ្ជារកម្ម។

លើសពីនេះទៅទៀត នៅក្នុងការប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានខិតខំប្រឹងប្រែងជម្នះឧបសគ្គ ដើម្បីដោះស្រាយជូនប្រជាពលរដ្ឋឱ្យទទួលបាននូវការគោរពសេចក្តីថ្លៃថ្នូរ និងទទួលបានផលប្រយោជន៍ស្របច្បាប់របស់ខ្លួន ហើយព្រមទាំងបានធ្វើការប្តេជ្ញាចិត្តប្រឆាំងដាច់ខាតនូវអំពើជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ ដោយមានការសហការជាមួយបណ្តាប្រទេសពាក់ព័ន្ធនានានៅក្នុងតំបន់ និងលើពិភពលោក ដើម្បីលុបបំបាត់អំពើជួញដូរមនុស្ស ហើយថែមទាំងពង្រឹងការអនុវត្តន៍ច្បាប់ជាតិ និងអនុសញ្ញាអន្តរជាតិ ក៏ដូចជាអនុស្សារណៈ កិច្ចព្រមព្រៀងទាំងឡាយ ដើម្បីឱ្យបទដ្ឋាគតិយុត្តទាំងនោះប្រកបដោយប្រសិទ្ធភាពខ្ពស់។

សរុបសេចក្តីមក បញ្ហាអំពើសញ្ជារកម្ម បានបង្កផលវិបាកយ៉ាងធ្ងន់ធ្ងរដល់មនុស្ស និងសង្គមជាតិទាំងមូល ជាពិសេសធ្វើឱ្យបាត់បង់សេចក្តីថ្លៃថ្នូររបស់មនុស្ស ដោយសារតែសកម្មភាពនៃអំពើនោះស្តែងចេញតាមរយៈ ការយកមនុស្សមកធ្វើជាកម្មវត្ថុ សម្រាប់ប្រកបអាជីវកម្ម (អាជីវកម្មពេស្យាចារ) ម្យ៉ាងវិញទៀត អំពើសញ្ជារកម្ម បានធ្វើឱ្យប្រពៃណី ទំនៀមទម្លាប់ល្អរបស់ជាតិត្រូវធ្លាក់ចុះផងដែរ ហេតុដូច្នេះហើយ អំពើបែបនេះមិនត្រូវឱ្យកើតមាននៅក្នុងសង្គមឡើយ។

# អនុសាសន៍

ដើម្បីធ្វើការប្រយុទ្ធប្រឆាំងទៅនឹងបញ្ហាអំពើសញ្ចារកម្ម ដែលតែងតែកើតមាននៅក្នុងសង្គម ក្នុងនាមយើងខ្ញុំជានិស្សិតច្បាប់ សូមចូលរួមផ្តល់អនុសាសន៍មួយចំនួន ដូចខាងក្រោម:

១. ត្រូវរៀបចំធ្វើកំណែទម្រង់ឡើងវិញ នូវចំណុចខ្វះខាតនៃច្បាប់ ឱ្យកាន់តែប្រសើរឡើង ដោយស្របទៅតាមបទដ្ឋានអន្តរជាតិ និងបរិបទសង្គម។

២. ជម្រុញឱ្យមានការគោរពច្បាប់ និងបទដ្ឋានគតិយុត្តនានាឱ្យមានប្រសិទ្ធភាពខ្ពស់។

៣. ត្រូវធ្វើការអប់រំ និង ផ្សព្វផ្សាយឱ្យបានទូលំទូលាយ ដល់មន្ត្រីអនុវត្តច្បាប់ និង ប្រជាពលរដ្ឋឱ្យមានការយល់ដឹងអំបញ្ហាអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

៤. ត្រូវធ្វើការពិនិត្យស្រាវជ្រាវអំពីបទល្មើស ឱ្យបានម៉ត់ចត់ ដើម្បីងាយស្រួលក្នុងការចុះទៅអនុវត្តភារកិច្ចបង្ក្រាបបទល្មើស។

៥. ត្រូវមានការសហការជាមួយស្ថាប័ននានា អង្គការមិនមែនរដ្ឋាភិបាល និងប្រជាពលរដ្ឋ ដើម្បីប្រយុទ្ធប្រឆាំងនិងអំពើល្មើសច្បាប់នៅក្នុងសង្គម។

៦. គាំទ្រឱ្យមានសកម្មភាព បណ្តុះបណ្តាល អប់រំ របស់សមាគមន៍អង្គការមិនមែនរដ្ឋាភិបា-លនៅមូលដ្ឋាន ដើម្បី លើកម្ពស់ចំណេះដឹងដល់ប្រជាពលរដ្ឋ។

៧. ជម្រុញឱ្យមានការលើកទឹកចិត្ត ចំពោះស្ថាប័នដែលបំពេញតួនាទីបានល្អ ក្នុងបេសកកម្មប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

# ឯកសារយោង

## I. ផ្នែកលិខិតបទដ្ឋានគតិយុត្តជាតិ

១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣

២. ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០០៧

៣. ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

៤. ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៨

៥. ច្បាប់ស្តីពី សុំកូនអន្តរប្រទេស ចុះថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០០៩

៦. ច្បាប់ស្តីពី ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០០៥

៧. ច្បាប់ស្តីពី ទេសចរណ៍ ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៥

៨. ព្រះរាជក្រមលេខ: នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

៩. ព្រះរាជក្រមលេខ: នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

១០. ព្រះរាជក្រមលេខ: នស/រកម/០១០៥/០០២ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី

១១. ព្រះរាជក្រឹត្យលេខ: នស/រកត/០៦១៤/៨០៨ ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

១២. អនុក្រឹត្យលេខ: ១៣ អនក្រ.បក ចុះថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងកិច្ចការនារី

១៣. អនុក្រឹត្យលេខ: ១០៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងមហាផ្ទៃ

១៤. អនុក្រឹត្យលេខ: ៥៤ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

១៥. អនុក្រឹត្យលេខ: ២៧៣ អនក្រ.បក ចុះថ្ងៃទី ៧ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

១៦. ក្រសួងមហាផ្ទៃ លេខៈ០២៣ ផក ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៥ ស្តីពី ផែនការសកម្មភាពប្រយុទ្ធប្រឆាំងការជួញដូរ ការរត់ពន្ធមនុស្សការធ្វើអាជីវកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ

១៧. ក្រសួងមហាផ្ទៃ ផែនការណែនាំលេខៈ០២០ ផក ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១០ ស្តីពីការចាត់តាំងអនុវត្តគោលនយោបាយ ភូមិ ឃុំមានសុវត្ថិភាព

១៨. គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សេចក្តីសម្រេចលេខៈ០៩៤/១៤ស.ស.រ ចុះថ្ងៃទី ២១ ខែ វច្ឆិកា ឆ្នាំ ២០១៤ ស្តីពីការបង្កើតក្រុមការងារជំនាញអន្តរក្រសួង ស្ថាប័នសម្រាប់ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

១៩. ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ សេចក្តីសម្រេចលេខៈ ១០៧ ក.ជ.ក.ក ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៧ ស្តីពីគោលការណ៍ការពារសិទ្ធិកុមាររងគ្រោះដោយសារការជួញដូរនៃព្រះរាជាណាចក្រកម្ពុជា

២០. កិច្ចព្រមព្រៀង ស្តីពីគោលការណ៍ណែនាំអនុវត្ត និងកិច្ចសហការរវាងស្ថាប័នរាជរដ្ឋាភិបាលដែលពាក់ព័ន្ធ និងបណ្តាទីភ្នាក់ងារគាំទ្រជនរងគ្រោះក្នុងដំណើររឿងក្តីជួញដូរមនុស្ស ចុះថ្ងៃទី ៦ ខែ កុម្ភៈ ឆ្នាំ ២០០៧

## II. ផ្នែកលិខិតបទដ្ឋានគតិយុត្តអន្តរជាតិ

### ១. អនុសញ្ញា

- អនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅអមនុស្សធម៌ ឬបន្ថោកបន្ទាប ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៨៧
- អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ ថ្ងៃទី ២ កញ្ញា ១៩៩០

### ២. ពិធីសារ

- ពិធីសារ ដើម្បីធ្វើការទប់ស្កាត់ បង្ក្រាប និង ការដាក់ទណ្ឌកម្ម លើការជួញដូរមនុស្សជាពិសេស លើស្ត្រី និងកុមារ និងការបំពេញបន្ថែមនូវអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងទៅនឹងបទឧក្រិដ្ឋកម្មឆ្លងដែនដែលបានចាត់តាំងឡើង ឆ្នាំ ២០០០
- ពិធីសារតាមចិត្តជ្រើសរើសជាប់នឹង អនុសញ្ញាស្តីពីសិទ្ធិកុមារ ពាក់ព័ន្ធនឹង ការលក់កុមារពេស្យាកម្មកុមារ និងកាមសាស្ត្រកុមារ ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០២

### ៣. អនុស្សារណៈ និងកិច្ចព្រមព្រៀងអន្តរជាតិ

- អនុស្សារណៈនៃការយោគយល់គ្នា រវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលនៃរាជាណាចក្រថៃឡង់ ស្តីពី កិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីលុបបំបាត់ការជួញ

ដូរកុមារ និងស្ត្រី និងជួយដល់ជនរងគ្រោះដោយសារការជួញដូរ ធ្វើនៅសៀមរាបថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០៣

– កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលនៃសាធារណៈរដ្ឋសង្គមនិយមវៀតណាម ស្តីពី កិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីលុបបំបាត់ការជួញដូរកុមារ និងស្ត្រី និងជួយដល់ជនរងគ្រោះដោយសារការជួញដូរ ធ្វើនៅទីក្រុងហាណូយ ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០០៥

## III. ផ្នែកស្លាដៃនិពន្ធ និងឯកសាររបាយការណ៍


១. សៀវភៅ " **ការសិក្សា ច្បាប់ គ្រប់ មាត្រា ទាំងអស់ ក្នុង ក្រមព្រហ្មទណ្ឌ** " របស់ អេង សុត បោះពុម្ពលើកទី២ ឆ្នាំ ១៩៦៤

២. សៀវភៅ " **ការជួញដូរមនុស្ស និងការស៊ើបអង្កេត** " រៀបរៀងដោយ មេធាវី សុក សំអឿន បោះពុម្ព ឆ្នាំ ២០០៦

៣. " **សៀវភៅណែនាំសម្រាប់ស្ត្រី** " រៀបរៀងដោយ អង្គការសន្តិភាព និងអភិវឌ្ឍន៍ (PYD) និងអង្គការវិទ្យាស្ថានបើកទូលាយ (OI) ឆ្នាំ ២០១០

៤. សៀវភៅ " **ស្ថានភាពអំពើហិង្សាលើ ស្ត្រី និងកុមារ** " បោះពុម្ពដោយសមាគម អាដហុក ខែ កុម្ភៈ ឆ្នាំ ២០១២

៥. និក្ខេបបទ ស្តីពី " **កងរាជអាវុធហត្ថក្នុងមុខងារស្រាវជ្រាវ ប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទនៅកម្ពុជា ពីឆ្នាំ ១៩៩៣-បច្ចុប្បន្ន** " រៀបរៀងដោយ ហ៊ាង ឆវី ឆ្នាំ ២០១២

៦. វចនានុក្រម " **ច្បាប់ ខ្មែរ-អង់គ្លេស** " ដោយ ភូឡាយស៊ុន និង ភូ រួចចេង បោះពុម្ពលើកទី ១ ឆ្នាំ ២០១២

៧. សទ្ទានុក្រម ស្តីពី " **ការជួញដូរមនុស្ស និងចិត្តវិទ្យា** " បោះពុម្ពលើកទី ២ ខែ កញ្ញា ឆ្នាំ ២០១៣

៨. សៀវភៅ " **កំណត់ពន្យល់មាត្រានីមួយៗនៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ** " រៀបរៀងដោយ ក្រសួងយុត្តិធម៌ បោះពុម្ពលើកទី ២ ឆ្នាំ ២០១៣

៩. " **យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី ៣** " របស់រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា, រាជធានីភ្នំពេញ ខែ កញ្ញា ឆ្នាំ ២០១៣

១០. អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ: **របាយការណ៍បូកសរុប សកម្មភាពនិងលទ្ធិផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទប្រចាំឆមាសទី១ និងទិសដៅឆមាសទី២ ឆ្នាំ ២០១៦**

១១. សៀភៅ នារីរតនៈទី៤ " **ផែនការយុទ្ធសាស្រ្តដើម្បីសមភាពយេនឌ័រ និងការបង្កើតភាពអង់អាចដល់ស្រ្តី** " ឆ្នាំ ២០១៤-២០១៨

១២. សៀវភៅ " **នីតិព្រហ្មទណ្ឌទូទៅ** " រៀបរៀងដោយសាស្ត្រាចារ្យ គង់ សាផន, បោះពុម្ពលើកទី ១ ឆ្នាំ ២០១៧


IV. **គេហទំព័រផ្សេងៗ**


១. https://www.everyday.com.kh/article/26541.html (25/02/2017)

២. http://khmeread.com/posts/12652 (25/02/2017)

៣. https://www.unicef.org/crc/ (26/02/2017)

៤. http://www.ncct.gov.kh/ (03/03/2017)

៥. http://www.mosvy.gov.kh/ (22/03/17)

៦. http://www.interior.gov.kh/ (23/03/17)

៧. http://www.mowa.gov.kh/ (26/03/17)

## ឧបសម្ព័ន្ធ

**<u>បញ្ជីឧបសម្ព័ន្ធ</u>**

១. ច្បាប់ស្តីពីការបំបិទផ្ទះបនស្រីពេស្យា ឆ្នាំ ១៩៦១

២. កិច្ចព្រមព្រៀង ស្តីពីគោលការណ៍ណែនាំអនុវត្ត និងកិច្ចសហការរវាងស្ថាប័នរាជរដ្ឋាភិបាលដែលពាក់ព័ន្ធនិងបណ្តាទីភ្នាក់ងារគាំទ្រជនរងគ្រោះក្នុងដំណើររឿងក្តីជួញដូរមនុស្សឆ្នាំ២០០៧

៣. សេចក្តីណែនាំលេខ: ០០៥ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១០ ស្តីពី ការបង្ការ~បង្ក្រាបការប្រើប្រាស់គ្រឿងញៀននៅតាមកន្លែងកំសាន្ត ការជួញដូរមនុស្ស និងការលេងភ្នាល់ល្បែងគ្មានការអនុញ្ញាត

៤. សេចក្តីណែនាំលេខ: ០០៩ ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១០ ស្តីពីការអនុវត្តកិច្ចប្រតិបត្តិការសង្គ្រោះជនរងគ្រោះដោយអំពើជួញដូរមនុស្ស និង/ឬការធ្វើអាជីវកម្មផ្លូវភេទនៅតាមបណ្តាទីតាំងដែលបានកំណត់

៥. សាលក្រមលេខ ០៤ (ង) ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៦ របស់តុលាកា ខេត្តសៀមរាប

៦. ដីកាកោះ នៃសំណុំរឿងព្រហ្មទណ្ឌលេខ: ១២៨០ ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៦

៧. ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ នៃសំណុំរឿងព្រហ្មទណ្ឌលេខ: ១៥០១ ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៦

# ច្បាប់ស្ដីអំពីការបំបិទផ្ទះបនស្រីពេស្យា

ព្រះរាជក្រមលេខ ៦០ - ប ស. ចុះថ្ងៃ ១៦ វិច្ឆិកា ១៩៦២

មាត្រា មួយ – ក្រោយ ៦ ខែ គិតពីថ្ងៃប្រកាសឲ្យប្រើច្បាប់នេះ ត្រូវហាមមិនឲ្យ មានបនស្ត្រីពេស្យា នៅក្នុងផែនដីព្រះរាជាណាចក្រ ហើយការប្រើប្រាស់បណ្ណ « កាត » ដល់ស្ត្រីពេស្យា ក៏ត្រូវមិនឲ្យមាន តាំងតែពីពេលនេះទៅដែរ ។

ផ្ទះបនស្ត្រីពេស្យា ដែលមានតាំងពីមុនមកដល់ពេលនេះ ត្រូវបិទទាំងអស់ ហើយលិខិតផ្សេង ៗ ដែលសំគាល់ពីការដែលបានអនុញ្ញាត ឲ្យបើកបនស្ត្រីពេស្យា ពីមុនមកនោះ ក៏ត្រូវដកហូតលែងឲ្យប្រើដែរ ដោយគ្មានចេញប្រាក់បំណាយអ្វីឡើយ ។ នៅក្នុងគ្រឹះស្ថានដដែលនេះ ក៏ត្រូវហាមដាច់ មិនឲ្យគេបើណា ដែលគេអាចសំគាល់បាន ជាបនស្ត្រីពេស្យា ។

មាត្រា ២ – ផុតពីពេលដែលបានកម្រិត ក្នុងមាត្រា១ខាងលើនេះ កិច្ចសន្យាទាំងប៉ុន្មាន ដែលបានធ្វើមក ក្នុងរបរតាំងផ្ទះបនស្ត្រីពេស្យានេះ ត្រូវបដិសេធចោលទាំងអស់ ដូចជាកិច្ចសន្យារវាងស្ត្រីពេស្យា នឹងថៅកែរបស់ខ្លួន ឬ កំពូកអតិថិជន , កិច្ចសន្យាពីរឿងជួលគ្រឹះស្ថាន សម្រាប់យកទៅធ្វើផ្ទះបន ទោះជាកិច្ចសន្យានេះបានធ្វើមក រវាងកូនឈ្នួលក្ដី អ្នក

ផ្តល់អ្វី១ក្តី អ្នកឲ្យប្រាក់ខ្ចីក្តី នឹងអ្នកជួលផ្ទះឲ្យគេ ឬ ទិញមុខរបរជំនួញ ធ្វើស្រីពេស្យាក្តី ។

ចំពោះការបដិសេធនេះ ឥតមានបញ្ញត្តិឲ្យបញ្ចេញសោហ៊ុយ ដាច់ខាតអ្វីឡើយ ហើយគ្មានបញ្ញត្តិឲ្យសងគ្រឿងសម្ភារៈទាំងឡាយ ដែលបានទទួលពីថ្ងៃមុន ឬ ក៏ប្រាក់កាសអ្វី ដែលគេបានប្រគល់ឲ្យពីថ្ងៃមុន ឬ ក៏សងប្រាក់ខ្ចីដែលគេបានឲ្យខ្ចី ។

មាត្រា ៣– ការប្រព្រឹត្តល្មើសនឹងច្បាប់នេះ ត្រូវផ្តន្ទាទោសជាបទមជ្ឈិមថ្នាក់ទី ២ ។

មាត្រា ៤– បទបញ្ញត្តិ ទាំងឡាយណា ដែលមានពីពេលមុនមក ហើយដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជាមោឃៈ ។ចប់ ។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមហាផ្ទៃ**
**អគ្គស្នងការដ្ឋាននគរបាលជាតិ**
លេខ:...០០៥......

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែមករា ឆ្នាំ២០១០

# សេចក្តីណែនាំ

## ស្តីពី

## ការបង្ការ-បង្ក្រាបការប្រើប្រាស់គ្រឿងញៀននៅតាមកន្លែងកំសាន្ត ការជួញដូរមនុស្ស និងការលេងភ្នាល់ល្បែងគ្មានការអនុញ្ញាត

ក្រោមដឹកនាំដ៏ឈ្លាសវៃរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រមុខនៃរាជរដ្ឋាភិបាលកម្ពុជា ប៉ុន្មានឆ្នាំចុងក្រោយនេះប្រទេសជាតិយើងបានបោះជំហានរីកចម្រើនយ៉ាងឆាប់រហ័សលើគ្រប់វិស័យ ជាពិសេស សេដ្ឋកិច្ច ពាណិជ្ជកម្ម វិនិយោគ ទេសចរណ៍ វប្បធម៌ និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ដែលធ្វើឱ្យជីវភាពប្រជាជនមានភាពប្រែប្រួលល្អប្រសើរជាបន្តបន្ទាប់ ទាំងសេដ្ឋកិច្ចគ្រួសារ វប្បធម៌ សុជីវធម៌ របៀបរស់នៅ និងសីលធម៌សង្គម ស័ក្តិសមជាប្រទេសមួយដែលកំពុងបោះដំណើរឆ្ពោះទៅកាន់វឌ្ឍនភាពគួរជាទីមោទនៈ។

ចំពោះកងកម្លាំងនគរបាល ផ្អែកតាមតួនាទីរបស់ខ្លួនស្របគ្នានឹងការច្បាមជាប់កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល និងគោលការណ៍ដឹកនាំរបស់ក្រសួងមហាផ្ទៃ បានអនុវត្តប្រកបដោយជោគជ័យ និងទទួលបាននូវស្នាដៃជាច្រើនក្នុងការរួមចំណែកអភិវឌ្ឍន៍ប្រទេស ជាពិសេសបានដើរតួនាទីស្នូលសំខាន់ក្នុងការរក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាពសង្គម ដែលជាបុព្វបទមិនអាចខ្វះបាន។

ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ អគ្គស្នងការដ្ឋាននគរបាលជាតិ បានសង្កេតឃើញមានសកម្មភាពល្មើសដូចជា : ការប្រើប្រាស់គ្រឿងញៀន នៅតាមក្លឹបកំសាន្ត ការឆ្លៀតយកអាជីវកម្មខារ៉ាអូខេ ម៉ាស្សា-កោសជប់ខ្យល់ ដើម្បីប្រព្រឹត្តអំពើជួញដូរពេស្យាចារ និងការលួចលាក់លេងល្បែងស៊ីសង ល្បែងភ្នាល់ខុសច្បាប់ បានប្រព្រឹត្តទៅនៅតាមមូលដ្ឋានមួយចំនួន ធ្វើឱ្យជះឥទ្ធិពលមិនល្អប៉ះពាល់ដោយផ្ទាល់ដល់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ និងរបៀបរៀបរយសង្គម។

ដើម្បីលើកកំពស់ស្មារតី ម្ចាស់ការថែមទៀត ក្នុងការរ៉ាប់រងភារៈកិច្ចរបស់ខ្លួន ក៏ដូចជាការឆ្លើយតបដោយការទទួលខុសត្រូវចំពោះ ការដឹកនាំណែនាំរបស់រាជរដ្ឋាភិបាល និងក្រសួងមហាផ្ទៃ អគ្គស្នងការដ្ឋាននគរបាលជាតិ សូមធ្វើការណែនាំដូចខាងក្រោម :

១-នាយកដ្ឋានកណ្តាល នាយកដ្ឋាន និងការិយាល័យជំនាញ ដែលមានភារៈកិច្ចបង្ការ និងបង្ក្រាបការជួញដូរគ្រឿងញៀនខុសច្បាប់ ការជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មលើពលកម្មមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ និងការលេងល្បែងខុសច្បាប់គ្រប់ប្រភេទ ត្រូវបង្កើនការទទួលខុសត្រូវលើតួនាទីដែលបានប្រគល់ឱ្យ ដោយខិតខំជំរុញការអនុវត្តន៍បណ្តាគោលការណ៍ វិធានការ និងទិសដៅទាំងឡាយដែលក្រសួងមហាផ្ទៃ ក៏ដូចជាអគ្គស្នងការដ្ឋាននគរបាលជាតិ បាន

អាស័យដ្ឋាន: មហាវិថីព្រះនរោត្តម (ជិតវង់មូលក្បាលថ្នល់) ទូរស័ព្ទ : ០២៣ ៦៣ ០០ ៦២០ ទូរព្រុម:០២៣ ២១៤ ៦៨២

ដាក់ចេញកន្លងមកឱ្យមានប្រសិទ្ធភាពខ្ពស់ សំដៅធ្វើឱ្យបទល្មើសទាំងនោះថយចុះជាអប្បបរមា និងឈានទៅលុបបំបាត់ឱ្យបាននាពេលអនាគត ។

**២**–គ្រប់ស្នងការដ្ឋាននគរបាលរាជធានី–ខេត្ត អធិការដ្ឋាននគរបាលក្រុង–ស្រុក–ខណ្ឌ និងប៉ុស្តិ៍នគរបាលរដ្ឋបាល ត្រូវក្តាប់ឱ្យបាននូវបណ្តាមូលដ្ឋានអាជីវកម្មដែលមានលក្ខណៈងាយស្រួលឱ្យជនល្មើសប្រព្រឹត្តសកម្មភាពប្រើប្រាស់គ្រឿងញៀន ឬសកម្មភាពជួញដូរមនុស្ស (ជួញដូរពេស្យាចារ) ដូចជា : កន្លែងប្រកបអាជីវកម្មរាំ–ច្រៀង–អាហារដ្ឋានគ្រប់ប្រភេទ សណ្ឋាគារ ផ្ទះសំណាក់ ផ្ទះជួល ម៉ាស្សា–កោសជប់ខ្យល់...។ល។ នៅក្នុងភូមិសាស្ត្រទទួលខុសត្រូវរបស់ខ្លួន ដើម្បីមានវិធានការគ្រប់គ្រងឱ្យបានល្អ ។

៣–ត្រូវកត់ត្រាបញ្ជីមូលដ្ឋានទាំងនេះឱ្យបានច្បាស់លាស់ និងធ្វើសេនាធិការជូនគណៈបញ្ជាការឯកភាពរាជធានី–ខេត្ត ដើម្បីប្រគល់ភារៈកិច្ចឱ្យថ្នាក់នីមួយៗទទួលខុសត្រូវគ្រប់គ្រង ដូចខាងក្រោម :

**–ប្រភេទ ក** : ប្រគល់ឱ្យប៉ុស្តិ៍នគរបាលរដ្ឋបាល គ្រប់គ្រង

**–ប្រភេទ ខ** : ប្រគល់ឱ្យអធិការដ្ឋាននគរបាលក្រុង–ស្រុក–ខណ្ឌ គ្រប់គ្រង

**–ប្រភេទ គ** : ប្រគល់ឱ្យស្នងការដ្ឋាននគរបាលរាជធានី–ខេត្ត គ្រប់គ្រង

**៤**–ត្រូវធ្វើសេនាធិការជូនគណៈបញ្ជាការឯកភាពគ្រប់ជាន់ថ្នាក់ និងសហការជាមួយអង្គភាព ឬស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំជួបប្រជុំឱ្យបានញឹកញាប់ជាមួយម្ចាស់មូលដ្ឋានអាជីវកម្ម និងអ្នកគ្រប់គ្រងទាំងអស់ដើម្បីផ្សព្វផ្សាយអំពីច្បាប់ អប់រំឱ្យមានការទទួលខុសត្រូវ និងធ្វើកិច្ចសន្យាហាមប្រាមការយកទីតាំង ឬអនុញ្ញាតឱ្យគេប្រព្រឹត្តសកម្មភាពប្រើប្រាស់គ្រឿងញៀន ឬជួញដូរមនុស្ស និងកំណត់កាតព្វកិច្ចត្រូវរាយការណ៍ពេលឃើញមានបាតុភាពសង្ស័យកើតឡើង ។

**៥**–នាយកដ្ឋានជំនាញត្រូវសរសេរដកស្រង់ខ្លឹមសារច្បាប់ ដោយសង្ខេបអំពីការផ្តន្ទាទោសចំពោះការចែកចាយ ការជួញដូរគ្រឿងញៀន និងសកម្មភាពជួញដូរមនុស្សប្រគល់ឱ្យស្នងការដ្ឋាននគរបាលរាជធានី–ខេត្ត ណែនាំឱ្យម្ចាស់មូលដ្ឋានអាជីវកម្មទាំងអស់ចម្លងបិទនៅតាមបន្ទប់ ឬកន្លែងដែលពិនិត្យឃើញថាមានការចាំបាច់ ដើម្បីរំលឹក ឬព្រមានដល់អ្នកមកកាន់កន្លែងនេះឱ្យចងចាំ និងប្រុងប្រយ័ត្ន។

**៦**–ត្រូវធ្វើការណែនាំ ជូនដំណឹងដល់ម្ចាស់មូលដ្ឋានអាជីវកម្មទាំងអស់ឱ្យពង្រឹងការអនុវត្តន៍ម៉ឺងម៉ាត់ ខ្លឹមសារលិខិតជូនដំណឹងរបស់ទីស្តីការគណៈរដ្ឋមន្ត្រីលេខ ១២៤០ សជណ ចុះថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ ២០០៩ ជាពិសេសការហាមក្មេងអាយុក្រោម ១៦ឆ្នាំ ចូលស្នាក់នៅសណ្ឋាគារ ផ្ទះសំណាក់ ក្លឹបកំសាន្ត និងកន្លែងសប្បាយភាពផ្សេងៗតែម្នាក់ឯង គ្មានការចូលរួមដំណើរពីអាណាព្យាបាល ឬឪពុកម្តាយ និងហាមយុវជន យុវនារី ក្រោមអាយុ ១៨ឆ្នាំ ចូលក្លឹបរាត្រី និងហូបគ្រឿងស្រវឹងក្រោយម៉ោង ២១:០០នាទី។

៧–ត្រូវយកចិត្តទុកដាក់ក្នុងការលុបបំបាត់ឱ្យបានដាច់ខាតការឆ្លៀតបើកឱ្យមានការរាំស្រាតនៅតាមមូលដ្ឋានអាជីវកម្ម រាំច្រៀងមួយចំនួនដែលធ្វើឱ្យប៉ះពាល់ដល់កិត្តិយស សេចក្តីថ្លៃថ្នូរ និងប្រពៃណីជាតិ ។

**៨**–ក្នុងករណីរកឃើញមានការប្រព្រឹត្តសកម្មភាពល្មើសនៅមូលដ្ឋានអាជីវកម្មណាមួយ ត្រូវខិតខំប្រមែប្រមូលភស្តុតាង សាក្សីឱ្យបានគ្រប់គ្រាន់ រួចហើយរាយការណ៍ស្នើសុំគណៈបញ្ជាការ

ឯកភាព ចាត់វិធានការបង្ក្រាប ដោយគួបផ្សំការដាក់បន្ទុកទាំងរដ្ឋបាល និងការផ្តន្ទាទោសតាមច្បាប់ ឱ្យបានម៉ឺងម៉ាត់បំផុតដោយពុំមានការយោគយល់។

៩–ដោយឡែកចំពោះការលេងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ ជាពិសេសល្បែងហ្គេមខុសច្បាប់នៅជិតគ្រឹះស្ថានសិក្សា អគ្គស្នងការដ្ឋាននគរបាលជាតិប្រគល់ភារកិច្ចឱ្យប៉ុស្តិ៍នគរបាលរដ្ឋបាលជាអ្នកទទួលខុសត្រូវក្នុងការក្តាប់ និងបង្ក្រាបគ្រប់ករណី ដោយប្រកាន់យកវិធានការផ្តន្ទាទោស គ្មានការលើកលែង គ្មានអន្តរាគមន៍ និងដោយ ស្មើភាពគ្នាចំពោះមុខច្បាប់។

ក្នុងករណីមានឧបសគ្គ មិនអាចអនុវត្តបានដោយប្រការណាមួយ ត្រូវរាយការណ៍តាមឋានានុក្រមមកស្នងការដ្ឋាននគរបាលរាជធានី–ខេត្ត ដើម្បីរាយការណ៍ជូនគណៈបញ្ជាការឯកភាព ដោះស្រាយទាន់ពេលវេលា។

១០–ដើម្បីអនុវត្តសេចក្តីណែនាំនេះឱ្យបានជោគជ័យ អគ្គស្នងការដ្ឋាននគរបាលជាតិ ប្រគល់ភារកិច្ចជូនឯកឧត្តម អគ្គស្នងការរងទទួលផែននគរបាលយុត្តិធម៌ ដើម្បីចាត់ចែង តាមដាន ត្រួតពិនិត្យណែនាំ និងដឹកនាំជំរុញឱ្យនាយកដ្ឋានកណ្តាល នាយកដ្ឋានជំនាញ និងស្នងការដ្ឋាននគរបាលរាជធានី–ខេត្តទាំងអស់ដែលមានការពាក់ព័ន្ធ អនុវត្តឱ្យមានប្រសិទ្ធភាព ព្រមទាំងធ្វើការបូកសរុប ដកពិសោធន៍ ដើម្បីអគ្គស្នងការ រាយការណ៍ជូនក្រសួងមហាផ្ទៃ ៕

អគ្គស្នងការនគរបាលជាតិ

នាយឧត្តមសេនីយ៍.នេត–សាវឿន

**ចម្លងជូន :**
- ថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ
- អគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ
- ថ្នាក់ដឹកនាំអគ្គស្នងការនគរបាលជាតិ
- ប្រធានលេខាធិការ
- ប្រធាននាយកដ្ឋានកណ្តាល, នាយកដ្ឋាន, អង្គភាព, ស្នងការ ទាំងអស់ដែលមានការ ពាក់ព័ន្ធ
- ឯកសារកាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
អគ្គស្នងការដ្ឋាននគរបាលជាតិ
លេខ:...០០៩...

រាជធានីភ្នំពេញ, ថ្ងៃទី១១ ខែសីហា ឆ្នាំ២០១០

# សេចក្តីណែនាំ

## ស្តីពីការអនុវត្តកិច្ចប្រតិបត្តិការសង្គ្រោះជនរងគ្រោះ
## ដោយអំពើជួញដូរមនុស្ស និង/ឬការធ្វើអាជីវកម្មផ្លូវភេទ នៅតាមបណ្តាទីតាំងដែលបានកំណត់

ប្រតិបត្តិការសង្គ្រោះជនរងគ្រោះដោយអំពើជួញដូរមនុស្ស និង/ឬ ការធ្វើអាជីវកម្មនៅតាមបណ្តាទីតាំងដែលបានកំណត់ ត្រូវតែមានការរៀបចំ និងប្រព្រឹត្តទៅដោយប្រុងប្រយ័ត្ន ដោយផ្អែកលើគោលការណ៍គោរពសិទ្ធិជនរងគ្រោះនិងមិនត្រូវធ្វើឲ្យសុវត្ថិភាពរបស់ពួកគេប្រឈមនឹងហានិភ័យជាដាច់ខាត។ **គ្រប់កិច្ចប្រតិបត្តិការសង្គ្រោះត្រូវតែគោរពយ៉ាងខ្ជាប់ខ្ជួននៅតាមសេចក្តីណែនាំដូចខាងក្រោម:**

**១.មុនពេលធ្វើកិច្ចប្រតិបត្តិការសង្គ្រោះ**

-ប្រមូលព័ត៌មាន ដែលមានសារៈប្រយោជន៍ឲ្យបានច្រើន តាមដែលអាចធ្វើទៅបាន អំពីទីតាំងប្រតិបត្តិការសង្គ្រោះ ជនសង្ស័យដែលពាក់ព័ន្ធ ចំនួន និងស្ថានភាពរបស់ជនរងគ្រោះ ពីសាក្សីជនរងគ្រោះ អ្នកផ្តល់ព័ត៌មាន និងភ្នាក់ងារសម្ងាត់:

| |
|---|
| ***កំណត់ចំណាំ ការស៊ើបអង្កេតដោយប្រើភ្នាក់ងារសម្ងាត់ ត្រូវបានយកមកប្រើប្រាស់តែក្នុងគោលបំណងប្រមូលព័ត៌មាន និងប្រមូលភស្តុតាងដើម្បីកាត់ទោសឧក្រិដ្ឋជនតែប៉ុណ្ណោះ គឺមិនមែនមានចេតនាញុះញង់ឲ្យបុគ្គលណាមួយប្រព្រឹត្តបទល្មើសនោះឡើយ។*** |

-ត្រូវព្យាយាមគូរប្លង់ ទីតាំង ដោយបញ្ជាក់ច្បាស់ពីទីកន្លែង របស់ជនរងគ្រោះ និងជនសង្ស័យស្ថិតនៅត្រង់ ណា ត្រូវបញ្ជាក់អំពីទ្វារ និងច្រកចេញដទៃទៀត។

-ត្រូវរក្សាសម្ងាត់គ្រប់ព័ត៌មានទាំងអស់។

-ត្រូវធ្វើរបាយការណ៍ជូនថ្នាក់លើ និងព្រះរាជអាជ្ញាជាបន្ទាន់ នៅពេលដែលអ្នកប្រមូលបានព័ត៌មានទាំងអស់នោះ។

-ត្រូវធ្វើការឃ្លាំមើលលើទីតាំង។

+មន្ត្រីទទួលបន្ទុកត្រូវរាយការណ៍អំពីការចេញ ឬ ចូលទៅក្នុងទីតាំងទាំងអស់ ការដឹកជញ្ជូនជនរងគ្រោះចេញ ឬ ចូលទៅក្នុងទីតាំងប្រតិបត្តិការសង្គ្រោះ ពីសកម្មភាពរបស់ជនសង្ស័យ និងព័ត៌មានប្រហាក់ ប្រហែល ដែលបានប្រមូលក្នុងអំឡុងពេលឃ្លាំមើល។

-កំណត់ និងវាយតម្លៃហានិភ័យមកលើនគរបាល ជនរងគ្រោះ និងសមាជិកសហគមន៍។

+ចាត់វិធានការឲ្យបានគ្រប់គ្រាន់ដើម្បីគ្រប់គ្រងហានិភ័យ។

-ធានាថាព័ត៌មានដែលប្រមូលបាន ផ្តល់នូវមូលដ្ឋានគ្រប់គ្រាន់ សម្រាប់ការចូលឆែកឆេរទីតាំង និងសម្រាប់កិច្ចប្រតិបត្តិការសង្គ្រោះ បានប្រព្រឹត្តទៅដោយស្របច្បាប់។

-ត្រូវទទួលបានការអនុញ្ញាតពីព្រះរាជអាជ្ញាជាមុនសិន មុននឹងអនុវត្តប្រតិបត្តិការសង្គ្រោះ ឆែកឆេរ និងចាប់ខ្លួន។

+ត្រូវចងចាំចំពោះករណី ដែលត្រូវសុំការអនុញ្ញាតពីព្រះរាជអាជ្ញាជាបន្ទាន់ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ត្រូវតែជូនដំណឹងទៅព្រះរាជអាជ្ញាគ្រប់ករណីទាំងអស់ ប៉ុន្តែក្នុងករណីបន្ទាន់ការផ្តល់ការអនុញ្ញាតសម្រាប់ធ្វើការឆែកឆេរ អាចធ្វើឡើងដោយផ្ទាល់មាត់បាន។ ហើយការឆែកឆេរអាចធ្វើបាន គ្រប់ពេលវេលានៅតាមទីកន្លែងដែលបើកចំហជាសាធារណៈ។

-ត្រូវបង្កើតក្រុមការងារប្រតិបត្តិការសង្គ្រោះ និងត្រូវធ្វើការបែងចែកភារកិច្ចដល់សមាជិកទាំងអស់នៅក្នុងក្រុម។

+ចំនួនសមាសភាព និងសមាជិកនៅក្នុងក្រុមប្រតិបត្តិការសង្គ្រោះ គឺអាស្រ័យទៅលើស្ថានភាព និងហានិភ័យ (ដែលជាធម្មតាត្រូវមានចំនួនមន្ត្រីពី ១០ ទៅ ២០នាក់)។

-រៀបចំការប្រជុំផ្សព្វផ្សាយខ្លីមួយ ដើម្បីធានាថា សមាជិកនៅក្នុងក្រុមទាំងអស់ យល់ពីភារកិច្ចរបស់ពួកគេម្នាក់ៗនៅក្នុងកិច្ចប្រតិបត្តិការនិងដឹងពីវិធីដើម្បីធានានូវសុវត្ថិភាពដល់ជនរងគ្រោះនិងសិទ្ធិរបស់ជនរង គ្រោះ នៅក្នុងអំឡុងពេលនៃកិច្ចប្រតិបត្តិការសង្គ្រោះ។

-ត្រូវរៀបចំសម្ភារៈ ឧបករណ៍ចាំបាច់សំខាន់ៗនានា(ដូចជាយានជំនិះ វិទ្យុទាក់ទង ទូរស័ព្ទដៃ អាវុធរបស់ នគរបាល ខ្នោះដៃ ពិល កាមេរ៉ាថតរូប និងថតវីដេអូ កំណត់ហេតុឆែកឆេរ និងស្រោមសម្រាប់ប្រមូល និង វេច ខ្ចប់វត្ថុតាង)។

-ត្រូវជួបជាមួយមន្ត្រីមន្ទីរសង្គមកិច្ច និងអង្គការក្រៅរដ្ឋាភិបាល ដែលមានឯកទេសដើម្បីធានាថា ជនរងគ្រោះនឹងទទួលបាននូវតម្រូវការចាំបាច់ (ដូចជា ទឹក ចំណីអាហារ......................) ការសង្គ្រោះបន្ទាន់ ប្រសិនជាចាំបាច់ត្រូវមានការគាំទ្រខាងផ្លូវចិត្ត និងសង្គម បន្ទាប់ពីធ្វើកិច្ចប្រតិបត្តិការសង្គ្រោះ។

+ត្រូវទំនាក់ទំនងជាមួយបុគ្គលិកមន្ទីរសង្គមកិច្ច និង បុគ្គលិកអង្គការក្រៅរដ្ឋាភិបាលដែលមានឯកទេសដើម្បីដឹងជាមុនថា តើគេត្រូវធ្វើការរៀបចំសម្រាប់ជនរងគ្រោះប៉ុន្មាននាក់ តើពេលណាដែលកិច្ចប្រតិបត្តិការសង្គ្រោះនេះនឹងកើតឡើង និងទីកន្លែងដែលជនរងគ្រោះត្រូវស្នាក់នៅ បន្ទាប់ពីកិច្ចប្រតិបត្តិការសង្គ្រោះ។

-ត្រូវកំណត់លើកាលបរិច្ឆេទ និងពេលវេលាសម្រាប់កិច្ចប្រតិបត្តិការសង្គ្រោះ។

**<u>២.អនុវត្តប្រតិបត្តិការសង្គ្រោះ ឆែកឆេរ និង ចាប់ខ្លួន:</u>**

-មន្ត្រីម្នាក់ៗត្រូវប្រកាន់ខ្ជាប់នូវភារកិច្ច តាមមុខងារដែលបានប្រគល់និងត្រៀមនៅជិតទីតាំងដែលត្រូវសង្គ្រោះតាមការកំណត់។

-ត្រូវធានាសុវត្ថិភាព ដល់ការចូលទៅកាន់ទីតាំងត្រូវសង្គ្រោះ និងត្រូវប្រាកដថាជនរងគ្រោះមានវត្តមាននៅទីនោះ។

+កំណត់អត្តសញ្ញាណ និងចាប់ខ្លួនជនសង្ស័យទាំងអស់ រួមទាំងភ្ញៀវផងដែរ ប្រសិនបើមានការពាក់ព័ន្ធនឹងអនីតិជន នៅក្នុងករណីដែលប្រតិបត្តិការសង្គ្រោះធ្វើនៅក្នុងផ្ទះបន រង្គសាល ភោជនីយដ្ឋាន ការ៉ាអូខេ ហាងម៉ាស្សា ឬក៏ទីតាំងធ្វើអាជីវកម្មផ្លូវភេទដែលមានលក្ខណៈប្រហាក់ប្រហែល។

+ធ្វើសកម្មភាពឲ្យបានឆាប់រហ័ស ម៉ឺងម៉ាត់ ប៉ុន្តែបើមិនចាំបាច់ទេមិនត្រូវប្រើកម្លាំងច្រើនឡើយ។

-ត្រូវបញ្ជូនជនរងគ្រោះ និងទ្រព្យសម្បត្តិរបស់ពួកគេទៅកាន់កន្លែងដែលមានសុវត្ថិភាព។

-ត្រូវប្រាប់ឲ្យជនសង្ស័យបានដឹងពីមូលហេតុ នៃកិច្ចប្រតិបត្តិការ និងហេតុផលនៃការចាប់ខ្លួន។

-ត្រូវថតយករូបភាពកន្លែងកើតហេតុ ដោយមិនត្រូវរំកិល ឬ ប៉ះពាល់របស់អ្វី ប្រសិនបើគ្មានការចាំបាច់។

-ត្រូវធ្វើការឆែកឆេរលើទីតាំងសង្គ្រោះទាំងមូល ទៅតាមវិធីសាស្ត្រត្រឹមត្រូវ ដោយមានការអនុញ្ញាតពីព្រះ រាជអាជ្ញា និងនៅចំពោះមុខជនសង្ស័យ ឬវត្តមានរបស់ម្ចាស់ផ្ទះ/អ្នកគ្រប់គ្រង ឬ ក៏សាក្សីពីរនាក់។

+ការឆែកឆេរនេះធ្វើឡើងក្នុងគោលបំណងដើម្បីស្វែងរកជនរងគ្រោះដទៃទៀត និងដើម្បីចាប់យក ភស្តុតាងនានា ដូចជា អត្តសញ្ញាណប័ណ្ណ ឯកសារធនាគារ ប្រាក់កាស ថ្នាំញៀន ឧបករណ៍តេទស៊ីនី នីវីឌី កុំព្យូទ័រ ឧបករណ៍ផ្ទុកទិន្នន័យ ទូរស័ព្ទដៃ និងសម្ភារៈដទៃទៀត ដែលពាក់ព័ន្ធករណី។

-ត្រូវធ្វើការទំនាក់ទំនងជាមួយជនរងគ្រោះដែលបានសង្គ្រោះដោយលក្ខណៈទន់ភ្លន់មានជំនឿទុកចិត្ត និងត្រូវប្រាប់ឲ្យពួកគេដឹងថា ពេលទៅដល់ទីកន្លែងថ្មីពួកគេនឹងទទួលបានការជួយឧបត្ថម្ភពីបុគ្គលិកក្រសួងសង្គមកិច្ច ឬអង្គការក្រៅរដ្ឋាភិបាល។

-ត្រូវចុះក្នុងកំណត់ហេតុរាល់ទ្រព្យសម្បត្តិផ្ទាល់ខ្លួនទាំងអស់របស់ជនរងគ្រោះ ដែលត្រូវបានដកហូតជាបណ្តោះអាសន្ន ដូចជា ទូរស័ព្ទដៃ សៀវភៅភាសយដ្ឋាន ប្រាក់កាស និងរបស់ដទៃទៀត និងថតចម្លង កំណត់ហេតុនោះជូនជនរងគ្រោះ។

+ប្រសិនបើទ្រព្យសម្បត្តិណាដែលគេមិនត្រូវការយកមកធ្វើជាភស្តុតាងទេទ្រព្យសម្បត្តិនោះគប្បី ប្រគល់ជូនទៅម្ចាស់ដើមវិញ បន្ទាប់ពីនគរបាលបានសម្ភាសន៍រួច។

+ត្រូវតាំងតាំងមន្ត្រីម្នាក់ឲ្យគ្រប់គ្រងទ្រព្យសម្បត្តិទាំងនេះ។

-ត្រូវធានាបានសុវត្ថិភាពក្នុងការដឹកជញ្ជូនជនរងគ្រោះទៅកាន់ទីស្នាក់ការរបស់នគរបាល។

+ត្រូវដឹកជញ្ជូនជនរងគ្រោះ និងជនសង្ស័យដោយរថយន្តផ្សេងពីគ្នា។

+ត្រូវបំបែកជនរងគ្រោះពេញវ័យចេញពីជនរងគ្រោះដែលជាអនីតិជន ឬត្រូវគេសង្ស័យថាជាអនីតិ ជន។

**៣.ក្រោយពីកិច្ចប្រតិបត្តិការ:**

-ត្រូវធ្វើការឆែកឆេរខ្លួនប្រាណ និងឃុំខ្លួនជនសង្ស័យនៅកន្លែងសុវត្ថិភាពរបស់នគរបាល។

+មិនត្រូវអនុញ្ញាតឲ្យជនសង្ស័យទំនាក់ទំនងគ្នា ឬទំនាក់ទំនងជាមួយជនរងគ្រោះ។

-ត្រូវសហការជាមួយមន្ទីរសង្គមកិច្ចដើម្បីផ្តល់សេវាសង្គម និងសេវាចិត្តសាស្ត្រដល់ជនរងគ្រោះ និង ដើម្បីសម្របសម្រួលការសម្ភាសន៍ជាមួយពួកគេ ព្រមទាំងផ្តល់ជូនពួកគេនូវតម្រូវការចាំបាច់នានា។

–តម្រូវការជាចាំបាច់ និងសិទ្ធិរបស់ជនរងគ្រោះ ត្រូវបានកំណត់នៅក្នុងបទដ្ឋានអប្បបរមាសម្រាប់ ការពារសិទ្ធិរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស។

-ត្រូវពន្យល់ប្រាប់ជនរងគ្រោះអំពីរបៀប និងហេតុផលនៃការសម្ភាសន៍។

–ត្រូវពន្យល់ប្រាប់ជនរងគ្រោះថា ពួកគេមិនបានប្រព្រឹត្តបទល្មើសណាមួយទេ ហើយពួកគេក៏មិន

ត្រូវបានចាប់ខ្លួនដែរ និងត្រូវពន្យល់ទៀតថា ពួកគេមានសុវត្ថិភាព ហើយនឹងទទួលបានការ គាំពារពីសេវាកម្មនគរបាល និងសង្គម។

-ត្រូវធ្វើបទសម្ភាសន៍មួយដែលផ្តោតលើផលប្រយោជន៍ជនរងគ្រោះ ហើយការសម្ភាសន៍នេះត្រូវធ្វើនៅក្នុង បរិយាកាសមេត្រីភាព ដោយគ្មានការគំរាមកំហែង ឬការយាយីឡើយ។

+នៅពេលដែលនគរបាលសម្ភាសន៍ជនរងគ្រោះគប្បីមានវត្តមានអាណាព្យាបាល ឬមេធាវី។ រីឯការសម្ភាសន៍កុមារវិញត្រូវតែមានវត្តមានរបស់បុគ្គលដែលធ្វើជាតំណាងការពារឧត្តមប្រយោជន៍ របស់កុមារ។

+ប្រសិនបើមានសំណូមពរ ត្រូវផ្តល់ជូនជនរងគ្រោះនូវពេលវេលាសមស្របសម្រាប់ឆ្លើយនឹង សំណួរ និងផ្តល់ពេលឲ្យឈប់សំរាក ហើយទន្ទឹមនឹងនោះ ពួកគេក៏មានសិទ្ធិ មិនឆ្លើយតបនឹងសំណួរណាមួយ។

+រាល់គ្រប់ការសម្ភាសន៍ត្រូវធ្វើកំណត់ហេតុឲ្យបានពេញលេញ។

-ត្រូវតែដឹងថា អ្នកចង់បាននូវកំណត់ហេតុដែលដាក់បន្ទុកដល់ការផ្តន្ទាទោសជនល្មើស ដូច្នេះត្រូវសួរនូវសំណួរទាំងឡាយណាដែលពាក់ព័ន្ធ។

-ត្រូវបញ្ជូនភស្តុតាង និងជនសង្ស័យទៅតុលាការឲ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាននៅក្នុងរយៈពេល៤៨ម៉ោង។

-ត្រូវប្រគល់ទ្រព្យសម្បត្តិជូនជនរងគ្រោះវិញ។

-ត្រូវធ្វើការសហការជាមួយអាជ្ញាធរដែនដីដើម្បីបិទទ្វារទីតាំងដែលបានប្រើប្រាស់សម្រាប់ធ្វើអាជីវកម្មលើជនរងគ្រោះ ទាំងការធ្វើអាជីវកម្មពលកម្ម និងអាជីវកម្មផ្លូវភេទ។

-ត្រូវសម្ភាសន៍ជនសង្ស័យឲ្យបានម៉ត់ចត់។

+ត្រូវធ្វើកំណត់ហេតុពីការសម្ភាសន៍នេះ។

រៀបចំកសាងសំណុំរឿង និងរបាយការណ៍បញ្ជូនទៅព្រះរាជអាជ្ញា ហើយប្រសិនបើព័ត៌មានដែលប្រមូលបាន មានពាក់ព័ន្ធដល់ជនល្មើស ឬ ជនរងគ្រោះដទៃទៀត ដែលកំពុងស្ថិតនៅក្នុងស្ថានភាពត្រូវគេធ្វើអាជី វកម្ម គប្បីរាយការណ៍ព័ត៌មានទាំងនេះជូនមន្ត្រីទទួលបន្ទុកបានជ្រាប។

ទទួលបានសេចក្តីណែនាំនេះ នាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ នាយកដ្ឋានជំនាញ និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្តទាំងអស់ត្រូវពាក់ព័ន្ធអនុវត្តឱ្យមានប្រសិទ្ធភាព។

**អគ្គស្នងការដ្ឋាននគរបាលជាតិ**

នាយឧត្តមសេនីយ៍.នេត_សាវឿន

ចម្លងជូន

.ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
.ឯកឧត្តមរដ្ឋលេខាធិការក្រសួងមហាផ្ទៃ
.ឯកឧត្តមអគ្គលេខាធិការក្រសួងមហាផ្ទៃ
.ស្នងការនគរបាលរាជធានី.ខេត្ត
.ឯកសារ-កាល្បវត្ត

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

តុលាការ

ខេត្តសៀមរាប_ឧត្តរមានជ័យ

សំណុំរឿងព្រហ្មទណ្ឌ

លេខ ១០១ ចុះថ្ងៃទី ២២

ខែ កុម្ភៈ ឆ្នាំ ២០០៦

សាលក្រម

លេខ ០៤ (ង) ចុះថ្ងៃទី ៣០

ខែ ឧសភា ឆ្នាំ ២០០៦

សាលក្រមនេះចូលជាស្ថាពរ ចាប់ពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៦

ដោយពុំមានភាគីណាមួយបានប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

សៀមរាប.ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៦

ក្រឡាបញ្ជី

ហត្ថលេខា និង ត្រា យ៉េង ជា

**នាមនាមប្រជារាស្ត្រខ្មែរ**

**តុលាការខេត្តសៀមរាប_ឧត្តរមានជ័យ**

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី នៃរដ្ឋកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៦ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ។

បានបើកសវនាការជាសាធារណៈ នៅនាទីតុលាការខេត្តសៀមរាប នាថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៦ ដោយមានសមាសភាព :

**ចៅក្រមជំនុំជំរះ**

លោក **ឃន សុគល** ចៅក្រមតុលាការខេត្ត

**តំណាងអយ្យការ**

លោក **ម៉ី ម៉ិនឆាន** ព្រះរាជអាជ្ញារងអមតុលាការខេត្ត

**ក្រឡាបញ្ជីសវនាការ**

លោក **យ៉េង ជា**

**ដើម្បីជំនុំជំរះ :**

សំណុំរឿងព្រហ្មទណ្ឌលេខ ១០១ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០៦ ដែលមានជនជាប់ចោទ :

ឈ្មោះ **ឱ ខ** ហៅ **ជ** ភេទប្រុស អាយុ ១៧ឆ្នាំ ជាតិខ្មែរ កើតនៅភូមិចុងឃ្លៀស ឃុំសៀមរាប ស្រុកសៀមរាប ខេត្តសៀមរាប កំរិតវប្បធម៌ថ្នាក់ទី១ សាសនាព្រះពុទ្ធ ទីលំនៅមុនពេលចាប់ខ្លួននៅភូមិចុងឃ្លៀស ឃុំសៀមរាប ស្រុកសៀមរាប ខេត្តសៀមរាប របររកស៊ី គ្មាន ឪពុកឈ្មោះ **ឱ ឱ** (ស) ម្តាយឈ្មោះ **ឥ ព** (ស) ទោសពីមុន *គ្មាន* ។ ចាប់ខ្លួននៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០៦ ។

ត្រូវចោទពីបទ **រំលោភសេពសន្ថវៈ** ប្រព្រឹត្តនៅមណ្ឌល២ ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០៦ ។

បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្តន្ទាទោសតាមមាត្រា ៥ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ចុះថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០០២ ។

ដោយមានលោក **ទឹម ឈុនឡេង** ជាមេធាវីការពារសិទ្ធិជនជាប់ចោទ

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ **ប សគន** ភេទស្រី អាយុ ៣៨ឆ្នាំ ជាតិខ្មែរ របររកស៊ីនៅផ្ទះ ទីលំនៅសព្វថ្ងៃ ភូមិត្រពាំងសេះ ឃុំគោកចក ស្រុកសៀមរាប ខេត្តសៀមរាប ។

ដោយមានលោក **ម៉ុល សុន** ជាមេធាវីការពារសិទ្ធិជនជាប់ចោទ

## ការប្រព្រឹត្តិរបស់ជនជាប់ចោទមានដូចតទៅ

កាលពីថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៦ វេលាម៉ោង ១០យប់ ឈ្មោះ **ឌ ខ** និង មិត្តភក្តិរបស់គេមានគ្នា ០៦នាក់ បាននាំគ្នាដើរលេងនៅបឹងតីឡូមុខព្រះរាជដំណាក់ស្ថិតនៅមណ្ឌល២ ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប ។ ពេលនោះឈ្មោះ **ឌ ខ** បានជួបស្រីៗនៅទីងបឹងតីឡូចំនួន ០៤ ឬ ០៥នាក់ តែឈ្មោះ **ឌ ខ** បានស្គាល់ឈ្មោះ **ហ សម** រួចបានបបួល **សម** ជិះកង់ថាជូនទៅផ្ទះ ។ ពេលនោះឈ្មោះ **ឌ ខ** ឆ្លៀតឱកាសចូលទៅបន្ទប់ទឹកនៅសួនច្បារព្រះរាជដំណាក់ថា ទៅជួបមិត្តភក្តិគេ ។ ឈ្មោះ **ហ សម** បានចូលបន្ទប់ទឹកដែរ ឈ្មោះ **ឌ ខ** បានដើរចូលទៅតាមក្រោយចាប់អោប **ហ សម** ពីក្រោយចាប់ស្រាតខោនាង **ហ សម** បន្ទាប់មកក៏ស្រាតខោខ្លួនឯងយកស្រោមអនាម័យពាក់ទីងលឹង្គរបស់ខ្លួន រួចដាក់ចូលក្នុងប្រដាប់ភេទនាង **ហ សម** ហើយធ្វើចលនារួមរ័ក្សរហូតបានសំរេច ។ ឈ្មោះ **ឌ ខ** ត្រូវសមត្ថកិច្ចចាប់ខ្លួននៅថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៦ ។

## នាពេលសវនាការ

ជនជាប់ចោទឈ្មោះ **ឌ ខ** បានឆ្លើយថា កាលពីថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៦ វេលាម៉ោង ១០យប់ ខ្លួន និង មិត្តភក្តិចំនួន ០៦នាក់ទៀត បានដើរលេងសួនច្បារបឹងតីឡូមុខព្រះរាជដំណាក់ ហើយបានជួបនឹងនាង **រ** ហើយខ្លួនក៏បានទាក់ទងនឹងឈ្មោះ **រ** ជាមេបនដើររកស្រីអោយខ្លួន ហើយខ្លួនក៏បានប្រគល់ប្រាក់ចំនួន ៥.០០០រៀលជាតម្លៃរ៉ៃសិច ។ ពេលនោះឈ្មោះ **រ** បានអោយខ្លួនទៅជួបស្រីម្នាក់ឈ្មោះ **ហ សម** ពេលជួបនាងហើយ នាងក៏បានព្រមព្រៀងជាមួយខ្លួន ហើយខ្លួននាំនាងទៅតាមមាត់ស្ទឹងខាងកើតបឹងតីឡូមានបង្គន់សាធារណៈ ក៏បានជួបនឹងឈ្មោះ **ម** ជាអ្នកថែសួន និង ជាអ្នកអនាម័យបង្គន់ ។ ឈ្មោះ **ម** បានផ្តល់ទីកន្លែងអោយខ្លួនដើម្បីរួមរ័ក្សជាមួយនាង ។ ឈ្មោះ **ម** បានដឹងពីបំណងរបស់ខ្លួនហើយ ពីព្រោះមិត្តភក្តិរបស់ខ្លួនធ្លាប់បានរួមរ័ក្សនៅក្នុងបន្ទប់ទឹកនេះ ។ ពេលចូលក្នុងបន្ទប់ទឹកនាង **ហ សម** ដោះខោអាវចេញដោយខ្លួនឯង ហើយបានដេកផ្ងារលើឥដ្ឋ ហើយខ្លួនក៏ដោះខោអាវរបស់ខ្លួនចេញពាក់ស្រោមអនាម័យលើលឹង្គរបស់ខ្លួន និង ចាប់ផ្តើមរួមរ័ក្សជាមួយនាង **សម** រហូតបានសំរេច ។ ក្រោយពីរួមរ័ក្សហើយខ្លួនបានអោយនាងនៅឈរចាំ និង មើលទូរទស្សន៍នៅទីនោះសិន ដោយខ្លួនយកកង់ទៅអោយមិត្តភក្តិសិន ប៉ុន្តែពុំបានមកជួបនាងវិញទេ ដោយនៅលេងជាមួយមិត្តភក្តិឯសួនច្បារ ។ វិលងបានប្រហែល ១ម៉ោង ខ្លួនត្រូវនគរបាលចាប់ខ្លួនតែម្តង ។

ជនរងគ្រោះឈ្មោះ **ហ សម** បានឆ្លើយថា កាលពីថ្ងៃខែមិនចាំឆ្នាំ ២០០៦ វេលាម៉ោង ០៧យប់ ខ្លួន និង ឈ្មោះ **ត** ឈ្មោះ **ត** ឈ្មោះ **រ** នាំគ្នាមកអង្គុយលេងនៅសួនច្បារ ។ មួយសន្ទុះក្រោយមក ខ្លួនឃើញមនុស្សប្រុសម្នាក់ជិះកង់មកបបួលខ្លួនទៅរ៉ៃសិច ខ្លួនក៏យល់ព្រមជាមួយ ដោយជិះកង់ឌុបគ្នាមកកន្លែងបង្គន់អនាម័យជាប់មាត់ស្ទឹង ។ ពេលមកដល់បន្ទប់បង្គន់អនាម័យមនុស្សប្រុសនោះ អោយខ្លួនចូលទៅក្នុងបន្ទប់ រួចខ្លួនក៏ដោះខោអាវបុរសនោះក៏រួមរ័ក្សជាមួយខ្លួនរហូតដល់បានសំរេច ហើយខ្លួនស្លៀកពាក់ខោអាវដើរចេញមកក្រៅរង់ចាំគេប្រគល់ប្រាក់អោយខ្លួន ។ ដោយរង់ចាំយូរពេក ខ្លួនក៏ប្តឹងនគរបាលថាគេចាប់រំលោភ ហើយនគរបាលចាប់ជននោះតែម្តង ។ ខ្លួនមិនដែលស្គាល់ជននោះទេ ដោយស្គាល់តាមរយៈឈ្មោះ **រ** ។

នៅក្នុងរឿងនេះ ខ្លួនពុំប្តឹងទាមទារសំណងអ្វីទេ ហើយសុំឈប់ប្តឹងពីជននេះហើយ ។

## តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានទោសថា

ឆ្លងតាមសវនាការនេះ តាមចម្លើយជនជាប់ចោទ និង តាមចម្លើយជនរងគ្រោះ នាពេលសវនាការនេះឃើញថា គ្មានពិរុទ្ធភាពលើជនជាប់ចោទទេ ។

ហេតុនេះ សូមតុលាការពិចារណាសំរេចតាមច្បាប់ចុះ ។

**មេធាវីការពារសិទ្ធិជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា**

ជនជាប់ចោទពិតជាបានរួមរ័ក្សជាមួយជនរងគ្រោះពិតប្រាកដមែន ។ ប៉ុន្តែជនជាប់ចោទ និងជនរងគ្រោះបានព្រមព្រៀងគ្នា ។

ហេតុនេះ សូមតុលាការមេត្តាដោះលែងជនជាប់ចោទ ដោយក្តីអនុគ្រោះ ។

**មេធាវីការពារសិទ្ធិជនរងគ្រោះបានធ្វើសេចក្តីសន្និដ្ឋានថា**

ជនជាប់ចោទ និង ជនរងគ្រោះពិតជាបានឯកភាពគ្នារួមរ័ក្សមែន ប៉ុន្តែសូមតុលាការមេត្តាពិចារណាលើសំណង ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយជនរងគ្រោះ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានទោសរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីជនរងគ្រោះ

-ក្រោយពីបានស្តាប់ជនជាប់ចោទនិយាយសំដីចុងក្រោយបង្អស់

**តុលាការ**

ក្រោយពីបានពិនិត្យត្រឹមត្រូវតាមច្បាប់ហើយ

-យល់ឃើញថា កាលពីថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៦ វេលាម៉ោង ១០យប់ ជនជាប់ចោទឈ្មោះ **ឌ ខ** បានមកលេងនៅបឹងកីឡាមុខព្រះរាជវាំង ហើយបានជួបនឹងនាង **រ** ជាមេបន ក៏មានការទាក់ទងដើម្បីរកស្រីអោយខ្លួន ហើយខ្លួនក៏បានប្រគល់ប្រាក់ចំនួន ៥.០០០រៀលទៅឈ្មោះ **រ** ជាតម្លៃរឺសិចរួចហើយឈ្មោះ **រ** បានអោយខ្លួនទៅជួបស្រីម្នាក់ឈ្មោះ **ហ សម** ពេលជួបហើយ នាងក៏បានព្រមព្រៀងជាមួយខ្លួនជិះកង់ឌុបគ្នាទៅបន្ទប់ទឹកនៅជិតសួនច្បារព្រះរាជដំណាក់រួមរ័ក្សគ្នារហូតដល់បានសំរេច ។

-យល់ឃើញថា ការប្តឹងចោទរបស់ឈ្មោះ **ហ សម** គឺជាល្បិចដើម្បីទារប្រាក់ពីជនជាប់ចោទតែប៉ុណ្ណោះ ព្រោះហេតុថា ពេលរួមរ័ក្សនាង **ហ សម** បានព្រមព្រៀងដោយស្ម័គ្រចិត្ត ព្រមទាំងដោះសំលៀកបំពាក់ដោយខ្លួនឯងពុំមានការបង្ខិតបង្ខំឡើយ រហូតដល់បានសំរេច តែដោយជនជាប់ចោទពុំបានប្រគល់ប្រាក់អោយទើបនាងប្តឹងនគរបាលថា រំលោភទៅវិញ ។

-យល់ឃើញថា គ្មានភស្តុតាងចួនល្មមបញ្ជាក់ថា ឈ្មោះ **ឌ ខ** ប្រព្រឹត្តបទល្មើសរំលោភសេពសន្ធវៈលើនាង **ហ សម** កាលពីថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៦ នៅមណ្ឌល២ ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប ។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង អោយផ្តន្ទាទោសតាមមាត្រា ៥ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ចុះថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០០២ ។

-យល់ឃើញថា ជនរងគ្រោះឈ្មោះ **ឈា សម** បានឆ្លើយនៅចំពោះសវនាការថា ខ្លួនសុំឈប់ប្តឹងពីជនជាប់ចោទទៀតហើយ តុលាការបានពិចារណារួចហើយ ។

## <u>**ហេតុដូច្នេះទើបសំរេចសេចក្តី**</u>

១-អោយឈ្មោះ **ឌ ខ** ( ហៅ **ជ** ) រួចផុតពីបទចោទ ។

ពីបទ **រំលោភសេពសន្ថវៈ** ប្រព្រឹត្តនៅភូមិមណ្ឌល២ ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៦ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង អោយផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៥ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ចុះថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០០២ ។

២-សាលក្រមនេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ ជនរងគ្រោះឈ្មោះ **ឈា សម** បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

| | |
|---|---|
| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមជំនុំជំរះ** |
| **ហត្ថលេខា និង ត្រា** | **ហត្ថលេខា និង ត្រា** |
| **យេង ដា** | **យន សុភល** |

---

**បានឃើញ**

*សៀមរាប,ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០៦*

**ប្រធានតុលាការខេត្ត**

**អ៊ាំង មាលតី**

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ឆា រ៉ាត

បន្ទប់ "ឋ" ជាន់ទី៣

**អយ្យការអមសាលាដំបូង**
**រាជធានីភ្នំពេញ**
សំណុំរឿងព្រហ្មទណ្ឌលេខៈ ១២៨០
ចុះថ្ងៃទី ១៨.០៣.២០១៦

# <u>ដីកាកោះ</u>

**យើង សៀង សុខ ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ**

អញ្ជើញឈ្មោះ **ត វ ច** ជា ជនសង្ស័យ

មានអាស្រ័យដ្ឋាន ផ្ទះលេខA២៣ ភូមិទួលតាចាន់ សង្កាត់ព្រែកឯង ខណ្ឌច្បារអំពៅរាជធានីភ្នំពេញ។

អោយចូលទៅកាន់ អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

នៅថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១៦ វេលាម៉ោង ០៩ និង០០វិនាទី

ដើម្បី សាកសួរ

ពីដំណើររឿង ពាក់ព័ន្ធនឹងអំពើពេស្យាចារ

សាមីខ្លួនត្រូវអញ្ជើញតាមដីកានេះ ឲ្យទាន់ពេវេលា និងយកលិខិតផ្សេងៗដែល

ទាក់ទងនឹងរឿងខាងលើមកជាមួយផង ប្រសិនបើមាន។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៦

**ជ.ព្រះរាជអាជ្ញា**

**សៀន សុខ**

ព្រះរាជអាជ្ញារង

យើង ..........................................................................................................

បានប្រគល់លិខិតអញ្ជើញនេះឲ្យឈ្មោះ ..............................................................................

ទីលំនៅសព្វថ្ងៃ ..........................................................................................................

នៅថ្ងៃទី.............ខែ.............ឆ្នាំ.............ផ្ទាល់រួចហើយ ដោយយើងបានទុកចុងដីកានេះ មួយច្បាប់ ឲ្យសាមីខ្លួន ហើយប្រាប់ថាឲ្យសាមីខ្លួនប្រគល់ចុងដីកាដល់ក្រលាបញ្ជី នៅពេលខ្លួនចូលដល់ តុលាកា ឬអយ្យការ។

**អ្នកទទួលលិខិត** **អ្នកប្រគល់លិខិត**

ហត្ថលេខា ឬស្នាមមេដៃ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ឆា វ៉ាត

បន្ទប់ "ប" ជាន់ទី៣

**អយ្យការអមសាលាដំបូង**
**រាជធានីភ្នំពេញ**

សំណុំរឿងព្រហ្មទណ្ឌលេខ: ១២៨០
ចុះថ្ងៃទី ១៨.០៣.២០១៦

# <u>ដីកាកោះ</u>

**យើង សៀង សុខ ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ**

អញ្ជើញឈ្មោះ **ពរន** ជា ជនសង្ស័យ

មានអាស្រ័យដ្ឋាន ផ្ទះលេខ៨០ ផ្លូវ១៧CA សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

អោយចូលទៅកាន់ អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

នៅថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១៦ វេលាម៉ោង ១៤ និង៣០វិនាទី

ដើម្បី សាកសួរ

ពីដំណើររឿង ពាក់ព័ន្ធនឹងអំពើពេស្យាចារ

សាមីខ្លួនត្រូវអញ្ជើញតាមដីកានេះ ឲ្យទាន់ពេវេលា និងយកលិខិតផ្សេងៗដែល

ទាក់ទងនឹងរឿងខាងលើមកជាមួយផង ប្រសិនបើមាន។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៦

**ជ.ព្រះរាជអាជ្ញា**

**សៀន សុខ**

ព្រះរាជអាជ្ញារង

យើង ..........................................................................................................

បានប្រគល់លិខិតអញ្ជើញនេះឲ្យឈ្មោះ ..........................................................................

ទីលំនៅសព្វថ្ងៃ..............................................................................................

នៅថ្ងៃទី.............ខែ............ឆ្នាំ.............ផ្ទាល់រួចហើយ ដោយយើងបានទុកចុងដីកានេះ មួយច្បាប់ឲ្យសាមីខ្លួន ហើយប្រាប់ថាឲ្យសាមីខ្លួនប្រគល់ចុងដីកាដល់ក្រលាបញ្ជី នៅពេលខ្លួន ចូលដល់តុលាកា ឬអយ្យការ។

**អ្នកទទួលលិខិត** **អ្នកប្រគល់លិខិត**

ហត្ថលេខា ឬស្នាមមេដៃ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ឆា រ៉ាត

បន្ទប់ "ប" ជាន់ទី៣

**អយ្យការអមសាលាដំបូង**
**រាជធានីភ្នំពេញ**

សំណុំរឿងព្រហ្មទណ្ឌលេខ: ១២៨០
ចុះថ្ងៃទី ១៨.០៣.២០១៦

# ដីកាកោះ

**យើង សៀង សុខ ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ**

អញ្ជើញឈ្មោះ **ក ស ខ** ជា **សាក្សី**

មានអាស្រ័យដ្ឋាន ផ្ទះលេខ៩៧ ផ្លូវ៣១៣ សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

អោយចូលទៅកាន់ **អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ**

នៅថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៦ វេលាម៉ោង ០៩ និង០០វិនាទីព្រឹក

ដើម្បី សាកសួរ

ពីដំណើររឿង **ពាក់ព័ន្ធនឹងអំពើសញ្ជារកម្ម**

សាមីខ្លួនត្រូវអញ្ជើញតាមដីកានេះ ឲ្យទាន់ពេវេលា និងយកលិខិតផ្សេងៗដែលទាក់ទងនឹងរឿងខាងលើមកជាមួយផង ប្រសិនបើមាន។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៦

**ជ.ព្រះរាជអាជ្ញា**

**សៀង សុខ**

ព្រះរាជអាជ្ញារង

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**

**សាលាដំបូងរាជធានីភ្នំពេញ**

សំណុំរឿងព្រហ្មទណ្ឌលេខ: ២៥០១

ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៦

លេខ: ១៣៨២អ.យ.ប

# ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ

## យើង សៀង សុខ តំណាងអយ្យការ អមសាលាដំបូងរាជធានីភ្នំពេញ

– បានឃើញរបាយការណ៍សំយោគលេខ ៥៥/២០១៦ រ.ប.ក ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៦ របស់ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ[1]។

## ក្រោយពីបានពិនិត្យឯកសារខាងលើ

យល់ឃើញថា មានតម្រុយសន្មត់បានថា៖

នាម-គោត្តនាៈ **ក ស ខ** ភេទប្រុស អាយុ ៦៣ឆ្នាំ មុខរបរ តំណាងរាស្ត្រមណ្ឌលខេត្តកំពង់ចាម កើតនៅថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ១៩៥៣ ទីកន្លែងកំណើត ឃុំឧត្តមសូរិយា ស្រុកត្រាំកក់ ខេត្តតាកែវ ទីលំនៅបច្ចុប្បន្នផ្ទះលេខ៩៧ ផ្លូវ៣១៣ សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ជានីតិជន។

អង្គហេតុនៃសំណុំរឿងមានដូចតទៅ[2] អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បាននឹងកំពុងចាត់ការលើសំណុំរឿងព្រហ្មទណ្ឌលេខ១២៨០ ចុះថ្ងៃទី ១៨.០៣.២០១៦ ទាក់ទងនឹងអំពើសញ្ជារកម្ម។ នៅក្នុងសំណុំរឿងនេះតំណាងអយ្យការធ្វើការកោះហៅ ឯកឧត្តម **ក ស ខ** ចំនួន ពីរលើក៖

– កាលពីថ្ងៃទី៤ ខែឧសភា ឆ្នាំ ២០១៦ អយ្យការអមសាលាដំបូងរាជធានីភ្នំពេញបានធ្វើការកោះហៅឯកឧត្តម កឹម សុខា ក្នុងឋានៈជាសាក្សីដើម្បីចូលមកបំភ្លឺនៅចំពោះមុខតំណាងអយ្យការ នៅថ្ងៃទី ១៧ ខែឧសភា ឆ្នាំ ២០១៦ វេលាម៉ោង ៩ ព្រឹក ប៉ុន្តែ ឯកឧត្តម **ក ស ខ** មិនបានចូលមកបំភ្លឺក្នុងឋានៈជាសាក្សី តាមដីកាកោះហៅរបស់តំណាងអយ្យការឡើយ។

– នៅថ្ងៃទី ១៧ ខែមេសា ឆ្នាំ ២០១៦ តំណាងអយ្យការបានចេញដីកាកោះហៅជាលើកទី ២ ម្តងទៀតដើម្បីអញ្ជើញ ឯកឧត្តម **ក ស ខ** មកឆ្លើយបំភ្លឺក្នុងឋានៈជាសាក្សី នៅថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០១៦ វេលាម៉ោង ៩ព្រឹក ប៉ុន្តែ ឯកឧត្តម **ក ស ខ** នៅតែមិនចូលខ្លួនមក បំភ្លឺនៅចំពោះមុខតំណាងអយ្យការដដែល ដោយគ្រាន់តែ

[1] លេខសំណុំរឿងរបស់អគ្គភាពនគរបាលយុត្តិធម៌

[2] សេចក្តីសង្ខេបអង្គហេតុ

ឲ្យមេធាវីរបស់ខ្លួនចំនួន ៥ រូប បញ្ជូនលិខិតមួយច្បាប់មក អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដោយមានបញ្ជាក់មិនសមស្រប។

អង្គហេតុខាងលើ ជាបទល្មើសជាក់ស្តែង គឺ បទបដិសេធក្នុងការចូលខ្លួន ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០១៦ តាមបញ្ញាតិមាត្រា ៥៣៨ នៃក្រមព្រហ្មទណ្ឌ ដែលចែងថា *"រាល់បុគ្គលណាដែលត្រូវបានកោះហៅឲ្យមកឆ្លើយជាសាក្សីនៅមុខអយ្យការ ឬចៅក្រមស៊ើបសួរ ឬមុខតុលាការព្រហ្មទណ្ឌ ហើយមិនព្រមចូលខ្លួនតាមដីកាកោះហៅនោះដោយគ្មានមូលហេតុសមស្របត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែដល់ទៅ៦(ប្រាំមួយ) ខែនិងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១.០០០.០០០ (មួយលាន) រៀល"*។

បានឃើញមាត្រា ៤៤ នឹងមាត្រា ១២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

## សម្រេច

បើកការស៊ើបសួរចំពោះអង្គហេតុខាងលើ និងស្នើសុំ

☑ ដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ[3]

- ឈ្មោះ **ក ស ខ** ភេទប្រុស អាយុ ៦៣ឆ្នាំ (គ្មានខ្លួន)។

☑ ដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ[4]

ធ្វើនៅអយ្យការ, ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៦

**តំណាងអយ្យការ**

**សៀង សុខ**

ព្រះរាជអាជ្ញារង

---

[3] នៅក្នុងពេលត្រូវចោទ

[4] កាតព្វកិច្ចណាមួយដែលបានចែងនៅក្នុងមាត្រា ២២៣